## ការិយាល័យនិពន្ធ
កាសែត " ខ្មែរប៉ុស្តិ៍ " ប្រចាំសហរដ្ឋអាមេរិក

ឆ្នេរខាងលិច
- មាជ សុវណ្ណារ៉ា
- តឹម សារឿន
- ម៉ៅ ចិត្រា
- ភា នាថ
- សុភា ឫទ្ធិ
- ម៉ី សម្ផស្ស
- ចាន់ កុសល
- សុវណ្ណារិទ្ធ

ឆ្នេរខាងកើត
- ពិន សំខុន
- សួន សើរី
- ម៉ម យិន
- តឹម ភឿន
- ឆន យ៉ុង

# ខ្មែរប៉ុស្តិ៍
# The Khmer Post

## ទូរស័ព្ទពាណិជ្ជកម្មខ្មែរប៉ុស្តិ៍ ហ្វីឡាដែលហ្វីយ៉ា
- សុបិន : (២៦៧) ២៥៣-៣៩៤៧
- ទូរស័ព្ទ នៅរ៉ូដអាយឡិន
- សើរី : (៤០១) ៩១៩-៩៩៥៤

ទូរស័ព្ទវិទ្យុសម្លេងខ្មែរអាមេរិកាំង
- ស៊ីជន : (២១៥) ២៨៤-១៣៤៣

Email : thekhmerpostEC@gmail.com

KHMER BILINGUAL BIWEEKLY NEWSPAPER

VOLUME 02 ISSUE 16 June 21th- July 04th 2008 ADVERTISING (267) 253-3947 WWW.THEKHMERPOST.COM

## ស្ថានភាពអន្លង់វែង នៅថ្ងៃទី ០២ មេសា ឆ្នាំ ១៩៩៨



ដោយ : ពិន សំខុន

●ចំនួនជិត ១ ខែ ហើយដែលអន្លង់វែង បានទទួលការវាយប្រហារបកមកវិញ ពីសំណាក់ក្រុមខ្មែរក្រហម ដែលទើបនឹងផ្តាច់ខ្លួន ( តទៅទំព័រទី០៧ )

## សម្តេចក្រុមព្រះ ហ៊ុន សែន ចង់បញ្ចប់ជីវិតនយោបាយ និងបន្តការនិរទេសព្រះអង្គ

គូឡាឡាំពួ,ម៉ាឡេស៊ី : មាជ សុវណ្ណារ៉ា

●●●សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ដែលជាអតីតសហនាយករដ្ឋមន្ត្រីទី១ បានមានព្រះបន្ទូលប្រាប់កាសែតខ្មែរប៉ុស្តិ៍កាលពីថ្ងៃទី០៨ ខែ មិថុនា ដោយប្រតិកម្មតបតថា សំដីលោក ហ៊ុន សែន ( តទៅទំព័រទី ១២ )

## រក្សា និង ដានី ទទួលបានរង្វាន់



ដានី រក្សា

●ប្រណាំងរថយន្តតូចប្រើពន្លឺថ្ងៃ រក្សា ជាកូនខ្មែរ អាយុ ១១ ឆ្នាំ និង ដានី កូនឡាវ អាយុ ១២ឆ្នាំ រៀនសាលាហ្វិនឡេជ័រ រួមដៃគ្នាកសាងរថន្តប្រើបន្លឺថ្ងៃ ហើយប្រកួត បានជ័យជំនះលេខ ២ក្នុងចំណោមអ្នកប្រកួតចំនួន៧៩នាក់ ... BRAVO REAKSA និង DANNY ! (តទៅទំព័រទី០៦)

# លោក ជន ម៉ាកេន មានគូប្រកួតហើយ



ជន ម៉ាកេន



បារ៉ាក់ អូបាម៉ា

ដោយ : ស៊ី ជន

●●●លោក បារ៉ាក់ អូបាម៉ា បានត្រូវតែងតាំងជាផ្លូវការជាបេក្ខជនប្រធានាធិបតី រួចហើយ បន្ទាប់ពីបានជ័យជំនះយ៉ាងស្វិតស្វាញលើលោកស្រី អ៊ីឡារីគ្លីនតុន ។

លោក បារ៉ាក់អូបាម៉ា ជាបេក្ខជនស្បែកខ្មៅទី១ ដែលបានទទួលឋានៈដ៏ខ្ពង់ខ្ពស់នេះ លោកត្រូវប្រឈមមុខប្រកួតជាមួយលោក ជន ម៉ាកេន នៃគណបក្សសាធារណរដ្ឋ ដែលការប្រកួតនេះ ត្រូវគេទស្សន៍ទាយថា "ឡានប្រកួតដល់ផ្លូវលោក់ខ្លាំងហើយ សូមដាក់ខ្សែក្រវ៉ាត់" ( តទៅទំព័រទី០៧ )

## "ខ្មែរកណ្តាលស្រោច វាលរាល់យោជ រកខ្មោចមិនឃើញ"

ដោយ : ពិន សំខុន

●●●នេះជាសម្តីរបស់មនុស្សចំណាស់ម្នាក់ នៅហ្វីឡាដែលហ្វីយ៉ា ដែលបានត្រូវកូនបង្កើតរបស់ខ្លួន ហៅប៉ូលិសឱ្យនាំខ្លួនទៅដាក់ពេទ្យព្យាបាលសរសៃប្រសាទ ។ ខ្ញុំបានជួបគាត់នៅមន្ទីរពេទ្យព្យាបាលជម្ងឺ ហើយគាត់បន្ថែមប្រាប់ខ្ញុំទៀតថា "ខ្លួនខ្ញុំជាខ្មែរ តែជា"ខ្មែរឆ្កោច" ពីខ្ញុំនិយាយច្រើន គេថា ខ្ញុំឆ្កួត " ។ គាត់ពុំបានត្រូវគេអនុញ្ញាតិឱ្យចេញមកក្រៅដូចដែលគាត់ទាមទារនោះទេ ព្រោះស្ថានភាពគាត់អាចនឹងបណ្តាលឱ្យបង្កើតការគ្រោះថ្នាក់ដល់អ្នកដទៃបានគាត់បានត្រូវពេទ្យរក្សាខ្លួននៅច្រើនថ្ងៃ ហើយខ្លួនខ្ញុំនៅពេល ឮសម្តីរបៀបនេះ ពុំអាចចាត់ទុកថា គាត់ជាមនុស្សឆ្កួត ( តទៅទំព័រទី១៧ )

សូមអញ្ជើញស្តាប់វិទ្យុសម្លេងខ្មែរអាមេរិកាំង
AM 1540 ផ្សាយចេញពីស្ថានីយ៍ New world Radio








Youth Voice Project
Phone : Glenn Wrighten
267-918-6284

Every Saturday 3-4 PM

Voice of Khmer
Phone :
(215) 722-2226

# បន្ទប់បរិយាកាស សូមពិសាភេសជ្ជៈមួយកែវ

## នៅបារ៍ TIPSY BAR & LOUNGE

ជាហាងក្មេងខ្មែរធំធំបំផុត នៅតំបន់ហ្វីឡាខាងជើង

ធីបស៊ី មាន "បារ៍" មាន "ឡោនជ៍"

ទទួលភ្ញៀវនឹងរាំកំសាន្តយ៉ាងសប្បាយរីករាយ



ធីបស៊ី នឹងនាំឱ្យលោកអ្នកចង់រាំកំសាន្ត

Live D.J. every Fri & Sat night from 9 p.m. – 2 p.m.
(pool table)

មានក្រុមតន្ត្រីសម័យ ឬ DJ ចាក់ចម្រៀងពីរោះៗឱ្យស្តាប់ រៀងរាល់រាត្រី ថ្ងៃសុក្រ ថ្ងៃសៅរ៍ ពីម៉ោង ៩ យប់ ដល់ម៉ោង ២ ភ្លឺ

**មានតុបុកប៊ីយ៉ាទៀតផង**

Ralph Rinn
Tel: 215.305.5763
Cell: 267.968.3413
Michael Lay (General Manager)
215.409.4772
Email: tipsybar@gmail.com

Sun-Thu: 10 – 12 a.m.
Fri & Sat: 10 – 2 a.m.
Kitchen Open Daily
Sun-Sat: 10 – 11 p.m.
3904 Frankford Ave.
Philadelphia, Pa 19124

---

## សាលារៀន "ឡូហ្គានហុប"

LOGAN HOPE

តម្លៃទាប,គុណភាពសិក្សាខ្ពស់ នៅក្នុងថ្នាក់ដែលសិស្សតិច
សូមអញ្ជើញចុះឈ្មោះថ្នាក់ K ឬថ្នាក់ទី១ នៅខែកញ្ញាខាងមុខ



Low cost, quality education in small classes
Join us for K or 1st grade in September
LOGAN Hope School
4934 N 13th St
Philadelphia, PA 19141
(215) 455-7442

---

## ក្រុមហ៊ុនទេសចរណ៍ខ្មែរ

Since 1997

ក្នុង និងក្រៅប្រទេស

**LOW FARE TRAVEL, INC.**

Domestic & International
OFFICE IN THE UNITED STATES
CALIFORNIA-FLORIA-ILLINIOS-N.COROLINA-MASSACHUSET

1800 s. 15TH Street. Philadelphia, Pa 19145 USA

តម្លៃចុះថោក ពិសេសទៅស្រុកខ្មែរ,ឡាវ និងវៀតណាម

Special offers to Cambodia/Lao, Thai, & Vietnam:

មានសេវាទៀត
- Passport
- Passport
- Lawyer referrals

- China
- Eva
- All Nippon
- Korean
- Singapore
- Thai
- Northwest
- Cathay
- Asiana
- Japan

**ទៅលេងស្រុកខ្មែរ...**

មានតម្លៃពិសេសជូនលោក លោកស្រី លោកយាយលោកតា បងប្អូន មីងមា ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ បុណ្យទូក អកអំបុក និងសំពះព្រះខែ ។ សូមជ្រើសរើសយន្តហោះ ដែលលោក លោកស្រី លោកយាយ លោកតា បងប្អូន មីងមា ចង់ជិះធ្វើដំណើរតាមបំណង...





To book a reservation call @
PHONE 215-462-0886/CELL 215-833-3669
OFFICE HOURS
Monday-Friday 4-8 PM/EST
Saturday-Sunday 10-4 PM/EST

We're accepted all methods of payment. We're very proud to serve you for the last 11 years, and your business with is highly appreciated.

---

FreeLife
The Himalayan Goji Company®

# the World's Most Powerful Anti-Aging Food

ចំណីដែលទប់ទល់ជរាភាពដ៏ខ្លាំងជាងគេក្នុងលោក
គឺទឹកផ្លែឈើ "គោជី" នៃព្រៃហេមពាន្ត

## HIMALYAN GOJI Juice






ការសម្ងាត់នៃសុខភាពល្អរបស់ពួកអាស៊ីបានត្រូវរកឃើញ នារជ្ជកាលស្តេចតាំងឆ្នាំ ៨០០ គ.ស ពលរដ្ឋនៃតំបន់មួយនៅព្រៃហេមពាន្តមិនព្រមចាស់-សក់ក៏មិនស-ធ្មេញក៏មិនបាក់-គេថា អ្នកស្រុកបានផឹកទឹកអណ្តូងមួយដែលមានដើម "គោជី "ដុះជុំវិញ គេស្មានថា មានវត្ថុសក្តិសិទ្ធអ្វីមួយជួយថែរក្សាពួកគេ ។ ទើបឥឡូវនេះ គេដឹកថា "គោជី " មានជីវជាតិពិសេសមួយឈ្មោះ POLYSACHARIDES ដែលពុំមាននៅផ្លែឈើឯណាទៀតសោះ ដែលជួយដល់ប្រព័ន្ធការពារខ្លួនរបស់មនុស្សបាន ។

បើចង់បាន Goji មកពិសារសូំជាវតាម www.forever.freelife.com
ឬក៏ទូរស័ព្ទលេខ : **(267) 253-3947**

SHARE THE SECRET

## TIME Magazine wrote :

*" this year's breakout (Superfruit ) was the Himalayan Goji Berry, said to be a source of energy and longevity ".* To order, please visit the website at : **www.forever.freelife.com**

**Or please call (267) 253-3947 to order**

# សកម្មភាពដ៏ស្ងប់ស្ងាត់របស់សមាគមខ្មែរក្នុងរដ្ឋរ៉ូដអៃឡិន្ត

*ដោយ : សេរីភាព*

"ខ្ញុំនឹងជួយឱ្យខ្មែរដែលគ្មានផ្ទះ អាចទិញផ្ទះបាននៅ... ។ ខ្ញុំនឹងបើកបង្រៀនសំរាប់ចាស់ៗ និងអ្នកដែលចង់ប្រលងចូលសញ្ជាតិអាមេរិក... ។ ខ្ញុំនឹងបង្កើតឱ្យមានសេវាកម្មបកប្រែភាសាខ្មែរ សំរាប់ជួយចាស់ៗ ដែលត្រូវទៅមន្ទីរពេទ្យ ឬទៅសុំប្រាក់ចាស់ជរា និងជួយរកការងារឱ្យខ្មែរធ្វើ... ។ ខ្ញុំ សុវណ្ណ ឈួក គ្មានប្រពន្ធរស់នៅម្នាក់ឯង សុំដាក់ចិត្តបំរើសហគមន៍ខ្មែរក្នុងរដ្ឋ រ៉ូដអៃឡិន្ត នេះ ហើយបើបងប្អូនមានការ សូមកុំខ្លាចទូរស័ព្ទមកខ្ញុំ... ទូរស័ព្ទខ្ញុំបើក២៤ម៉ោង រង់ចាំជួយដោះស្រាយបញ្ហាជូនបងប្អូន... ។ល។"

●ខាងលើនេះជាពាក្យសន្យាយ៉ាងសង្ខេបរបស់លោក សុវណ្ណ ឈួក ប្រធានសមាគមខ្មែរ ក្នុងរដ្ឋរ៉ូដអៃឡិន្ត កាលពីពេលដែលលោកទើបនឹងជាប់ឆ្នោតដំបូង កាលពីថ្ងៃអាទិត្យ ទី១៧ ខែធ្នូ ឆ្នាំ២០០៦ ក្នុងមណ្ឌលសហគមន៍វេសអ៊ីន នាទីក្រុងប្រូវីដិន រដ្ឋរ៉ូដអៃឡិន្ត ។ មកដល់ថ្ងៃនេះ ពាក្យសន្យានេះមានអាយុកាលចំនួនមួយឆ្នាំ និង៦ខែគត់ ពោលគឺអាណត្តិរបស់លោក សុវណ្ណ ឈួក បានជិតផុតទៅទៀតហើយ តែសំរាប់ប្រជាពលរដ្ឋ និងសហគមន៍ខ្មែរក្នុងរដ្ឋរ៉ូដអៃឡិន្តទាំងមូល គឺនៅមិនទាន់បាននរណាម្នាក់ ឬក្រុមគ្រួសារណាមួយទទួលបានសេវាកម្មនេះឡើយ ។ តាមពាក្យសន្យាកាលពីពេលឃោសនាបោះឆ្នោត ។

អតីតប្រធានសមាគមខ្មែរមួយរូបដែលសុំលាក់ឈ្មោះ បានបង្ហាញពីទស្សនៈរបស់លោកឱ្យដឹងថា "លោកដឹងតាំងពីដំបូងមកម្ល៉េះថា ក្រុមរបស់លោក សុវណ្ណ ឈួក គឺមិនអាចជួយអ្វីខ្មែរកើតទេ ព្រោះប្រជាពលរដ្ឋក្នុងរដ្ឋរ៉ូដអៃឡិន្តនេះ អ្នកណាក៏គេស្គាល់ពីសមត្ថភាពរបស់លោក និងចរិតរបស់លោកយ៉ាងច្បាស់ថា ជាមនុស្សពូកែតែនិយាយភាសាមិនបានការ និងឡូឡារកតែស្រាផឹកតែប៉ុណ្ណោះ ។ ប៉ុន្តែដោយសារពលរដ្ឋខ្មែរយើងដែលទៅបោះឆ្នោតមិនបានតាមដាន និងមិនបានស្គាល់ឱ្យបានច្បាស់ពីមនុស្សនេះ ទើបបណ្តាលឱ្យចាញ់កលល្បិចឃោសនា "។


លោកស្រី និត សារិន អគ្គហិរញ្ញិក
លោក សារ៉ាក់ សាយ អគ្គលេខាធិការ
លោក សុវណ្ណ ឈួក ប្រធានសមាគម

ប្រជាពលរដ្ឋខ្មែរជាច្រើនបានរិះគន់ថា "ក្នុងអាណត្តិរបស់លោក សុវណ្ណ ឈួក គេឃើញមានសកម្មភាពតែពីរដងគត់ គឺធ្វើពិធីជប់លៀងរៃអង្គាសយកលុយក្នុងពេលបុណ្យចូលឆ្នាំខ្មែរ តែត្រង់ថា ប្រមូលបានប៉ុន្មាន? ហើយយកប្រាក់ទាំងនោះទៅចំណាយធ្វើអ្វីខ្លះជាប្រយោជន៍សំរាប់សហគមន៍ខ្មែរ គឺមិនដែលមានរបាយការណ៍ ឬមានព័ត៌មានផ្សព្វផ្សាយឱ្យខ្មែរបានដឹងទាល់តែសោះ" ។ លោកស្រី សុធី មានអាយុ៥២ឆ្នាំ រស់នៅក្នុងរដ្ឋរ៉ូដអៃឡិន្ត បានមានប្រសាសន៍ថា "ខ្ញុំឮប្រធានសមាគមលោក សុវណ្ណ ឈួក និយាយថា សមាគមនឹងបើកបង្រៀនអ្នកចង់ប្រលងចូលសញ្ជាតិ ដូច្នោះខ្ញុំបានរង់ចាំជិតពីរឆ្នាំហើយ តែនៅមិនឃើញមានបង្រៀន ។ ខំឱ្យកូនទូរស័ព្ទទៅការិយាល័យសមាគមក៏គ្មានអ្នកលើកទូរស័ព្ទដែរ ក្រោយមកទើបដឹងថា ការិយាល័យនោះគ្មានអ្នកប្រចាំការទេ គឺគេគ្រាន់តែជួលចោលទុកគ្រាន់ជួបជុំគ្នាប្រជុំ និងស៊ីផឹកម្តងម្កាលតែប៉ុណ្ណោះ" ។

មិនមែនមានតែលោកស្រី សុធី ទេ ដែលរិះគន់សមាគមខ្មែរ ក្នុងអាណត្តិរបស់លោក សុវណ្ណ ឈួក តែក៏មានខ្មែរជាច្រើនគ្រួសារបានត្អូញត្អែរ និងរិះគន់លោក សុវណ្ណ ឈួក ថា មិនគោរពបច្ចុប្បន្ននេះប្រជាពលរដ្ឋខ្មែរក្នុងរដ្ឋរ៉ូដអៃឡិន្ត គឺនៅតែគាំទ្រអតីតប្រធានសមាគមចាស់ គឺលោក អ៊ុម សុផុន ហើយបើមានកិច្ចការអ្វីៗ គេច្រើនតែទំនាក់ទំនងទៅលោក អ៊ុម សុផុន ឱ្យជួយ ព្រោះទូរស័ព្ទសមាគមគ្មានអ្នកទទួលទូរស័ព្ទទៅលោក សុវណ្ណ ឈួក ក៏មិនទទួល ឬជួនកាលទទួលតែនិយាយខុសរឿងមិនបានការ ហើយមិនបានបំពេញសំណូមពរ និងតំរូវការបន្ទាន់របស់ពួកគេ ។ ជាពិសេសអ្នកដែលជួលផ្ទះសមាគមរស់នៅ គឺគេទំនាក់ទំនង និងហៅតែលោក អ៊ុម សុផុន ទេ ពីព្រោះពេលផ្ទះមានបញ្ហាអាចហៅលោក អ៊ុម សុផុន មកជួយបានគ្រប់ពេល ។

អ្នកជិតស្និទ្ធជាមួយលោក សុវណ្ណ ឈួក ម្នាក់ប្រាប់ថា "ប្រធានសមាគមរូបនោះមិនដែលគិតគូរពីកិច្ចការរបស់សមាគមទេ គឺគិតគូរ និងធ្វើតែកិច្ចការណាដែលមិនត្រូវធ្វើទៅវិញ" ។ លោកបន្ថែមថា គណៈកម្មការសមាគមធ្លាប់បានប្រជុំ និងជំរុញឱ្យលោក សុវណ្ណ ឈួក ឈប់បន្តជួលការិយាល័យដែលចំណាយប្រាក់បានមកពីឈ្នួលផ្ទះសមាគមនេះទៀតទៅហើយរៀបចំ

(តទៅទំព័រទី០៩)

# កេង វ៉ាន់សាក់: គេប្រឌិតរឿងខ្ញុំ ព្រោះតែការច្រណែនចង់បានមរតកជាផ្ទះរបស់ខ្ញុំ

*ដោយ : សួន សេរីវុឌ្ឍា*

●●●មិត្តអ្នកអានជាទីគោរព មុនជូនអត្ថបទនេះ ខ្ញុំបាទសូមធ្វើការកែតំរូវនូវអត្ថបទមុនដូចតទៅ :

១-ប្អូនស្រីរបស់លោក ស៊ាន ម៉ាសាវ៉ាង នៃក្រុមខ្មែរម្ចាស់ស្រុកមិនមែនឈ្មោះ ស៊ាន ម៉ាសាវ៉ន ទេ គឺឈ្មោះ ស៊ាន សារឿន ហើយប្តីរបស់លោកស្រីឈ្មោះលោក ឌី សាផាត ។

២-ប្រពន្ធទីពីររបស់លោក បណ្ឌិត កេង វ៉ាន់សាក់ មិនមែន ឈ្មោះ សុវណ្ណ ទេ គឺឈ្មោះ ស៊ីវ៉ន ។

៣-ថ្ងៃរៀបការរបស់លោក បណ្ឌិត កេង វ៉ាន់សាក់ មិន មែន២៩ មេសា ដូចពាក្យចចាមអារ៉ាមនោះទេ គឺថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៨ ។

អ្នកប្រាជ្ញខ្មែរលោកបណ្ឌិត កេង វ៉ាន់សាក់ ដែលត្រូវរងនូវពាក្យរិះគន់ថា រៀបការជាមួយស្រីក្មេងជាជនជាតិយួននោះ បានមានប្រសាសន៍ប្រតិកម្មថា "បើគេថាខ្ញុំរៀបការជាមួយស្រីក្មេងនោះវាជារឿងពិត តែនាងប្រពន្ធខ្ញុំមិនមែនមានអាយុ៣៨ឆ្នាំ ដូចគេថានោះទេ តាមពិតនាងមានអាយុ៤៣ឆ្នាំហើយ ។ តែពាក្យថា នាងប្រពន្ធខ្ញុំជាស្រីយួននោះ ជាការមួលបង្កាច់ទាំងស្រុង ព្រោះខ្ញុំបានស្គាល់បងប្អូនសាច់ញាតិក្រុមគ្រួសារ និងជីវិតកំណើតរបស់នាងយ៉ាងច្បាស់តែបើថាក្រុមគ្រួសារនាងមានជាប់សែស្រឡាយ ចិន-ខ្មែរ នោះខ្ញុំអាចទទួលបាន" ។


លោក កេង វ៉ាន់សាក់

លោកស្រី មា គា ជាសាក្សី និងជាភ្ញៀវដែលបានចូលរួមក្នុងពិធីមង្គលការរបស់លោកបណ្ឌិត កេង វ៉ាន់សាក់ បានប្រាប់ថា "អ្វីដែលគេនិយាយទាំងអស់នោះ គឺជាការប្រឌិតជារឿងមិនពិត និងជាពាក្យកុហកទាំងអស់" ។ លោកស្រី មា គា បន្តថា "ជាពិសេសអ្នកទាំងនោះមិនមែនជាអ្នកដែលបានចូលរួមក្នុងថ្ងៃមង្គលការរបស់លោកបណ្ឌិត កេង វ៉ាន់សាក់ ទៅទៀត ព្រោះសូម្បីតែថ្ងៃរៀបការក៏និយាយមិនត្រូវដែរ ។ ថ្ងៃរៀបការ

( តទៅទំព័រទី១១ )

**កេង វ៉ាន់សាក់ គេប្រឌិតរឿង...**

ពិតប្រាកដ គឺថ្ងៃសៅរ៍ ទី២៦ ខែមេសា មិន


សូមអញ្ជើញចូលរួម ពិព័រណ៍អំពី អត្ថប្រយោជន៍ សំរាប់ បុរស ស្ត្រី ដែលមានវ័យចំណាស់ មកពីអាស៊ីអាគ្នេយ៍

រៀបចំដោយ CASA & SEAMAAC

**ថ្ងៃ សៅរ៍ ទី 28 មិថុនា 2008**

**10 am – 2 pm**

**សួនច្បារ Dickinson Square Park**

**ផ្លូវលេខ 4th និង Morris Streets**

សូមអញ្ជើញនាំយកគ្រួសារ ឬ អ្នកជិតខាង និង មិត្តភ័ក្ត មកកំសាន្តរដូវក្តៅ នៅសួនច្បារ!

សូមស្វែងយល់ពី អត្ថប្រយោជន៍ ដែលលោកអ្នក អាចទទួលយកបាន!

ការថែទាំសុខភាព (Health Care) ផ្ទះសំណែរ (Housing and Utilities) ចំណីអាហារ (Food)

មធ្យោបាយធ្វើដំណើរ (Transportation) ការងារ (Employment) សេវាសង្គម (Social Services)

ការអាសន្ន (Emergency) ជំនួយហិរញ្ញវត្ថុ (Financial Support) សេវាច្បាប់ (Legal Services)

សេវាតាមផ្ទះ និង សហគមន៍ (Home & Community-based Services)

មានអ្នកបកប្រែភាសា ចិនកុកងឺ ចិនកួងតុង វៀតណាម ខ្មែរ ឡាវ ថៃ

**គូររូបលើមុខ**
សូមនាំកូនចៅលោកអ្នក មកចូលរួមសប្បាយ ជាមួយការគូររូបលើមុខ!

**អាហារឥតគិតថ្លៃ**
ផ្តល់អាហារឥតគិតថ្លៃ ដល់អ្នកមានអាយុ 60 ឡើងទៅ។ ពួកយើងស្វាគមន៍អំណោយ (Donation) ពីអ្នកចូលរួមផងដែរ។

បើមានសំនួរ សូមទាក់ទងមក ដាហ្វីនី លី នៅ SEAMAAC (215) 467 0690, daphnelee@seamaac.org

PCA PHILADELPHIA CORPORATION FOR AGING
Cambodian-American Senior Association, Inc. C.A.S.A
SEAMAAC

# "នាទីកាសនិទានសម្រាប់បិតា"

## សេចក្តីឧទ្ទិសរបស់អ្នកកវីនិពន្ធកំណាព្យ "វាចាឪពុក"

*ដោយ : ម៉ម យិន*



•សូមជំរាបបញ្ជាក់ពីគោលបំណងខ្ញុំបាទដោយយល់ឃើញថា បុត្រាបុត្រីទាំងអស់នៅក្នុងលោកីយនេះ សុទ្ធតែមានមាតាបិតាជាអ្នកបង្កើតមក ហើយមាតាបិតាសឹងតែទាំងអស់ សុទ្ធតែបានបំពេញកាតព្វកិច្ចរបស់ខ្លួនយ៉ាងពេញលេញបំផុត ដោយសេចក្តីស្រឡាញ់អាណិត និងបីបាច់ថែរក្សាយ៉ាងស្មោះត្រង់អស់ពីកំលាំងកាយកំលាំងចិត្តឥតមានសំចៃឡើយ ជាពិសេសមាតាបិតាតែងមានដក់ជាប់នៅក្នុងចិត្តជានិច្ចនូវសេចក្តីសង្ឃឹមយ៉ាងមាំថា នឹងឃើញរស្មីភ្លឺដ៏ត្រចះត្រចង់របស់បុត្រធីតាទៅអនាគត ដោយបានឃើញសេចក្តីសម្រេចជោគជ័យនៅក្នុងពេលបញ្ចប់ការសិក្សាជាយុវវ័យ និងក្នុងវ័យជាបន្តទៅខាងមុខទៀត ។

ដូច្នេះការនិពន្ធកំណាព្យនេះក៏ជាសេចក្តីរំលឹកដាស់តឿនទូន្មានប្រៀនប្រដៅដល់បុត្រធីតាទាំងអស់ឱ្យត្រង់ត្រាប់ និងប្រព្រឹត្តិតាមឱ្យបានហ្មត់ចត់ ដើម្បីទុកជារស្មីដ៏ត្រចះត្រចង់នៃអនាគតរបស់ខ្លួន និងជាសេចក្តីសង្ឃឹមយ៉ាងមាំនៃមាតាបិតាទាំងអស់ផង ។

ខ្ញុំបាទសូមឧទ្ទិសកំណាព្យនេះ បានចូលទៅដល់ក្រអៅបេះដូងនៃឪពុកគ្រប់រូបទាំងអស់នៅក្នុងលោកឱ្យមានសេចក្តីសន្តោសប្រោសប្រណីស្រឡាញ់ទូន្មានប្រៀនប្រដៅ ដោយសន្តានចិត្តស្មោះត្រង់បរិសុទ្ធដល់បុត្រធីតាទាំងអស់ឱ្យបានឃើញពីសេចក្តីស្រឡាញ់ដ៏ធំមហិមារបស់ឪពុកដែលតែងតែមានចំពោះបុត្រធីតា ។

# វាចាឪពុក

| | |
|---|---|
| សម័យថ្ងៃមួយ | អរសប្បាយណាស់ក្នុងគ្រួសារ |
| ជាថ្ងៃសំរាកពីការងារ | ដែលអស់ប្រជាតែងមានពិត ។ |
| ជាមុខរបរប្រចាំខ្លួន | ឱ្យបានមាំមួនក្នុងជីវិត |
| បានរស់ប្រពៃហើយបានស្ថិត | ក្នុងក្តីពិសិដ្ឋចិត្តសុខំ ។ |
| ពេលនោះល្អណាស់ទើបឪពុក | បានមកជួបមុខកូនតូចធំ |
| ដោយអរសប្បាយហើយប្រជុំ | ប្រាប់កូនឧត្តមតទៅថា ។ |
| ឱកូនស្ងួនភ្ងាទាំងប្រុសស្រី | ពុកតែងស្រដីប្រាប់ពុំងារ |
| ដើម្បីទូន្មានបុត្រធីតា | ឱ្យបានថ្លៃថ្លាមានរស្មី ។ |
| ចូរកូនខិតខំផ្ចង់តាំងចិត្ត | ស្តាប់ពាក្យពិសិដ្ឋពុកស្រដី |
| ដោយសារតែពុកមានសេចក្តី | ស្រឡាញ់ពេកក្រៃចំពោះកូន ។ |
| កូនអើយរូបពុកជាមនុស្សម្នាក់ | ដែលមានភារៈរៀបចំក្បួន |
| ដើម្បចម្លងបុត្រមាសស្ងួន | ឱ្យបានជួបជួនក្តីឧត្តម ។ |
| សេចក្តីស្រឡាញ់ដែលពុកមាន | ដក់ចាប់ក្នុងប្រាណនោះសែនធំ |
| គ្មានជនផ្សេងណាអាចបន្លំ | ថាខ្លួនគេខំស្មោះស្នេហ៍ស្និទ្ធ ។ |
| ជនណានិយាយរបៀបនេះ | កូនត្រូវត្រិះរិះឱ្យឃើញពិត |
| មុននឹងជឿគេផ្ញើជីវិត | ហើយទៅស្នេហ៍ស្និទ្ធនិងគេនោះ ។ |
| កូនអើយចូរកូនពិចារណា | ដោយយកប្រាជ្ញាមកពិគ្រោះ |
| ថាអ្នកណាមួយដែលត្រង់ស្មោះ | ហើយជួយសង្គ្រោះជីវិតបុត្រ ។ |
| ឪពុកជាអ្នកបង្កើតកូន | ស្រឡាញ់មាសស្ងួនខ្លាំងបំផុត |
| ខំថែរក្សាយ៉ាងហ្មត់ចត់ | ឱ្យកូនបរិសុទ្ធចាកទុក្ខភ័យ ។ |
| ពេលកូននៅតូចពុកថ្នាក់ថ្នម | លើកពរបីបមយ៉ាងប្រពៃ |
| បំប៉នអាហារកូនរាល់ថ្ងៃ | យ៉ាងល្អពេកក្រៃគ្មានត្អូញត្អែរ ។ |
| លុះកូនបានធំចំរើនវ័យ | ឪពុកលកលៃមិនបង្អែ |
| ចូលទៅសាលារៀនសុទ្ធតែ | វិជ្ជាផ្លាស់ប្រែកែជីវិត ។ |
| ពេលនេះជាពេលដ៏ឧត្តម | កូនអើយត្រូវខំហើយប្រព្រឹត្តិ |
| សិក្សារៀនសូត្រតាមកំរិត | ដែលគ្រូប្រៀនព្រឹទ្ធជារាល់ថ្ងៃ ។ |
| ចូរកូនចងចាំកុំបីភ្លេច | នូវភារៈកិច្ចដ៏ថ្លាថ្លៃ |
| លោកគ្រូអាចារ្យបានស្រដី | ឱ្យកូនយល់ន័យលោកបង្រៀន ។ |
| ពាក្យចាស់បានពោលមកយ៉ាងនេះ | បើកូនចង់ចេះកុំខ្មាសអៀន |
| ត្រូវសាកសួរគ្រូដោយក្លាហាន | នោះកូនទើបបានយល់បញ្ហា ។ |
| បើអ្នកចង់ចេះនូវវិជ្ជា | ចូរកុំរុញរាសម្លាប់អាចារ្យ |
| បើអ្នកចង់បានកូនស្ងួនភ្ងា | កុំខ្មាសភរិយាទើបបានពិត ។ |
| រីពាក្យថាសម្លាប់អាចារ្យ | ពាក្យនេះប្រែថាសួរជំរិត |
| ដេញដោលអាចារ្យឱ្យល្អន់ល្អិត | តាមដោយគំនិតចង់បានចេះ ។ |
| មិនមែនសម្លាប់ផ្តាច់ជីវិត | គឺការក្បៀកកិតសុំតិរិះ |
| ឱ្យគ្រូពន្យល់អស់ចំណេះ | ទើបយើងបានចេះដូចគ្រូដែរ ។ |

( តទៅទំព័រទី១១ )

# ជនជាតិថៃនៅតែចោទថា ខ្មែរជាអ្នករំលោភលើអធិបតេយ្យភាពទឹកដីប្រទេសថៃ

*ហ៊ឿងាំងលហ៊ឿយ៉ា : ម៉ម យិន*





**ប្រទេសថៃ :** កាលពីថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០០៨ បណ្តាញទូរទស្សន៍ថៃមួយឈ្មោះ ASTV ដែលគេស្គាល់ថា ជាទូរទស្សន៍ផ្សព្វផ្សាយសុទ្ធតែជាការប្រឆាំងនឹងរដ្ឋាភិបាលដែលអនុវត្តនយោបាយពុំត្រឹមត្រូវប្រាសចាកពីផលប្រយោជន៍ប្រទេសជាតិមានការប្រព្រឹត្តអំពើទុច្ចរិតពុករលួយជាដើម ។

ដោយសារតែគោលបំណងនិងសេចក្តីប្តេជ្ញាជាដាច់ខាតនៃអង្គការទូរទស្សន៍នេះ បានជារៀងរាល់ថ្ងៃ២៤ម៉ោង គេឃើញ TV នេះផ្សាយចេញតែពីកិច្ច-ការនយោបាយទាំងអស់សំរាប់ពន្យល់ និងផ្តល់ការសិក្សារៀនសូត្ររំលឹកដាស់តឿនជនជាតិថៃឱ្យគិតតែរឿងផលប្រយោជន៍ប្រទេសជាតិថៃខ្លួនឯងតែប៉ុណ្ណោះ ។

ទោះបីបញ្ហាខ្លះ មិនត្រឹមត្រូវក្នុងការពួកនេះលើកឡើងមកផ្សព្វផ្សាយ ដែលទុកជាបញ្ហារបស់ប្រទេសជិតខាងមានប្រ-ទេសខ្មែរជាដើម ក៏ទូរទស្សន៍នេះ បាននាំយកមនុស្សសំខាន់ៗ

( តទៅទំព័រទី០៩ )

From :Philadelphia



ហាងខ្មែរជួសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

Rathe`s Auto Service

State and Emission
Inspection General
Repairs and Maintenance

MON-SAT, 8:30AM -5:30PM
SUN. EMERGENCY ONLY




-ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
-មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
-មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ -មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨
ទៅ : -ដូរប្រេងកំរិត ៥ ក្វាត $22. - INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ ពាក់-មានជូនប័ណ្ណពិសេស សំរាប់ដូរប្រេង ចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
-តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត
- ប្តេជ្ញាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ ។
ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL: (215) 329-2418
Fax: (215) 329-2419.Rath CELL: (215) 431-6376

## Danny and Reaksa won the Solar Car Race

It is a happy day for Reaksa Lim and Danny Lo. The two best friends since 3rd- 5th grade just landed on the 2nd place during the Solar Car Race at the Wissahickon Middle School on May 31st, 2008. Out of 79 Solar Car racers, their car was the fastest runner and could have achie-ved the first prize winner if it were-n't stopped in the middle of the road because the wire that connec-ted to the battery got lose for a second. The Solar Car project was assigned to stu-dents and moni-tored by the sci-ence teachers from different local middle schools for a month prior to the event.



Reaksa Lim is 11 and Danny Lo is 12 years old. They are currently attending T.K. Finletter middle school. Unlike Lo who is Laos-American born, Lim was born in 1997, Cam-bodia, and moved with his family to Philadelphia, Pennsylvania in 2004. At the age of seven, Reaksa experienced cultural shocks and language barrier when he started his first day in the kinder-garten.

His father, Mr. Hasvan Lim, said, "Reaksa learned English very fast. I remember his first day at school, I got a phone call from school said he was crying, the teacher did not understand why. When I got there, I found that he cried because he was too hungry. The lunch time was at 12 p.m., but they let the girls serve first. He was too hungry, and did not understand the culture why girls were served first, or knew how to say he was hungry." The next day, Reaksa came back to school with three words, "I'm hun-gry" to be able to say to the teacher. Everything was fine and he was happy.

Mr. Lim also added, "for sure he didn't know English, but he kept every notes and papers, and I tutored him with reading about one year, he was on his own."

Lim and Lo are now the members of Civil Air Patrol in their school to learn about how to become a pilot for the air force, they are also the safety members for their school halls, and beside the serious and educational activities, the children also in the music team. They both play Clarinet.

សុខភាព

## ជំងឺសំពាធឈាមខ្ពស់

•យើងដឹងហើយថា ជំងឺលើសឈាមនេះ ក៏ដូចជាជំងឺមើលមិនជាដាច់ដទៃទៀត ដូចទឹកនោមផ្អែម ជំងឺក្រិនថ្លើម ជំងឺហឺត ជំងឺមហារីក ហួសរយៈពេលវះកាត់ ជំងឺអេដស៍ ។ល។ តែពុំមានន័យថា មានជំងឺលើសឈាមហើយ គឺចប់នោះទេ ចេះថៃធ្នូន ចេះតមចំណី ចេះតាមបញ្ជាគ្រូពេទ្យដោយខ្ជាប់ខ្ជួន អ្នកមានជំងឺនេះអាចរស់ក្នុងជីវិតមួយដ៏សុខសាន ហើយមានអាយុវែង ដូចមនុស្សដទៃទៀតដូច្នោះដែរ ។ ហេតុនេះហើយ មនុស្សមានជំងឺនេះ ឬអត់មានជំងឺនេះក៏ដោយត្រូវអនុវត្តតាមតម្រាខាងក្រោមនេះ (សម្រាប់អ្នកមានជំងឺហើយកុំឱ្យជំងឺវិវឌ្ឍន៍ទៅមុខទៀត ។ អ្នកពុំទាន់ឈឺ កុំឱ្យជំងឺកើតឡើងបាន )។



១-របបអាហារទទួលទានអាហារឱ្យសមល្មមកុំឆ្អែតពេករបៀបនេះធ្វើឱ្យរាងកាយរក្សាបានលំនឹងសុខភាពមួយយ៉ាងប្រសើរ ហើយមានកម្លាំងបំបាត់បានភាពខ្ជិលច្រអូស ។ បរិភោគបន្លែស្រស់ឱ្យបានច្រើនតមខ្លាញ់ ប្រើប្រេងឆា។ កុំពិសារសាច់ច្រើនហួសហេតុ ។ ក្នុងករណីនេះគេសង្កេតឃើញថា មនុស្សទទួលទានអាហារបួស (Vegetarian foods) មិនសូវមានជំងឺលើសឈាមនេះទេ។ ក្នុងរបបអាហារពួកក្រុមនេះ គេមិនសូវប្រើជាតិប្រៃហួសហេតុទេ គ្មានខ្លាញ់ជាតិប្រេងក៏តិច ។ ម្ហូបអាហារប្រៃ ដែលគួរជៀសវាង ឬប្រើតិចបំផុតនោះមាន ដូចតទៅ: ប្រហុក ផ្អក មាំ កាពិ ទឹកត្រី ទឹកស៊ីអ៊ីវជ្រក់ ឆាយប៉ូវ គួរជៀសវាងប្រេងខ្យង នឹងប៊ីចេងផងដែរ ព្រោះរូបមន្តរបស់អាហារទាំងពីមុខនេះក៏មានសំបូរដោយជាតិអំបិលដែរ ។

**២-ហាត់ប្រាណ :** ពិធីហាត់ប្រាណគួរអនុវត្តសម្រាប់មនុស្សគ្រប់វ័យ ។ ក្មេងការពារកុំឱ្យធាត់ និងធ្វើឱ្យឈាមរត់បានស្មើល្អ មនុស្សចាស់ពិសេសអ្នកមានជំងឺលើសឈាមពិធីហាត់ប្រាណក្លាយជាភាពចាំបាច់ តែអ្នកមានជំងឺនេះ មិនត្រូវហាត់ឱ្យហួសកម្លាំងទេ ធ្វើយ៉ាងនេះ អាចមានផលវិបាកទៅវិញទេ ។

**(សូមរង់ចាំអានជំងឺទឹកនោមផ្អែមយើងនឹងលើកមកជម្រាបជូននៅពេលក្រោយ )**

## CASA និង MHASP សហការណ៍



•ម្ដាយឪពុក ជីតា ឬជីដូន ប្រមាណ១០នាក់ បានចូលរួមក្នុង "កម្មវិធីពីក" PEAK PROGRAM របស់សមាគម MHASP សហការណ៍ដោយសមាគមព្រឹទ្ធាចារ្យខ្មែរ CASA នៅហ្វីឡាដែលហ្វីយ៉ាខាងត្បូង កាលពីថ្ងៃព្រហស្បត្តិ៍មុន ។

សមាគមខ្មែរភាគច្រើនពុំបានដឹងថា "រដ្ឋ" បានផ្ដល់សេវាយ៉ាងសំខាន់ៗជូនដល់ពលរដ្ឋទាំងអស់ឱ្យអាចជួយការពារថែរក្សានឹងគាំទ្រការសិក្សាការចិញ្ចឹមកូនចៅបាននោះទេ ។ ហេតុដូច្នោះហើយ PEAK មានបំណងផ្ដល់ថាមពលជូនមាតាបិតានូវចំណេះ ដែលអាចណែនាំកូនចៅឱ្យមានប្រសិទ្ធភាពជាទីបំផុតបន្ថយភាពក្រីក្រ ភាពអវិជ្ជា ពីក្រុមគ្រួសារខ្មែរ នៅ "ហ្វីឡា" ឱ្យបានក្រាស់ក្រែល ។

កម្មវិធីព័ត៌មាន៨សប្ដាហ៍ ក្នុងមួយសប្ដាហ៍មាន២ម៉ោង គឺនៅរៀងរាល់ល្ងាចថ្ងៃព្រហស្បត្តិ៍ ចាប់ពីម៉ោង៦ដល់ ៨ ល្ងាច នៅទីស្នាក់ការ CASA ៕




Nail Technicians are needed!

Pay on salary base
or commission 6/4
Room & Board is available
for out of area workers!
We are located on
214 Eagle Valley Mall,
East Stroudsburg, Pa 18301
Please call Mr. Trang
(570) 350 - 4114 for details!

យើងត្រូវការជាងធ្វើក្រចក ជូនជាប្រាក់ខែ ឬ ក៏ជាកុមីស្យុង
ក៏បាន មានកន្លែងសំណាក់ជូនដល់ជាងដែលមកពីឆ្ងាយផង
សូមហៅរកលោក **ត្រាំង**

**(510) 350-4114 បើចង់ជ្រាបច្បាស់**

# The Way You Make Me Feel


EMY PHAT

You make me feel special,
You make me feel new,
You make me feel loved,
With everything you do.

You hold me close when I am sad.
You wipe the tears from my face.
Every time we are together,
It seems like the perfect place.

My eyes light up when you enter a room.
I smile when we are together.
No matter how bad things are,
You always make them better.
I love the way you kiss me,
The way you hold me tight.
I love the way you touch me,
I could be with you all night.

I love the way you can make me laugh
For absolutely no reason at all.
I love how no matter what I do,
You will be there to catch me when I fall.

I just want you to know,
That even though we sometimes fight,
I will always love you!
No matter what, day or night.

# ស្ថានភាពអន្លង់វែង...

ទៅចូលរដ្ឋាភិបាលភ្នំពេញ ។ ការវាយប្រហារនេះ គាំទ្រដោយ "ភ្នំពេញ" ។

រហូតមកទល់ថ្ងៃទី ១ ខែ មេសា នេះ ពាក់កណ្តាលផ្នែកខាងត្បូងនៃអន្លង់វែង បានត្រូវក្រុមផ្តាច់ខ្លួនចូលមកកាន់កាប់ ហើយក៏មានបំណងវាយផ្តាច់យកជាជ័យភ័ណ្ឌទាំងមូល នាពេលនោះផង ក៏ប៉ុន្តែ កងកម្លាំង តាម៉ុក បានប្រមូលពីជិតឆ្ងាយជុំឡើងវិញ ទាន់ពេលមានមកតាំងពីស្ទឹងត្រែង បន្ទាយមានជ័យ ឫសំឡូត ។ល។

អន្លង់វែងបានត្រូវយកមកវិញបាន នៅថ្ងៃទី ២ មេសា ដោយរុញច្រានក្រុមផ្តាច់ខ្លួន ឱ្យថយក្រោយបានប្រមាណតែ៣០គីឡូម៉ែត្រតែប៉ុណ្ណោះ ។ រីឯ តាម៉ុក ដែលជាប្រមុខផែនទីរំដោះពេលនោះ ផ្ទះគាត់ស្ថិត នៅចំកណ្តាលអន្លង់វែង ជាពិសេសនៅចំខ្សែត្រៀមថែមទៀតផងនោះ ក៏បានប្តូរទីតាំងមកនៅផ្នែកខាងជើងនៃអន្លង់វែងវិញ តាំងតែក្រុមផ្តាច់ ខ្លួនចាប់ផ្តើមវាយលុកមកម្ល៉េះ ។

ថ្ងៃធ្វើសម្ភាសន៍ជាមួយនឹង ប៉ុល ពត នៅថ្ងៃទី ០២ មេសា ១៩៩៨ នោះ គឺធ្វើនៅផ្ទះគាត់មួយទៀត ដែលនៅផ្នែកខាងជើងនៃអន្លង់វែង មិនឆ្ងាយពីផ្ទះ តាម៉ុក ទេ ។ ផ្ទះចុងក្រោយនេះ មិនមានលក្ខណៈជាផ្ទះសំណាក់ទេ តែជាសាលទទួលភ្ញៀវ ។

ថ្ងៃនោះគេពុំឃើញវរជននយោបាយ ដូចជា លោក ខៀវ សំផន លោក ចាន់ វ៉ាន់ ឬ លោក ទេព ឃុនណាល់ ដូចពេលមុនទេ អ្នកខ្លះនិយាយថា អ្នកទាំងនោះកំពុងស្ថិតនៅផ្ទះរបស់គេ ឯលើភ្នំឯណោះ ។ គួររំលឹកថា នៅកំពូលភ្នំដងរែក មានសភាពរាបស្មើ ដែលរថយន្តអាចបើកបរបានដោយពុំមានភ័យព្រួយមានទទឹងប្រមាណកន្លះគ.ម ទៅ ៣ គ.ម ហើយរាបស្មើចូលទៅក្នុងដែនដីថៃទៀតផង ។

នៅលើកំពូលភ្នំដងរែកនេះ គេអាចឃើញផ្ទះរបស់ ប៉ុល ពត នៅ "ក្បាលអន្ទេ្យង" នោះ គឺជាតំបន់មួយនៃអន្លង់វែង ដែលផ្តល់នូវសន្តិសុខច្រើនជាងគេ ជូនអ្នកដឹកនាំទាំងនោះ ។

**បទសម្ភាសន៍ជា មួយ ប៉ុល ពត**
**ថ្ងៃទី ០២ មេសា ឆ្នាំ ១៩៩៨**
**ដោយ : ពិន សំខុន**

**សំនួរ :** នៅពេលព្រឹត្តិការណ៍វាយប្រហារអន្លង់វែង គេថា លោកត្រូវជម្លាសចេញ តើមែនទេ ? សុខភាពរបស់លោកយ៉ាងណាដែរ ?

**ប៉ុល ពត :** ឆ្លើយនឹងសំនួរលោកថា តើខ្ញុំយ៉ាងណា? ឥឡូវនេះ នឹងពីមុនមក ?

គឺច្រើនឆ្នាំមកហើយ ខ្ញុំនៅអន្លង់វែង គ្រាន់តែជាការផ្លាស់ប្តូរទីកន្លែង ពីនេះទៅនោះ ពីនោះទៅនេះ តាមសភាពការណ៍ជាក់ស្តែង ។ ក្រោយមកមានព្រឹត្តិការណ៍ខែ មិថុនា ១៩៧៧ ខ្ញុំត្រូវបានគេចាប់ឃុំឃាំងឱ្យនៅផ្ទះដោយឡែកពីគេពីឯង ឥតមានទំនាក់ទំនងមហាជនអ្វីទេ ការផ្គត់ផ្គង់អ្វីក៏បានល្មមគ្រប់គ្រាន់ក្នុងការចិញ្ចឹមគ្រួសារ ដូច្នោះ ខ្ញុំឥតមានទៅណាមកណាទេ គ្រាន់តែនៅពេលមានការប្រយុទ្ធគ្នាអ្នកដែលត្រូវមានភារកិច្ចគេចាត់ចែងខ្ញុំទៅនៅកន្លែងណាមួយស្ងាត់កន្លះ ឬមួយគីឡូម៉ែត្រពីក្រុមហ្នឹង ប៉ុន្តែឱ្យស្ងាត់ដូច្នោះ ខ្ញុំឥតមានទៅណាទេ ទៅណាក៏មិនបានផង ពីព្រោះមានច្បាប់ទម្លាប់ប្រទេសគេ គេមានតម្រួត គេមានទាហាន ស្អីៗហើយ ខ្ញុំចេញចូលយ៉ាងម៉េចបាន ខ្ញុំគ្មានច្បាប់ទេ នេះឱ្យខ្ញុំសូមជំរាបថា ខ្ញុំឥតមានទៅណាទេ ខ្ញុំនៅតែតំបន់នេះ ។

រីឯសុខភាពខ្ញុំ ការពិតខ្ញុំឈឺខ្លាំងតាំងពីឆ្នាំ ១៩៩៥ ខ្ញុំធ្វើការច្រើនធ្វើទាំងយប់ទាំងថ្ងៃ ហើយវាឈឺក្បាល ក្តៅក្បាល ឈឺភ្នែក ឈឺទ្រូង ខ្ញុំមិនយល់ថាឈឺអ្វី ដល់យប់មួយនោះ វាខ្វាក់ភ្នែក ខ្ញុំភ្ញាក់ឡើងខ្ញុំស្មានថា វាជាប់ពពិកភ្នែក ញីចុះញីឡើងពីរបីដង លប់មុខអត់ឃើញពេទ្យ គេមកពិនិត្យឃើញថា មកពីបេះដូងវាហត់ពេក ។ ឈឺដល់ក្បាល ឈាមវារត់ចិញ្ចឹមមិនដល់ក្បាល មិនដល់ភ្នែកនេះបានវាខូចភ្នែកក្បាលវាក្តៅជាប់ ពីព្រោះបេះដូងវាមានវ៉ាល់ (Valve) ទ្វារវានេះ តែមួយទេ ធម្មតាមានពីរតែខ្ញុំមានតែមួយទេ ពីកំណើតមក ។ ដូច្នេះអានេះតែម្ខាងនេះ វាឥតបញ្ចេញឈាមមានតែមួយទេ វាឥតបញ្ចេញឈាម បើយើងធ្វើការធម្មតាវាមិនអីទេ តែធ្វើច្រើនឈាមវាមិនដល់ ឈឺរហូតដល់សព្វថ្ងៃ។ ហើយចាប់ពីខែមិថុនាឆ្នាំ១៩៩៧មក ខ្ញុំត្រូវឃុំឃាំងអ្វីថែមទៀត ខ្វិតតែងដុនដាប ។ ធម្មតាទេ ជាមនុស្សតែងមានបញ្ហា តែងមានទុក្ខព្រួយ

( តទៅទំព័រទី០៩ )

# លោក ជន ម៉ាកេន មានតួប្រកួត...

## តើបេក្ខជនមួយណាអាចជាប់ឆ្នោត ជាប្រធានាធិបតីសហរដ្ឋ អាមេរិក នៅអាណត្តិក្រោយនេះ ?

**ដោយ : ស៊ី ផន**

អ្នកដែលមានបទពិសោធន៍ក្នុង និងក្រៅប្រទេស ហើយមានអាយុច្រើនជាងគេគឺខ្ញុំ ជន ម៉ាកេន នឹងជាប់ឆ្នោត ធ្វើជាប្រធានាធិបតីសហរដ្ឋអាមេរិកនៅអាណត្តិក្រោយនេះ ។

លោកមានប្រសាសន៍នៅថ្ងៃ ពុធ ទី ១១ កន្លងមកនេះ នៅក្នុង International Contitution Center ក្រុងហ្វីឡាដែលហ្វីយ៉ា នៅពេលធ្វើការឃោសនាបោះឆ្នោត ដែលមានអ្នកចូលរួមប្រមាណ ៤00នាក់ ក្នុងនោះក៏មានអ្នកគាំទ្រខាងគណបក្សប្រជាធិបតេយ្យ និងអ្នកមិនប្រកាន់គណបក្ស ។ បរិយាកាសដ៏សែនអធឹកអធមសម្លេងទះដៃ ស្រែកជ័យឃោសន៍យ៉ាងរំពងមិនដាច់ ជន ម៉ាកេន ជន ម៉ាកេនៗ លោក បេក្ខជន ជន ម៉ាកេន សាធារណរដ្ឋរូបនេះ បាន មានប្រសាសន៍ក្នុង និងក្រៅប្រទេសក្នុងនោះ មានបញ្ហាសេដ្ឋកិច្ច បញ្ហាប្រេងសាំង ជាប្រធានបទមួយយ៉ាងសំខាន់ដែលបានចោទដោយសារ តែសាំងឡើងថ្លៃ ទំនិញក្នុងស្រុកក៏ឡើងថ្លៃដែរ ចំណុចនេះ លោក ជន ម៉ាកេន មានគំរោងចង់បង្កើតឧស្សាហកម្មក្នុងស្រុកអាចបញ្ឈប់ ឬបន្ថយការនាំចូលប្រេងសាំងពីបរទេស ដូចដែលសហរដ្ឋអាមេរិក បានបង្កើតថាមពលបរិមាណូ ដែលប្រើប្រាស់សព្វថ្ងៃនេះ។

សង្គ្រាមនៅប្រទេសអ៊ីរ៉ាក់ គឺជាសន្តិសុខមួយនៅមជ្ឈឹមបូពា៌ និងជាការរារាំងទប់ស្កាត់ការរាលដាលដែលអាចប៉ះពាល់ដល់សន្តិសុខរបស់សហរដ្ឋអាមេរិកនៅពេលអនាគត ។ លោកបាននិយាយពីបទពិសោធន៍របស់លោកក្នុងសភាជាច្រើនឆ្នាំ និងជាទាហានជើងចាស់ ដែលធ្លាប់ជាប់គុកឈ្លើយសង្គ្រាមនៅប្រទេសវៀតណាមអស់រយៈពេល៥ឆ្នាំ ជាភ័ព្វសំណាងគាត់មានជីវិតទោះជាខ្លួនរបស់គាត់សឹងតែក្លាយជាជនពិការក្តី ប៉ុន្តែមិត្តរួមអាវុធរបស់គាត់ភាគច្រើន មិនបានត្រឡប់មកវិញ ដូចគាត់ឡើយ លោកបានបន្ថែមទៀតថា ខ្ញុំអត់ស្រឡាញ់ធ្វើសង្គ្រាមទេ ក៏ប៉ុន្តែដោយសារតែស្រឡាញ់ជាតិ និងជនស្លូតត្រង់នៅប្រទេសអ៊ីរ៉ាក់ការដកទ័ពចេញពីប្រទេសអ៊ីរ៉ាក់ ដោយគ្មានការត្រៀមទុកមុននោះទេ ផលពិបាក និងពិបាកដោះស្រាយ នៅពេលក្រោយជាមិនខាន លោក ជន ម៉ាកេន បានមានប្រសាសន៍បន្ថែមទៀតថា កងទ័ព និងប្រជាជន អ៊ីរ៉ាក់ អាចមានតួនាទីយ៉ាងសំខាន់ ក្នុងការប្រយុទ្ធប្រឆាំង និងទទួលការការពារសន្តិសុខ និងកសាងប្រទេសគ្រប់រចនាសម្ព័ន្ធ ដោយខ្លួនឯង ពេលនោះ ទើបយើងអាចដកទ័ពបាន ។ សម្លេងទះដៃ និងសម្លេងស្រែកជ័យឃោសន៍ ជន ម៉ាកេនៗ ជាច្រើនដង ។ លោកបានបន្ថែមអំពីប្រទេស អ៊ីរ៉ង់ ដែលជាអ្នកគាំទ្រទាំងស្បៀង និងសម្ភារៈសឹកដល់ភេរវជននៅក្នុងប្រទេស អ៊ីរ៉ាក់ ។ នៅពេលនេះ លោកប្រធានាធិបតី ជច ប៊ូស កំពុងតែជួបជាមួយបណ្តាមិត្តសហគមន៍អន្តរ-ជាតិនៅ អ៊ីរ៉ាក់ ដើម្បីធ្វើការដាក់ទណ្ឌកម្មសេដ្ឋកិច្ចទៅលើប្រទេស អ៊ីរ៉ង់ ប្រសិនបើប្រទេសនេះនៅតែបន្តការចំរាញ់យកគ្រឿងអ៊ុយរ៉ាញ៉ូមតទៅទៀត ។

រីឯនៅខាងក្រៅ International Contitution Center ក្រុមប្រឆាំងមួយក្រុមផ្សេងៗទៀត ប្រមាណ ១៥ នាក់ កំពុងតែ

( តទៅទំព័រទី១០ )


# លក់ពាណិជ្ជកម្ម

លក់ឡានធំ ដឹកអាហារដ្ឋាន ដែលកំពុងតែសកម្មជាមួយពាណិជ្ជកម្មដែលស្ទាហាប់នឹងផ្តល់កំរៃខ្ពស់ លក់ក្នុងតម្លៃថោកជាងទីផ្សារ

**$ 32,000**

យើងនៅជ្រុងផ្លូវ BROARD ខាងជើងនឹង ONTABRO
ក្បែរសាកលវិទ្យាល័យ TEMPLE



LUNCH TRUCK BUSINESS FOR SALE
For $32,000
Locates on BROAD & ONTARIO
(Temple University)

**ទូរស័ព្ទ ស៊ីមន . (215) 870-7591**

Well established in American and Mediterranean breakfast and lunch: Kabab, Gyro, Steak, Hoagies, Falafel, and Vegetarian. We are located in front of Temple hospital. Please Call Simon @ 215-870-7591 for details.

# ឆ្លើយតបនឹងចំណារលិខិតអតីត...

វៀតណាមប្រើប្រាស់រណសិរ្សនេះ ដើម្បីពន្យល់ដល់ពិភពលោកថា នេះជាកងទ័ពរបស់ខ្មែរក្រហមដែលចង់វិលត្រឡប់ចូលទីក្រុងភ្នំពេញវិញ ។ វៀតណាមបានពន្យល់ដល់ពិភពលោកថា នេះជាកងទ័ពកម្ពុជាដែលវិលចូលមកកម្ពុជាកាន់កាប់ភ្នំពេញវិញ ហើយមិនមែនជាការឈ្លានពានរបស់វៀតណាមឡើយ។ តាមសភាពជាក់ស្ដែង វាគ្រាន់តែជាការពន្យល់ ប៉ុន្តែខ្ញុំអាចអះអាងបញ្ជាក់ប្រាប់ថា ក្រោយសង្គ្រាមជាមួយនឹងកម្ពុជាឡើយ។ អគ្គលេខាធិការបក្សបានដឹកនាំគណៈ-ប្រតិភូវៀតណាម មកកាន់ទីក្រុងភ្នំពេញ ដើម្បីចរចាស្វែងរកសន្តិភាពតាមបណ្ដោយព្រំដែន ។

**សំណួរទី២ :** ប៉ុល ពត បាននិយាយថា មេញ្ជាការកងទ័ពខ្មែរក្រហមជាច្រើននាក់នៃភូមិភាគបូព៌ា បានគាំទ្រ និងធ្វើការឱ្យវៀតណាម ហើយ រហូតមកដល់ពេលនេះ នៅមិនទាន់មាននរណាម្នាក់ដឹងច្បាស់នៅឡើយទេថា តើវាពិតឬមិនពិតនោះ ?

**ប៉ុយ ទីន ឆ្លើយ :** វាជាការពិតពីព្រោះដូចដែលខ្ញុំបានប្រាប់ខាងដើម គឺថា នៅសម័យបារាំងមានតែខ្មែរឥស្សរៈ (ខ្មែរយៀកមិញ) ជាង ១០០ នាក់ នៅក្នុងវៀតណាមខាងជើង។ ក្រោយពីទស្សនកិច្ចរបស់ អៀង សារី ទៅកាន់ទីក្រុងហាណូយ អ្នកទាំងអស់នោះ ត្រូវបានបញ្ជូនមកកាន់ប្រទេសកម្ពុជាវិញ។

ពេលមកដល់ព្រៃក្នុងទឹកដីខ្មែរ ខ្មែរក្រហមក៏បានសម្លាប់ចោលទៅ ។ ខ្មែរក្រហមក៏បានសម្លាប់ជនជាតិខ្មែរទាំងអស់នោះចោល ពីព្រោះពួកគេគិតថា អ្នកអស់ទាំងនោះជាតិញខ្មែរក្រហម ក៏បានសម្លាប់ជនជាតិខ្មែរ ដែលមកពីភូមិភាគបូព៌ានៃប្រទេស ហើយនិងមកពីវៀតណាមខាងត្បូង ពីព្រោះនៅក្នុងវៀតណាមខាងត្បូងមានខេត្តជាច្រើនដែលប្រជាពលរដ្ឋខ្មែររស់នៅដូចជាខេត្ត ត្រាវិញ ជាដើមនោះ ។

**សំណួរទី៣ :** លោកបាននិយាយថា លោក អៀង សារី បានធ្វើទស្សនៈកិច្ចនៅវៀតណាម ដើម្បីជួបជាមួយនឹងអតីតខ្មែរឥស្សរៈ (ខ្មែរយៀកមិញ) ហើយនាំអ្នកទាំងនោះមកកាន់កម្ពុជាវិញ តើនៅឆ្នាំណាដែរ ?

**ប៉ុយទីន ឆ្លើយ:** ខ្ញុំគិតថា នៅសម័យសង្គ្រាមអាមេរិកកាំង នៅឆ្នាំ១៩៧១ គឺនៅពេលដែលលោក អៀង សារី អមដំណើរត្រង់ សីហនុ និងមហេសីទ្រង់ទៅកាន់ទីក្រុងហាណូយ ដើម្បីធ្វើការបញ្ជូនខ្មែរឥស្សរៈ (ខ្មែរយៀកមិញ)ទាំងអស់នោះមកកាន់កម្ពុជាវិញ ។

**សំណួរទី៤ :** ដូច្នេះមានខ្មែរយៀកមិញជាច្រើនបានវិលមកតាមសម្ដេចនរោត្តម សីហនុ និងលោក អៀង សារី ចូលមកក្នុងប្រទេសខ្មែរវិញមែន ឬទេ ?

**ប៉ុយទីន ឆ្លើយ :** មិនមែនមកជាមួយអ្នកអស់ទាំងនោះទេ គឺគេមកតាមក្រោយ ។

**សំណួរទី៥ :** លោកបាននិយាយថា ខ្មែរក្រហមបានសម្លាប់ខ្មែរយៀកមិញទាំងនោះ តើពួកត្រូវសម្លាប់នៅឆ្នាំណា ?

**ប៉ុយទីនឆ្លើយ :** នៅអំឡុងពេលរបបខ្មែរក្រហម មេបញ្ជាការ និងទាហានខ្មែរក្រហមជាច្រើននាក់ បានត្រូវចាប់មកពីភូមិភាគបូព៌ា យកមកឃុំ និងសម្លាប់ចោលនៅគុកទួលស្លែងក្នុងក្រុងភ្នំពេញដោយធ្លាប់ចោទថា ជាតិញរបស់កងទ័ពវៀវណាម ដែលព្យាយាមផ្ដួលរំលំរបបខ្មែរក្រហម តើលោកបានដឹងរឿងហ្នឹងច្រើនប៉ុណ្ណោះ ?

**ប៉ុយទីន ឆ្លើយ :** វាមិនពិតទេ ខ្មែរមានមនោសញ្ចេតនាខ្លះៗជាមួយនឹងវៀតណាម ប៉ុន្តែពួកគេមិនមែនជាតិញយកការណ៍ឱ្យវៀតណាមនោះឡើយខ្ញុំមិនគិតដូច្នោះទេ ។

**សំណួរទី៧ :** នៅពេលដែលមានមេដឹកនាំពីក្នុងហាណូយបានសម្រេចចិត្តឈ្លានពានប្រទេសកម្ពុជា នៅឆ្នាំ១៩៧៨តើពួកគេមានបានពិភាក្សាជាមួយនឹងពួកខ្មែរក្រហមដែលបានចុះចូលជាមួយនឹងកងទ័ពវៀតណាមដេរ ឬទេ ដូចជា លោក ប៉ែន សុវណ្ណ លោក ហ៊ុន សែន លោក ហេង សំរិន និងលោក ជា ស៊ីម ជាដើម ?

**ប៉ុយទីនឆ្លើយ :** មែនហើយពួកគេបានរៀបចំរួមគ្នា នៅក្នុងព្រៃ នាស្រុកស្នួល នៅជាប់នឹងព្រំដែនខេត្តថាយនិញ ។ យើងបានជួបទាហានចំនួន៣ក្រុម ហើយក្រុមទាហាន ដែលទាហានទាំងនោះ គឺជាកងអនុសេនាធំរបស់ខ្មែរក្រហម។

**សំណួរទី៨ :** ខ្ញុំសូមបញ្ជាក់ត្រង់នេះបន្តិច ។ សំណួរខ្ញុំពិតជានៅពេលដែលមេដឹកនាំវៀតណាមជួបពិភាក្សាគ្នានៅទីក្រុងហាណូយ អំពីបញ្ហាថា តើត្រូវឈ្លានពានកម្ពុជា ឬក៏អត់ ? តើមានមេដឹកនាំអ្នកតស៊ូខ្មែរ ដូចខ្ញុំរៀបរាប់ខាងលើបានចូលរួមពិភាក្សាពីផែនការប្រយុទ្ធជាមួយនឹងខ្មែរក្រហមដែរ ឬទេ ?

**ប៉ុយទីនឆ្លើយ :** ខាងខ្មែរមិនត្រូវបានអនុ-ញ្ញាតឱ្យចូលរួមពិភាក្សាដោយផ្ដោតលើផែនការនោះទេ ។ វៀតណាបានពន្យល់ដល់លោក ប៉ែន សុវណ្ណ និងអ្នកផ្សេងទៀត ក្រោយពេលដែលគេបានធ្វើផែនការរួចហើយ ។ លោក ប៉ែន សុវណ្ណ បានស្នាក់នៅក្នុងទីក្រុងហាណូយអស់រយៈពេលជាច្រើនឆ្នាំ ។ គាត់គឺជាប្រធានវិទ្យុនៃទីក្រុងហាណូយ ផ្នែកភាសារខ្មែរ ។ ហើយលោកផងដែរ ពីឆ្នាំ១៩៦២ ហើយក្រោយមកអំឡុងពេលផ្ដើមការតស៊ូប្រឆាំងរបប លន់ នល់ លោកក៏បានក្លាយទៅជាប្រធានវិទ្យុផ្នែកភាសាខ្មែររបស់ខ្មែរក្រហមនៃទីក្រុងហាណូយ ហើយគាត់ក៏បានរៀបការជាមួយនឹងស្ត្រីវៀតណាមទៀតផង ។ នៅពេលនោះគាត់និយាយតែភាសាយួនទេ ហើយគាត់មានឱកាសប្រើភាសាខ្មែរក្រហមនៅការងារតែប៉ុណ្ណោះ ។ ការងារដំបូងរបស់លោក ប៉ែន សុវណ្ណ នៅក្នុងប្រទេសវៀតណាម គឺនៅក្នុងផ្នែកចារកម្ម ។

**សំណួរទី៩ :** មានពាក្យចរចាមអារាមខ្លះថា ភរិយារបស់លោក ប៉ែន សុវណ្ណ គឺជាកូនស្រីរបស់ឧត្តមសេនីយវៀតណាមម្នាក់មែន ឬទេ ?

**ប៉ុយទីន ឆ្លើយ :** មិនមែនទេ ។ ប្រពន្ធរបស់លោក ប៉ែន សុវណ្ណ គឺជានារីសាមញ្ញស្រុកស្រែម្នាក់ ។ ប៉ែន សុវណ្ណ ធ្វើការនៅក្នុងវិទ្យុទីក្រុងហាណូយមានមុខងារជាប្រធានផ្នែកខេមរភាសា ហើយនៅពេលដែលគាត់ធ្វើការនៅក្នុងជួរកងទ័ព គាត់មានមុខងារជាអនុសេនីយ៍ឯកតែប៉ុណ្ណោះ។ តើលោកស្គាល់លោកខាង សារិន ទេ ? លោកខាង សារិន គឺជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ គាត់ក៏ធ្លាប់បានបម្រើការនៅក្នុងជួរកងទ័ពវៀតណាមនៅទីក្រុងហាណូយផងដែរ ។

ក្រោយពីបានដឹងពីសំណួរ និងចម្លើយរបស់អតីតមន្ត្រីជាន់ខ្ពស់ និងជាអគ្គនិពន្ធនាយកនៃសារព័ត៌មានវៀតណាមខាងលើនេះមក "ខ្មែរ-ប៉ុស្ដិ៍ " បានធ្វើសេចក្ដីសរុប និងសន្និដ្ឋានទៅលើព្រឹត្តិការណ៍សម័យសង្គ្រាមដែលអតីតមហាក្សត្រសម្ដេចនរោត្តម សីហនុ បានចារលិខិតឃើញថា មានការបញ្ជាក់បង្ហាញឱ្យឃើញច្បាស់ថា ទង្វើ

( តនៅទំព័រទី១០ )

**Washington Wellness Care** មន្ទីរថែរក្សាខ្លួនប្រាណ"វ៉ាស៊ីនតុន"

Medical & Rehab.

ដោយវិជ្ជាពេទ្យ និងការបង្ហាត់រាងកាយឱ្យដើរឡើងវិញ

Medical & Rehab.
500 Washington Ave., 1st Fl.
Philadelphia, Pa 19147
Phone: 215.551.6838. Fax: 215.551.6718

**Dr. Scott C. Tran, D.C. Dr. Michael Barno, D.C. Dr. Zohar Stark, M.D.**

***We are specialized in treating:***

- Auto Accident Injuries - Work Related Injuries - Slip & Fall Injuries

**យើងមានជំនាញក្នុងការព្យាបាល :**

☞ របួសដោយគ្រោះថ្នាក់រថយន្ត ☞ របួសដោយទាក់ទងនឹងកន្លែងធ្វើការ ☞ របួសដោយរអិល ឬដួល

We have staffs who speaks Vietnamese, Chinese, and Cambodian
For Cambodian and Vietnamese Speaking Staff, please call Ricky Son at 215.380.1350
For English Speaking Staff, please call 215.551.6838

**យើងមានបុគ្គលិកដែលនិយាយភាសា វៀតណាម, ភាសាចិន , និងភាសាខ្មែរ**
ទាក់ទងជាមួយបុគ្គលិកខ្មែរ និងវៀតណាម សូមទូរស័ព្ទទៅ រីគី សុន **(215) 380-1350**
ទាក់ទងទៅបុគ្គលិកនិយាយភាសាអង់គ្លេស សូមទូរស័ព្ទទៅ **(215) 551-6838**

## នេះជាបារមីនៃការលះបង់...

អារ៉ែក្រមម្សៅតែងតួមានតិចជាងគេបំផុត ។ ទោះបីនាងចូលចិត្តតែសៀតផ្កាធម្មជាតិនៅគុម្ពត្រចៀក តែនាងមានភ្ញៀវតាមរកច្រើនជាងគេបំផុត ។ នាងបានចូលមកដណ្ដើមតួនាទី ដណ្ដើមឆ្នាំងបាយពីអ្នកដទៃក្នុងទីនោះសឹង "ស៊ីដាច់" ទៅហើយ ។ ព្រោះហេតុនឹងហើយទើបនាងផ្សេងៗដែលរួមមុខរបររករឿងតប់នាង ធ្វើឱ្យជាំមុខជាំមាត់ ទ្រាំមិនបានទាល់តែប្ដូរតំបន់ប្រយុទ្ធជារឿយៗ ។ ប្រាក់កាសសន្សំបាន នាងផ្ញើតាមរយៈទូរគមនាគមន៍ទៅលោកនាយកសាលា សំរាប់កសាងតាមគម្រោងដែលនាងបានគិតទុកមុនជាស្រេច នាងពុំបានផ្ញើជូនឪពុកម្ដាយនាងឡើយ ។ លោកនាយកបានធ្វើតាមបណ្ដាំអ្នកគ្រូខំជួសជុលសាលាយ៉ាងស្ងៀមស្ងាត់ ។ គេចេះតែចង់ដឹងថា លោកនាយកបានប្រាក់ពីណាមកជួសជុលសាលាទឹកមុខញញឹមៗគាត់ឆ្លើយយ៉ាងខ្លីថា មានសប្បុរសជនម្នាក់សុំជួយសាលាកំសត់នេះ ដើម្បីក្មេងៗអភ័ព្វក្នុងភូមិយើង ។ តែអ្វីដែលខំប្រឹងលាក់ខ្លាំង គេក៏កាន់តែចង់ដឹងខ្លាំងណាស់ដែរ ។ ក្រោយបំផុត តាមការបង្ហើបពីសេវាទូរគមនាគមន៍ គេក៏បានជ្រាបទាំងអស់គ្នាថា លុយជួសជុលសាលាបានមកពីអ្នកគ្រូ អ៊ឹងថៃហ្វ ។

មានអ្នកសារព័ត៌មានមូលដ្ឋានមួយចំនួនតាមសុំនាង ដើម្បីបានសម្ភាសផ្ទាល់ ។ នាងតែងតែសុំអនុញ្ញាតបានជំទាស់យ៉ាងទន់ភ្លន់ ព្រោះតែមុខរបរ ជួញកេសរ លក់ពិដោរដែលនាងកំពុងធ្វើដូចសព្វថ្ងៃ ។

នាងបានកត់ត្រាប្រចាំក្នុងសៀវភៅកំណត់ហេតុរបស់នាង ខែដំបូងបានទិញក្ដារខៀន ធ្វើអំពីប្រភេទឈើលេខមួយនឹងប្រក់ដំបូលថ្នាក់រៀន ។ ខែទីពីរទិញតុនឹងជើងម៉ាធ្វើអំពីឈើមួយចំនួន ។ ខែទីបីទិញសៀវភៅសិក្សា ។ ខែទីបួនទិញកន្សែងក្រហមរ៉.ក ចែកឱ្យសមាជិកសកម្មទាំងអស់ក្នុងសាលា។ ខែទីប្រាំប្ដេជ្ញាថា គ្មានសិស្សណាម្នាក់ដើរទៅសាលាដោយជើងទទេ ។ ខែទីប្រាំមួយ អ្នកគ្រូ អ៊ឹងថៃហ្វ ឆ្លៀតមកមើលថ្នាក់នឹងសាលាម្ដង ។ កូនសិស្សហ៊ោរកញ្ជ្រៀវសើចសប្បាយរត់មករោម នាងៗយំនាងនិយាយពុំរួច គ្រួសមួយដុំកំពុងស្ទះបំពង់កនាង !។

រួចហើយខែទី៧ ទី៨ ទី៩ឆ្លងផុតទៅយ៉ាងរលូន សាលាចេះតែបានបំពេញបន្ថែមដោយសម្ភារៈផ្សេងៗថ្មីៗ។ រួចខែ១១នាងបានទិញ ដងទង់ជាតិបញ្ឈរកណ្ដាលទីធ្លាសាលាឱ្យសិស្សបានឈរគោរពទង់ជាតិរួចហើយ អ្នកគ្រូចាប់ផ្ដើមមានផ្ទៃពោះហើយត្រូវរកឆ្នប់ពន្លួតចេញ។

**(នៅមានតនៅលេខក្រោយទៀត)**

## ជនជាតិថៃនៅតែចោទថាខ្មែរ...

លុះមកដល់ពេលនេះ ហេតុអ្វីបានជាក្រុមប្រឆាំងរដ្ឋាភិបាលថៃនេះ ចេះតែខិតខំព្យាយាមលើកបញ្ហានេះមកចោទ ដោយបំពានទៅលើប្រទេសខ្មែរថា ជាអ្នកធ្វើអ្វីៗតាមទំនើងចិត្តតែម្នាក់ឯង មិនព្រមឱ្យប្រទេសថៃមានចំណែកចូលរួមបែងចែកផលប្រយោជន៍ដ៏ធំធេងចេញពីប្រាសាទព្រះវិហារ និងពីដែនទឹកសមុទ្រ ក្នុងការធ្វើអាជីវកម្មឧស្ម័នធម្មជាតិ និងប្រេងកាតនេះផង ដែលជាហេតុបណ្ដាលឱ្យប្រទេសថៃត្រូវខាតបង់ផលប្រយោជន៍មហាសាល សំរាប់ប្រទេសជាតិថៃ នៅពេលបច្ចុប្បន្ន និងទៅអនាគត ។

ការប្រជុំបាតុកម្ម និងការថ្លែងប្រកាសរបស់ក្រុមស្នេហាជាតិថៃ តាមរយៈបណ្ដាញទូរទស្សន៍ ASTV ផ្សាយចេញទៅពេញពិភពលោកនេះបានភ្ជាប់បញ្ហាប្រាសាទព្រះវិហារ និងដែនទឹកសមុទ្រនេះធ្វើជាប្រធានបទមួយសំខាន់បំផុតត្រូវបានវាគ្មិនគ្រប់រូបលើកយកមកថ្លែងយ៉ាងក្អេងក្អាងបំផុត ក្រោមការទះដៃយ៉ាងកងរំពងនៃមហាជន ។

ទេសភាពបង្ហាញរូបភាពទាំងនេះ បញ្ជាក់ឱ្យឃើញថា ក្រុមនេះកំពុងប្រព្រឹត្តអំពើឈ្លានពានដោយអយុត្តិធម៌ និងឃោឃៅបំផុតមកលើអធិបតេយ្យភាពទឹកដីប្រទេស និងជនជាតិខ្មែរជាពិសេសមានគោលបំណង និងចេតនាប៉ុនប៉ងខិតខំព្យាយាមធ្វើយ៉ាងណាឱ្យជនជាតិ និងប្រទេសខ្មែរត្រូវរលំរលាយឱ្យអស់ទៅ ដើម្បីជនជាតិថៃ មានឱកាសរឹបអូសយកប្រទេសខ្មែរទាំងមូលឱ្យក្លាយទៅជាប្រទេសថៃពិតប្រាកដណាស់ ៕

**តមកពីទំព័រទី០៤**

## វាចាឪពុក

កូនអើយរយៈពេលសិក្សា
ជាពេលថ្លៃថ្លារកគ្មានទេ
បើកូនប្រហែសហើយគិតតែ
សប្បាយដើរលេងគ្មានរៀនសោះ ។
លុះពេលហួសទៅទើបកូនដឹង
មកពីមិនប្រឹងធ្វើឡេះឡោះ
ស្ដាយពេលវេលាដែលហួសនោះ
នេះហើយពីព្រោះមិនស្ដាប់គ្រូ ។
ព្រមទាំងមិនស្ដាប់ឪពុកម្ដាយ
មាមីងទាំងឡាយខំគិតគូរ
ពន្យល់ទូន្មានយ៉ាងហែហូរ
ឱ្យកូនបានស៊ូរកវិជ្ជា ។
វិជ្ជាជាទ្រព្យដ៏វិសេស
នៅលើលោកនេះសែនថ្លៃថ្លា
ជាទ្រព្យសំខាន់គ្មានជនណា
មកប៉ងប្រាថ្នាលួចបានឡើយ ។
វិជ្ជាធ្វើឱ្យអស់ពួកមនុស្ស
មានកេរ្តិ៍មានឈ្មោះរស់សុខស្បើយ
ជនជិតខាងកូនបានដឹងហើយ
គេមិនកន្តើយស្រឡាញ់ស្និទ ។
ហេតុនេះចូរកូនចាំឱ្យច្បាស់
ពាក្យពេចន៍ល្អណាស់ជាប់ក្នុងចិត្ត
ដើម្បីឱ្យកូនបានស្ថេរស្ថិត
ក្ដីសុខពិសិដ្ឋអាយុវែង ។
ព្រមទាំងប្រកបក្ដីសប្បាយ
ទាំងចិត្តទាំងកាយយ៉ាងក្រៃលែង
មានកំលាំងខ្លាំងហើយខែងរែង
កិត្តិយសចាំងចែងសែងរស្មី ។
ពាក្យពេចន៍ឱ្យពរនៅចុងក្រោយ
ដល់កូនគ្រាណាត្រើយមាសថ្លើមថ្លៃ
ឱ្យបានជួបព្រះដ៏ជោគជ័យ
មានរិទ្ធិបារមីក្រៃអស្ចារ្យ ។
សូមព្រះអង្គមកគង់ជាមួយ
ថែរក្សាជួយនាំយាត្រា
ក្នុងផ្លូវជីវិតពិតសោកា
រហូតលុះត្រាដល់ត្រើយអើយ ៕

***សូមអរគុណ !***

មែនថ្ងៃអង្គារ៍ ទី២៩ ខែមេសា ដូចគេបានផ្សព្វផ្សាយក្នុងពាក្យប្រឌិតនោះទេ ។ លោកស្រីបន្តថា "ក្នុងថ្ងៃរៀបការនោះ គ្មានពាក់អាវយ៉េ និងគ្មានភ្ញៀវជាជនជាតិយួនទេ ពោលគឺភ្ញៀវទាំងអស់ជាជនជាតិខ្មែរ ដែលជាមិត្តជិតស្និទ្ធជាសាច់ញាតិ និងអ្នកដែលលោកបណ្ឌិត កេង វ៉ាន់សាក់ ស្គាល់" ។

លោកស្រី មា គា បានបញ្ជាក់យ៉ាងច្បាស់ថា "អ្នកដែលបង្កើតពាក្យចចាមអារ៉ាមនោះ គឺជាអ្នកដែលមានគំនិតច្រណែន និងជាអ្នកដែលចង់បានកេរ្តិ៍មរតករបស់លោកបណ្ឌិត កេង វ៉ាន់សាក់" ។ លោកស្រីបន្ថែមថា "ខ្ញុំស្គាល់ពួកអ្នកមានគំនិតខូចទាំងអស់នោះយ៉ាងច្បាស់នោះ គឺពួកអ្នករស់នៅស្រុកបារាំងនេះមានលោកស្រី អ៊ុង ប៊ុនហោ និងលោក ទូច គីម-សួ" ។

ចំណែកលោកបណ្ឌិត កេង វ៉ាន់- សាក់ក៏បានបញ្ជាក់យ៉ាងដូច្នេះថា "ពួកអ្នកដែលគេចង់ធ្វើបាបខ្ញុំដែលរួមមានទាំងអ្នកស្រី ស៊ាន សារឿន ដែលត្រូវជាប្អូនស្រីលោក ស៊ាន ម៉ាសាវ៉ាង និងលោកស្រី សេង មាឃលី ដែលត្រូវជាសាច់ញាតិថ្លៃខាងលោក ស៊ាន ម៉ាសាវ៉ាង នោះ គេធ្លាប់បានមកផ្ទះរបស់ខ្ញុំ និងបានបង្ខំឱ្យខ្ញុំទៅសុំប្រាក់រដ្ឋ និងចេញទៅនៅផ្ទះរដ្ឋទៅហើយទុកផ្ទះដែលខ្ញុំនៅឱ្យគេ ឬលក់ឱ្យក្នុងតម្លៃថោកឱ្យគេ ព្រោះគេគិតថា ខ្ញុំគ្មានកូនគ្មានចៅឯណាមកស្នងមរតកទេ ។


លោក សួន សេរីរដ្ឋា

ក្នុងដំណើរមកកាន់សហរដ្ឋអាមេរិក លោក ស៊ាន ម៉ាសាវ៉ាង ជាមួយនឹងគូកន គឺលោកស្រីបណ្ឌិត ចក់ សុខុន ក្នុងក្រុមដែលមានឈ្មោះថា "ខ្មែរម្ចាស់ស្រុក" បាននិយាយប្រាប់គេឯង ដែលរួមមានទាំងចាស់ៗមួយចំនួនដែលជាអតីតៈសិស្សរបស់លោកបណ្ឌិត កេង វ៉ាន់សាក់ ថា "លោក កេង វ៉ាន់សាក់ ចិញ្ចឹមក្មេងស្រីយួនយូរណាស់មកហើយៗ ឥឡូវរៀបការយកស្រីយួននោះធ្វើជាប្រពន្ធទីពីរ ។ ដូច្នោះត្រូវឈប់នាំគ្នាជឿលោក កេង វ៉ាន់សាក់ តទៅទៀត" ។ អតីតសិស្សលោកបណ្ឌិត កេង វ៉ាន់សាក់ ដែលរស់នៅទីក្រុងបុស្តុន ក្នុងរដ្ឋម៉ាសាឈូសេតម្នាក់ដែលត្រូវជាមិត្តភ័ក្តិរបស់លោក ស៊ាន ម៉ាសាវ៉ាង ផងដែរនោះ បានបញ្ជាក់ថា "ពួកគាត់នាំគ្នាជឿលោក ស៊ាន ម៉ាសាវ៉ាង ព្រោះគិតថាជាក្មួយនិងជាសាច់ញាតិខាងឪពុកចិញ្ចឹមរបស់លោក កេង វ៉ាន់សាក់ តែមិននឹកស្មានថា ពួកនេះ (ក្រុមខ្មែរម្ចាស់ស្រុក) មកនិយាយពាក្យកុហកបោកប្រាស់គេមួយពិភពលោកយ៉ាងនេះសោះ"។ ឆ្លើយតបទៅករណីលោក ស៊ាន ម៉ាសាវ៉ាង នៃក្រុមខ្មែរម្ចាស់ស្រុកនេះដែរ លោកបណ្ឌិត កេង វ៉ាន់សាក់ បានរៀបរាប់ឱ្យដឹងថា "តាមពិតខ្ញុំ និង ស៊ាន ម៉ាសាវ៉ាង មិនដែលទាក់ទងគ្នាជាងបីឆ្នាំមកហើយ ។ ព្រោះកាលពីរបីឆ្នាំមុន តាំងពីខ្ញុំមិនទាន់ស្គាល់នាង ស៊ីវ៉ន មកម្ល៉េះ ក្នុងពិធីជប់លៀងមួយ ស៊ាន ម៉ាសាវ៉ាង បានចាត់ទុកខ្ញុំដូចជាជនជាប់ចោទ ដោយងើបឈរក្នុងកណ្ដាលហ្វូងមនុស្ស ហើយចោទសួរខ្ញុំថា មើលពូ តើពូចិញ្ចឹមក្មេងស្រីយួននៅក្នុងផ្ទះមែនទេ ? រឿងនេះ គេដឹងពេញមួយប្រទេសអូស្ត្រាលី ដែលខ្ញុំទើបត្រឡប់នេះ" ។ លោកបណ្ឌិត កេង វ៉ាន់សាក់បានបន្ថែមថា "រឿងនោះធ្វើឱ្យគាត់ខ្មាសគេណាស់ ព្រោះនៅកណ្ដាលហ្វូងមនុស្ស ហ៊ានលើកយករឿងដែលមិនពិតដូច្នោះមកនិយាយ ។ ពេលនោះ គឺខ្ញុំនៅតែម្នាក់ឯងមិនទាន់ស្គាល់នាង ស៊ីវ៉ន ទេ ។ ហើយតាំងពីពេលនោះមក ស៊ាន ម៉ាសាវ៉ាង មិនដែលមកផ្ទះខ្ញុំ ឬបន្តមានទំនាក់ទំនងជាមួយនឹងខ្ញុំទៀតឡើយ ហើយក្នុងថ្ងៃរៀបការក៏ ស៊ាន ម៉ាសាវ៉ាង និងលោកស្រី ចក់ សុខុន មិនបានមកចូលរួមដែរ ។ ដូច្នោះពួកគេប្រឌិតរឿងរ៉ាវបែបនេះ គឺគ្រាន់តែចង់ធ្វើបាបមនុស្សចាស់ម្នាក់ និងមិនចង់ឱ្យមានអ្នកមើលថែពេលដែលខ្ញុំចាស់ ធ្វើអ្វីមិនបានតែប៉ុណ្ណោះ ។ ឯម្ខាងទៀត គឺលោកស្រី ស៊ាន សារឿន និងលោកស្រី សេង មាឃលី ដែលជាក្រុមសាច់ញាតិរបស់លោក ស៊ាន ម៉ាសាវ៉ាង ដែរនោះ គឺពួកគេចង់បានផ្ទះដែលខ្ញុំកំពុងរស់នៅសព្វថ្ងៃនេះ" ។

លោកស្រី ស៊ីវ៉ន ដែលមានអាយុ៤៣ឆ្នាំ និងជាប្រពន្ធទីពីររបស់លោកបណ្ឌិត កេង វ៉ាន់សាក់ បានឱ្យដឹងថា លោកស្រីជាកូនស្រីពៅ ដែលមានបងប្រុសចំនួនពីរនាក់ ។ ឪពុកលោកស្រីឈ្មោះ ជា ទ្រី ជាអ្នកស្រុកភ្នំពេញ និងម្ដាយឈ្មោះ សេង សុខ ជាអ្នកស្រុកត្រាំកក់ ខេត្តតាកែវ នៅក្នុងសម័យ ប៉ុល ពត ក្រុមគ្រួសារលោកស្រីត្រូវគេជម្លៀសទៅខេត្តពោធិ៍សាត់ ដូច្នោះហើយបានជាលោកស្រីមានកំណើតនៅក្នុងខេត្តពោធិ៍សាត់ ។ ក្រោយសម័យប៉ុលពត ក្រុមគ្រួសារមករស់នៅក្នុងទីរួមខេត្តពោធិ៍សាត់ នៅម្ដុំផ្សារក្រោម ហើយចាប់ផ្ដើមមុខរបរជាអ្នកលក់ចាប់ហួយនៅទីនោះរហូត ។

លោកស្រីបានត្រូវទីពីរដែលរស់នៅប្រទេសបារាំង ធានាមករៀនបន្តនៅប្រទេសបារាំង និងបានរស់នៅមានសិទ្ធិធ្វើការក្នុងប្រទេសបារាំងចំនួន៥ឆ្នាំហើយ មុននឹងបានជួបគ្នាជាមួយលោក កេង វ៉ាន់សាក់ ។

លោក លី ភឿង អ្នកផ្សាយវិទ្យុជាភាសាខ្មែរក្នុងទីក្រុងលីយ៉ុង ប្រទេសបារាំង ដែលបានជួបផ្ទាល់ និងបានសម្ភាសន៍ជាមួយលោកស្រី ស៊ីវ៉ន បានគូសបញ្ជាក់ថា "លោកស្រី ស៊ីវ៉ន គឺជាជនជាតិខ្មែរ តែឪពុកលោកស្រីមានជាប់សាច់ឈាមចិន និងម្ដាយលោកស្រីជាជនជាតិខ្មែរសុទ្ធមិនមែនជាជនជាតិយួនដូចដែលគេបាននិយាយប្រឌិតនោះទេ" ។ បន្ថែមលើនេះ លោកទទួលស្គាល់ថា "អ្នកដែលព្យាយាមបង្កើតពាក្យប្រឌិតទាំងនោះ គឺគេច្រណែននឹងលោកស្រី ស៊ីវ៉ន ដែលជាអ្នកទទួលមរតករបស់លោកបណ្ឌិត កេង វ៉ាន់សាក់ ទៅថ្ងៃអនាគត ៕

# ក.ខ.គ ផុសកណ្ដាល ក្រុងខ្មែរឡុងបិច

**ក្រុងខ្មែរ : រ៉ានាថ**

•សូរស័ព្ទសម្លេងបានលាន់រំពងឡើងចេញពីបន្ទប់ធំល្មមមួយនៅក្នុងបណ្ណាល័យ Mark Twain តាមបណ្ដោយផ្លូវ Anaheim កណ្ដាលបេះដូងក្រុងខ្មែរ Long Beach ។ ដែលសម្លេងនោះបានកើតចេញពីក្រុមមនុស្សក្មេងចាស់ ប្រមាណជាង៦០នាក់ កំពុងតែអានថាតាមអ្នកគ្រូ-លោកគ្រូនូវគាត់ចង់ឱ្យកូនៗចេះអក្សរខ្មែរ ដើម្បីស្គាល់ជាតិខ្លួនឯងមានអំបូរមកពីណា ? ដើម្បីកុំឱ្យពួកគេភ្លេចទំនៀមទំលាប់ខ្មែរ ក្នុងន័យថា "វាជាជនជាតិខ្មែរ ត្រូវចេះភាសាខ្មែរ, និយាយភាសាខ្មែរ " ។ ដោយឪពុកម្ដាយពួកគេទាំងនោះ បានពញ្ញាក់អារម្មណ៍អ្នកកាសែតខ្មែរប៉ុស្តិ៍យើងឱ្យក្រឡេកមើលជាតិសាសន៍នៅអាស៊ីដូចគ្នា មិនថា ចិន



អ្នកគ្រូ ម៉ែន វីតា កំពុងបង្រៀនសិស្ស ( រូបថតខ្មែរប៉ុស្តិ៍ )

ពាក្យ ក.ខ.គ.ឃ.ង ។ កុមារាម្នាក់ឈ្មោះ Christopher Heng Him អាយុ៧ឆ្នាំ និយាយថា "ខ្ញុំចង់រៀនភាសាខ្មែរ ព្រោះចង់ឆ្លងឆ្លើយជាមួយឪពុកម្ដាយខ្ញុំនៅឯផ្ទះ!" ។Christopher និយាយខ្មែរស្ទាក់ស្ទើរលាយឡំភាសាអង់គ្លេសបាននិយាយប្រាប់ខ្មែរប៉ុស្តិ៍បន្តថា "ភាសាខ្មែរមួយនេះពិបាករៀនណាស់ តែខ្ញុំត្រូវតែខំប្រឹងប្រែងរៀន ព្រោះខ្ញុំស្រឡាញ់ឪពុកម្ដាយរបស់ខ្ញុំ... ម្ដាយខ្ញុំបានលើកទឹកចិត្តខ្ញុំឱ្យព្យាយាមរៀនអក្សរខ្មែរ ដែលគាត់និយាយប្រាប់ខ្ញុំថា "អក្សរខ្មែរដែលកូនកំពុងរៀននេះហើយជាតម្លៃតំណាងឱ្យជាតិសាសន៍ម្ដាយនោះ! " ។ ចំណែកកុមារីម្នាក់ទៀតឈ្មោះ Victoria Ben អាយុ៨ឆ្នាំ នាងបាននិយាយថា " ខ្ញុំមករៀនដើម្បីអនាគតទៅមុខចេះនិយាយខ្មែរ, អាចសរសេរភាសាខ្មែរ និងចង់ប្រាប់ដល់អ្នកផ្សេងៗថា ខ្ញុំអាមេរិកាំង មានឈាមជ័រជាខ្មែរ តាមរយៈការនិយាយភាសាកំណើតឪពុកម្ដាយខ្ញុំពីតួអក្សរ ក.ខ.គ.ខ.ង នោះឯង។ ក្មេងស្រីដ៏គួរឱ្យខ្ញាញ់ឈ្លាសវៃនិយាយភាសាខ្មែរបានច្បាស់បានឱ្យដឹងទៀតថា " ឪពុកខ្ញុំកំពុងបានជួយបំរើសមាគមខ្មែរយូរមករហើយ ដោយខ្ញុំគួរតែដើរតាមគន្លងរបស់ឪពុកខ្ញុំ ដែលគាត់ជាមនុស្សម្នាក់ចេះជួយឈឺឆ្អាលដល់បងប្អូនខ្មែរ ។ ដោយកុមារីនោះនិយាយថា " ខ្ញុំចេះខ្មែរច្បាស់ដោយការប្រើភាសាខ្មែរនៅឯផ្ទះជាមួយឪពុកម្ដាយខ្ញុំ... ឪពុកម្ដាយខ្ញុំមិនដែលនិយាយភាសាអង់គ្លេសដាក់ខ្ញុំទេ ព្រោះគាត់ចង់ឱ្យខ្ញុំចេះភាសាខ្មែរ ។ ហើយខ្ញុំក៏មិនរុញរានឹងការនិយាយស្ដីសន្ទនាជាមួយគាត់ដែរ ដោយខ្ញុំមិនព្រួយពីការខ្វល់ថា មិនចេះភាសាអង់គ្លេសនោះទេ ខ្ញុំកើតនៅទីនេះ សាលារដ្ឋនៅក្បែរផ្ទះរបស់ខ្ញុំជុំវិញខ្លួន ខ្ញុំជាជនបរទេសចម្រុះនោះ ដែលផ្ទុយទៅវិញទេ ដែលខ្ញុំបារម្ភមិនចេះអក្សរខ្មែរនិយាយខ្មែរនោះ ។

ឪពុកម្ដាយជាច្រើន ដែលនាំកូនទៅកាន់សាលាបង្រៀនភាសាខ្មែរសុទ្ធតែអះអាងថា ពួកយួន ថៃ លាវ ពួកគេបានអប់រំដល់សង្គមគេ កូនចៅគេ ឱ្យខិតខំរៀនសូត្រភាសាជាតិខ្លួន, ថែរក្សាតម្លៃវប្បធម៌ ប្រពៃណីជាតិ ដើម្បីរក្សា អត្តសញ្ញាណជាតិពួកគេនោះ ។

អ្នកសម្របសម្រួលឱ្យមានកម្មវិធីបង្រៀនភាសាខ្មែរពីសាលាក្រុង Long Beach លោក Bryan Ben និងលោក ណុប ច័ន្ទដារ៉ា បាននិយាយថា កម្មវិធីនេះឧបត្ថម្ភ និងគាំទ្រដោយសាលាក្រុង Long Beach ដើម្បីបំរើនូវសេចក្ដីត្រូវការរបស់បងប្អូនខ្មែរ ។

លោក Bryant Ben បន្តថា កម្លាំងឪពុកម្ដាយ និងកូនតូចៗមានលក្ខណៈចង់រៀន, ចង់ចេះ, ចង់ដឹងនូវភាសាមួយ, វប្បធម៌មួយ ដែលយើងយល់ថា មានសារៈសំខាន់ណាស់ ចៀសវាងការបាត់បង់ពូជសាសន៍របស់យើង ។

កម្មវិធីសិក្សាភាសាខ្មែរមួយនេះ បានបើកការរៀនសូត្រពាអាទិត្យមកហើយ ជារៀងរាល់ថ្ងៃសៅរ៍ ចាប់ពីម៉ោង៩:០០-១១:៣០ ព្រឹក ។

អ្នកគ្រូ ម៉ែន វីតា និយាយថា ការវិវឌ្ឍនៃការរៀនសូត្ររបស់ពួកគេពុំទាន់បានល្អប្រសើរនៅឡើយទេ ចំពោះក្មេងតូចៗ ព្រោះការគិតនៅខ្ចី អារម្មណ៍នៅបែក ប៉ុន្តែពួកគេនៅតែសង្វាតខិតខំណាស់ ។ចំណែកក្មេងធំៗ ឬយុវជនប្រុស-ស្រី ពួកគេសិក្សាបានល្អបំផុត ។ លោកគ្រូ ជ័យ សិទ្ធី ក៏បានឱ្យដឹងដែរថា វាជាចំណង់ចំណូលចិតរបស់ពួកគេ និងឪពុកម្ដាយរបស់ពួកគេដែលចង់រក្សានូវទំនៀមទំលាប់ជាតិសាសន៍ និងភាសារបស់ពួកគេ ។ ហើយពង្រីកនូវសមត្ថភាពភាសារបស់គេឱ្យបានកាន់តែខ្លាំងឡើង ពីព្រោះភាសាខ្មែរជាភាសាមួយដែលសំបូរទៅដោយសម្លេង ដែលអាចឱ្យធ្វើត្រាប់តាមភាសាដទៃទៀតបានយ៉ាងស្រួលនៅពេលបានរៀនភាសានេះហើយ ។

លោកគ្រូ ជ័យ សិទ្ធី បន្តថា កម្មវិធីនេះនឹង

( តទៅទំព័រទី១៩ )

# សៀវភៅមួយនិយាយពី ជីវិតខ្មែរ នៅឡុងបិច

**ឡុងប៊ិច : មាជ សុវណ្ណារ៉ា , ពិន សំខុន**

សៀវភៅមួយដែលដាក់ចំណងជើងក្នុងក្របមុខរបស់ខ្លួនថា "Cambodians in Long Beach" មានចំនួន១២៧ទំព័រ ដែលបានពិពណ៌នាផ្ដោតសំខាន់បំផុត គឺស្ថានភាពនៃជីវភាពខ្មែររស់នៅឡុងប៊ិច ក្រោយពីជីវិតរស់សារជាថ្មីពីរបប ប៉ុល ពត មក ពួកគេបានយកជីវិតរបស់ខ្លួនជាអតីតជនភៀសខ្លួនទៅប្រឡូកក្នុងឆាកនៃ



សៀវភៅប្រវត្តិសាស្ត្រខ្មែរឡុងប៊ិច (រូបថត ឯល ម៉ាន់ថា)

សង្ខេបជាភាសាអង់គ្លេស ភ្ជាប់ជាមួយរូបថតរាប់រយសន្លឹក ត្រូវបានសាស្ត្រាចារ្យពីររូបពីសាកលវិទ្យាល័យឡុងប៊ិច ស្រាវជ្រាវ និងចងក្រង ហើយត្រូវបានផ្សព្វផ្សាយជាសារធារណៈ និងមានការដាក់លក់ដូរផងដែរ តម្លៃ២៥ដុល្លារអាមេរិកក្នុងមួយក្បាល ។

សាស្ត្រាចារ្យដែលមានឈ្មោះ Susan Needham និង Karen Quintitiani បានពិពណ៌នាក្នុងសៀវភៅនោះ និយាយទៅដល់តម្លៃប្រវត្តិសាស្ត្រខ្មែរត្រួសៗនាសម័យអង្គរ និងអ្វីដែលសង្គមអាមេរិក មិនថា ក្លាយខ្លួនជាជីវិតអ្នកនយោបាយ អ្នកសេដ្ឋកិច្ច ជំនួញ អ្នកស្រាវជ្រាវប្រវត្តិសាស្ត្រ ឬអ្នកវិទ្យាសាស្ត្រ អ្នកសិល្បៈ និងអ្នករដ្ឋការស៊ីវិលជាដើមនោះ ។

នៅក្នុងសៀវភៅនោះបានចែកសណ្ឋានខ្មែរជាជនភៀសខ្លួនជាពីដំណាក់កាល ដែលដំណាក់កាលទី១ ជាអ្នកភៀសសឹកសង្គ្រាមក្នុងរបបលន់ នល់ "សម័យសាធារណរដ្ឋខ្មែរ" ដែលខ្មែរក្រហមបានផ្ដួលរំលំក្នុងឆ្នាំ១៩៧៥ មករស់នៅ

( តទៅទំព័រទី១៩ )

AUTOGRAPH
Audio Visual Vehicle Design Specialist
Wimean Hing
Cell: (215) 892-4122

ហាងកូនខ្មែរសំរាប់ដាក់ "អូតូរ៉ៃឡាឌីយ៉ូ " ដាក់ " ការពារកុំឱ្យចោរលួចដាក់ម៉ាស៊ីនសំរាប់ជួយរកផ្លូវ នឹងគ្រឿងអេឡិចត្រូនិចច្រើនទៀត"

-Audio
-Video and Navigation Systems
-Wheels and Tires
-Satellite Radio
-GPS Tracking
-Alarm and Remote Start
-Custom Fiberglass Enclosures and Accessories



"អតូក្រាហ្វ" ជាហាងរបស់កូនខ្មែរ ដែលមានបទពិសោធល្អខ្ពស់ ក្នុងការដាក់សម្ភារៈបន្ថែម ឬ អេឡិចត្រូនិចបំរើលោក-អ្នកមិនឱ្យខុសចិត្តឡើយ ។
បើចង់បានព័ត៌មានបន្ថែម សូមរកវិមាន ហ៊ីង

7114 State Road
Philadelphia, Pa 19135
Phone : (215) 333-3723
Fax : (215) 333-3715
vimeanhing@autogrpahcar.com, www.autographcar.com

# គ្មានការចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ?

**ហុងកុង : ខ្មៅ មុំរហៃ**

●នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨ កងទ័ពវៀតណាមបានចូលទៅរំលំរបបកម្ពុជាប្រជាធិបតេយ្យគឺរបបខ្មែរក្រហមដែលជារបបកុម្មុយនីស្ត ។ ក្រោយការរំលំនេះមកនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ របបកុម្មុយនីស្តមួយទៀតដែលមានឈ្មោះថាសាធារណរដ្ឋប្រជាមានិតកម្ពុជា ក៏ត្រូវបានបង្កើតឡើង ។

តាំងពីការដួលរលំរបស់ខ្លួនមករបបខ្មែរក្រហមត្រូវបានទទួលការចោទប្រកាន់ជាបន្តបន្ទាប់ថាជា "របបប្រល័យពូជសាសន៍ "។ នៅខែសីហា ឆ្នាំ១៩៧៩ ប៉ុល ពត និង អៀង សារី ដែលជាមេដឹកនាំកំពូលទី១ និងទី២នៃរបបខ្មែរក្រហម ត្រូវបានតុលាការបដិវត្តប្រជាជនកម្ពុជាដែលបង្កើតឡើង ដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា កាត់ទោសដោយកំបាំងមុខពី"បទប្រល័យពូជសាសន៍ " ហើយដាក់ទោសប្រហារជីវិតក្នុងក្របខ័ណ្ឌ និងឈរលើមូលដ្ឋាន "អនុសញ្ញាស្តីអំពីការបង្ការ និងផ្តន្ទាទោសចំពោះ បទឧក្រិដ្ឋប្រល័យពូជសាសន៍" ដែលចូលជាធរមាននៅឆ្នាំ១៩៥១ ហើយប្រទេសកម្ពុជាជាភាគីមួយ ។ សាធារណរដ្ឋប្រជាមានិតកម្ពុជាដដែល ក៏បានប្រែក្លាយគុក ទួលស្លែងរបស់របបខ្មែរក្រហមនៅភ្នំពេញជា "សារមន្ទីរប្រល័យពូជសាសន៍" ។

តាំងពីពេលនោះមកក៏មានការសិក្សាគម្រោងការកម្មវិធី និងមជ្ឈមណ្ឌលនានា នៅក្នុងពិភពលោកធ្វើការស្រាវជ្រាវពិនិត្យ ពិចារណាពិភាក្សាអំពីការប្រល័យពូជសាសន៍ របស់របបខ្មែរក្រហម។ នៅឆ្នាំ១៩៩៤ សភាជាន់ទាបរបស់សហរដ្ឋអាមេរិកបានអនុម័តច្បាប់មួយដែលហៅថា Cambodian Genocide Justice Act ដើម្បីជួយដល់ការខំប្រឹងប្រែងក្នុងការចាប់យកសមាជិកខ្មែរក្រហមមកផ្តន្ទាទោស ។

ការខំប្រឹងប្រែងជាបន្តបន្ទាប់ជាង១០ឆ្នាំ ដើម្បីរកយុត្តិធម៌នេះ បាននាំមកនូវការបង្កើតតុលាការមួយដែលមានឈ្មោះជាផ្លូវការថា "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ហើយដែលហៅជាសាមញ្ញថា "តុលាការខ្មែរក្រហម" នៅឆ្នាំ២០០៦ ។ នៅឆ្នាំ២០០៧ តុលាការនេះ ក៏បានចាប់ឃុំឃាំងមេដឹកនាំខ្មែរក្រហម៥រូបគឺ : (១) កាំង ហ្គេចអ៊ាវ ហៅ ឌុច (២) នួន ជា (៣) ខៀវ សំផន ហៅ ហែម
(៤) អៀង សារី ហៅ វ៉ាន់ និង (៥) អៀង ធីរិទ្ធ ហៅ ភា (ភរិយា អៀង សារី) ។

តុលាការខ្មែរក្រហមបានចោទប្រកាន់មេដឹកនាំខ្មែរក្រហមទាំង៥រូបនេះ ពីបទល្មើសទាំងឡាយដូចតទៅនេះ :

(១) កាំង ហ្គេចអ៊ាវ ហៅ ឌុច : "ការបានគ្រប់គ្រងមជ្ឈមណ្ឌលសន្តិសុខ ស-២១ (គុកទួលស្លែង) នៅចន្លោះឆ្នាំ១៩៧៥ និង ១៩៧៩ ជាកន្លែងដែលការរំលោភឥតគណនា ត្រូវបានប្រព្រឹត្តនៅក្រោមអំណាចរបស់ខ្លួន ប្រឆាំងនឹងប្រជាពលរដ្ឋស៊ីវិល (ការឃុំឃាំងដោយបំពាន ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ឯទៀត ការសម្លាប់រង្គាល ។ល។) ដែលស្ថិតក្នុងក្របខ័ណ្ឌនៃការអនុវត្តនយោបាយជាលក្ខណៈប្រព័ន្ធ ឬមានលក្ខណៈទូទៅដែលបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ។ (ដីការសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ របស់សហចៅក្រមស៊ើបអង្កេត) ។

(២) នួន ជា : "បទល្មើសប្រឆាំងនឹងមនុស្សជាតិ (មនុស្សឃាត ការធ្វើទារុណកម្ម ការដាក់ឃុំឃាំង ការធ្វើទុក្ខបុកម្នេញ ការសម្លាប់ផុតពូជ ការនិរទេសការជន្លៀសប្រជាពលរដ្ឋដោយបង្ខំ ការដាក់ជាទាសករ និងអំពើអមនុស្សឯទៀត ) និងបទឧក្រិដ្ឋសង្គ្រាម ដែលផ្អែកលើការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី


អៀង សារី


ខៀវ សំផន

១២ ខែសីហា ឆ្នាំ១៩៤៩ (ការសម្លាប់ដោយចេតនា ការធ្វើទារុណកម្ម ការប្រព្រឹត្តអមនុស្សធម៌ ការបង្កព្យសនកម្មធ្ងន់ធ្ងរ ឬការធ្វើឱ្យមានការឈឺចាប់ខ្លាំងដោយចេតនាដល់រាងកាយ និងសុខភាព ការដកហូតដោយការបង្ខាំងជនស៊ីវិលដោយខុសច្បាប់)" ។ (ដីការសម្រេចឃុំឃាំងខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ របស់សហចៅក្រមស៊ើបអង្កេត ) ។

(៣) ខៀវ សំផន ហៅ ហែម : "បទល្មើសប្រឆាំងមនុស្សធម៌ (មនុស្សឃាតការដាក់ឃុំឃាំង ការធ្វើទុក្ខបុកម្នេញ ការសំលាប់បំផុតពូជ និងអំពើអមនុស្សធម៌ឯទៀត) និងបទឧក្រិដ្ឋសង្គ្រាមដែលផ្អែកលើការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ សីហា ឆ្នាំ១៩៤៩ (ការសម្លាប់ដោយចេតនា ការប្រព្រឹត្តអមនុស្សធម៌ ការបង្កព្យសនកម្មធ្ងន់ធ្ងរ ឬការធ្វើឱ្យមានការឈឺចាប់ខ្លាំងដោយចេតនាដល់រាងកាយ និងសុខភាព ការដកហូតដោយចេតនាពីអ្នកទោសសង្គ្រាម និងជនស៊ីវិលនូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ការនិរទេស ឬជន្លៀស ឬការបង្ខាំងជនស៊ីវិលដោយខុសច្បាប់)"។ (ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់សហចៅក្រមស៊ើបអង្កត) ។

(៤) អេង សារី ហៅ វ៉ាន់ : "បទល្មើសប្រឆាំងនឹងមនុស្សធម៌ (មនុស្សឃាតការដាក់ឃុំឃាំង ការធ្វើទុក្ខបុកម្នេញ ការសំលាប់បំផុតពូជ និងអំពើអមនុស្សធម៌ឯទៀត) និងបទឧក្រិដ្ឋសង្គ្រាមដែលផ្អែកលើការរំលោភបំពានធ្ងន់ធ្ងរអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែ សីហា

( តទៅទំព័រទី២២ )

# សម រង្ស៊ី : សុខចិត្តចូលគុកជាថ្នូរដោះលែងអ្នកកាសែត

**ភ្នំពេញ : ចាន់ កុសល**

●●●ការចាប់ខ្លួនលោក ដាំ សិទ្ធិ និពន្ធនាយកកាសែតមនសិការបានធ្វើឱ្យមានប្រតិកម្មពីបណ្តាអង្គការសមាគមអ្នកកាសែតជាតិ-អន្តរជាតិ និងតំណាងរាស្ត្រនៃគណបក្សប្រឆាំង ដោយបានធ្វើការស្តីបន្ទោសចំពោះតុលាការក្រុង-


សម រង្ស៊ី

ភ្នំពេញយ៉ាងចាស់ដៃ ។

ចំណែកលោក សម រង្ស៊ី ប្រធានគណបក្សសម រង្ស៊ី បានបញ្ជាក់ ថា លោក ដាំ សិទ្ធិ គ្មានកំហុសនោះទេ ពីព្រោះលោកគ្រាន់តែដកស្រង់សំដីរបស់លោកមកចុះផ្សាយប៉ុណ្ណោះ ។ លោកសុខចិត្តឱ្យគេចាប់លោកដាក់គុកដូចនៅប្រទេសភូមា គឺឱ្យតែគេធ្វើការដោះលែងលោក ដាំ សិទ្ធិ ឱ្យមានសេរីភាពឡើងវិញ ។

លោក សម រង្ស៊ី បានថ្លែងក្នុងសន្និសីទព័ត៌មាននៅទីស្នាក់ការកណ្តាលគណបក្ស សម រង្ស៊ី ក្រុងភ្នំពេញថា ការចាប់ខ្លួនលោក ដាំ សិទ្ធិ គឺជារឿងនយោបាយសុទ្ធសាធ ពីព្រោះប្រជាជនកម្ពុជាកំពុងតែភ័យពីរឿងដីធ្លីបញ្ហាទំនិញឡើង ថ្លៃគ្រប់មុខមិនអាចដោះស្រាយចេញ ។ ដូច្នេះការចាប់ខ្លួននិពន្ធនាយកកាសែតមនសិការនេះ គឺចង់បង្វែរអារម្មណ៍របស់ប្រជាពលរដ្ឋឱ្យឈប់គិតពីរឿងទាំងអស់នោះ ។

លោក សម រង្ស៊ី ក៏បានធ្វើការរិះគន់ចំពោះគណបក្សប្រជាជនកម្ពុជា ដែលតែងតែធ្វើការយាយីដល់មន្ត្រីគណបក្សលោក តាមរយៈការ


ហោ ណាំហុង

ទិញទឹកចិត្តផ្តល់តួនាទី និងអំណាចបុណ្យសក្តិឱ្យចាកចេញពីគណបក្សជាបន្តបន្ទាប់ទៅចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា ។ លោកបន្តថា ទង្វើបែបនេះ ប្រជាពលរដ្ឋដឹងអស់ហើយនៅថ្ងៃទី២៧ កក្កដា ពលរដ្ឋលែងបោះឆ្នោតឱ្យហើយបែរជាមកគាំទ្រគណបក្ស សម រង្ស៊ី វិញ ។

ទាក់ទិនទៅនឹងការចោទប្រកាន់នេះ មន្ត្រីគណបក្សប្រជាជនកម្ពុជាមួយរូប ក៏បានច្រានចោលទាំងស្រុងដោយលើកហេតុផលថា កន្លងមករដ្ឋាភិបាលបានធ្វើការកែសំរួលដល់សេរីភាពសារព័ត៌មានឱ្យកាន់តែប្រសើរឡើង គឺលប់ចោលច្បាប់ព្រហ្មទណ្ឌចេញពីបទបរិហារកេរ្តិ៍ ។


លោក ដាំ សិទ្ធិ

មន្ត្រីរូបនោះ បានបញ្ជាក់ ថា រឿងលោក ដាំ សិទ្ធិ និង លោក ហោ ណាំហុង គឺជារឿង បុគ្គលជាពិសេសនោះ លោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មានបានធ្វើលិខិតទៅកាន់តុលាការក្រុងភ្នំពេញ ដោយសុំឱ្យដោះលែងលោក ដាំ សិទ្ធិ ឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ។

លោកនិពន្ធនាយកកាសែតមនសិការត្រូវបានចាប់ខ្លួន នៅថ្ងៃទី០៨ មេសា ក្នុងអត្ថបទដកស្រង់សំដីរបស់លោក សម រង្ស៊ី និយាយកាលពីថ្ងៃទី ១៧ មេសា នៅឯវាល ពិឃាតជើងឯក ជាយក្រុងភ្នំពេញ ក្នុងពិធីគោរពវិញ្ញាណក្ខន្ធជនរងគ្រោះក្នុងរបប ប៉ុល ពត ។ ក្នុងសន្ទរកថា របស់លោក សម រង្ស៊ី បានផ្សាភ្ជាប់អតីតមេគុកបឹងត្របែក សម័យខ្មែរក្រហម ដែលមានតួនាទីដឹកនាំក្នុងរដ្ឋាភិបាលបច្ចុប្បន្ន ប៉ុន្តែមិនបានបញ្ជាក់ឈ្មោះលោក ហោ ណាំហុង នោះទេ ។

ដោយស៊ីលាសរអៀសខ្លួននោះ លោក ហោ ណាំហុង ក៏ឱ្យមេធាវីរបស់ខ្លួន គឺលោក កា សាវុធ ធ្វើជាដើមបណ្តឹងចំពោះលោក សម


ពុង ឈីវកេក

រង្ស៊ី និងលោក ដាំ សិទ្ធិ ពីបទបរិហារកេរ្តិ៍ ។

បន្ទាប់ពីតុលាការក្រុងភ្នំពេញ ចាប់ខ្លួននិពន្ធនាយកកាសែតមនសិការមិនស្របតាមផ្លូវច្បាប់នោះមក ក៏បណ្តាលឱ្យមានប្រតិកម្មពីក្លឹបអ្នកកាសែតកម្ពុជា សមាគមអ្នកកាសែតសហព័ន្ធ

( តទៅទំព័រទី១៨ )



# ហោរាសាស្ត្រប្រចាំខែ មិថុនា ថ្ងៃទី ២១_០៤



**ឆ្នាំជូត : (ពពួកទេវតាប្រុស ធាតុទឹក)**

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ បើជាបុគ្គលិកកម្មករដែលបំរើការងារនៅតាមក្រុមហ៊ុន ឬរោងចក្រនានា ចូរចេះដាក់ខ្លួនដាក់កាយ និងចេះធ្វើទំនាក់ទំនងល្អជាមួយនឹងចៅហ្វាយនាយ ឬថៅកែ ព្រមទាំងអ្នករួមការងារជាមួយ ទើបកិច្ចការងារអាចដំណើរការបានស្រួល ៕



**ឆ្នាំឆ្លូវ : ( ពពួកមនុស្សប្រុស ធាតុដី )**

រាសីលោកអ្នកល្អធម្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះរាល់ឧបទ្រពចង្រៃ និងរាល់ឧបសគ្គ ត្រូវបានសាបរលាបជាបណ្តើរៗ ដូច្នេះលោកអ្នកអាចប្រកបកិច្ចការងាររកស៊ីបានពេញដៃពេញជើង ។ ចំពោះអ្នកជំនួញជួញដូរ បើមានប្រគល់ ឬ ទទួលនូវមុខទំនិញសព្វសារពើ ចូរចេះពិនិត្យគុណភាព និងរាប់ចំនួនឱ្យបានច្បាស់លាស់ ទើបពុំមានរឿងឆបោកកើតឡើង ៕



**ឆ្នាំខាល : ( ពពួកយក្សស្រី ធាតុឈើ )**

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបរឿង រកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ បើមានរឿងឈ្លោះប្រកែកកើតឡើង ចូរចេះអត់ធ្មត់ និងរម្ងាប់ចិត្តឱ្យបានត្រជាក់ ដាច់ខាតមិនត្រូវតបតទាំងកំហឹងទល់នឹងកំហល់ឡើយ ទើបរឿងតូចមិនអាចក្លាយជារឿងធំបាន ។ ក្នុងរយៈពេលនេះ បើមានដំណើរទៅណាមកណា ចូរប្រយ័ត្នប្រយែងក្រែងជួបគ្រោះថ្នាក់ចរាចរ ៕



**ឆ្នាំថោះ : ( ពពួកមនុស្សស្រី ធាតុឈើ )**

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ក្នុងរយៈពេលនេះ អ្វីដែលលោកអ្នកត្រូវយកចិត្តទុកដាក់នោះ គឺនៅតែមានមនុស្សខិលខូចខ្លះប៉ងបំផ្លិចបំផ្លាញរាល់កិច្ចការងារ ដូច្នេះមុននឹងធ្វើអ្វីមួយ ឬមុននឹងធ្វើដំណើរទៅណាមកណា ចូរមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះមានការយល់ចិត្តគ្នាល្អ គ្មានបញ្ហាអ្វីកើតឡើងធំដុំទេ ៕



**ឆ្នាំរោង : (ពពួកទេវតាប្រុស ធាតុមាស)**

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបរឿងរកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ លោកអ្នកអាចផ្អាករាល់កិច្ចការងារសំខាន់ៗមួយរយៈពេលសិន ព្រោះបើហ៊ានតែមានចិត្តមានះរឹងរូស គឺពិតជាស៊យធំអាចបង់ខាតទ្រព្យជាក់ជាមិនខាន ។ ចំពោះស្ត្រីភេទក្នុងរយៈពេលនេះ មិនត្រូវដើរផ្លូវឆ្ងាយដាច់សង្វែងតែម្នាក់ឯងឡើយប្រយ័ត្នបានជួបគ្រោះភ័យ ៕



**ឆ្នាំម្សាញ់ : (ពពួកមនុស្សប្រុស ធាតុភ្លើង)**

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ ថ្វីត្បិតតែមានផលចំណូលហូរចូលបានច្រើនក្រាស់ក្រែលគួរសមក្តី តែពុំមានសល់អ្វីជាដុំកំភួនឡើយ ព្រោះចាយវាយខ្ជះខ្ជាយខ្លាំងពេក ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះ បើស្រលាញ់កុំទៅញីក បើរពូកកុំទៅញយ ទើបចំណងស្នេហាអាចគង់វង្សបានយូរអង្វែង ៕



**ឆ្នាំមមី : (ពពួកទេវតាស្រី ធាតុភ្លើង)**

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹងបញ្ហាលំបាកៗច្រើន ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ចូរកុំមានការធ្វេសប្រហែសឱ្យសោះ ជាពិសេសចំពោះអាជីវករអ្នករកស៊ីប្តូរប្រាក់ ឬលក់គ្រឿងអលង្ការមានតម្លៃផ្សេងៗ ត្រូវប្រយ័ត្នប្រយែងមានជនខិលខូចលួចបន្លំ ឬឆក់ប្លន់ ៕



**ឆ្នាំមមែ : (ពពួកទេវតាស្រី ធាតុមាស)**

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ក៏អាចទទួលបានផលសម្រេចសមតាមបំណងប្រាថ្នាទាំងអស់ ។ បើជាអាជីវករអ្នករកស៊ីជួញដូរនឹងមានទំនិញលក់ចេញទិញចូលឥតទំនេរដៃព្រមទាំងមានទ្រព្យ ហូរចូលជាហូរហែទៀតផង ៕



**ឆ្នាំវក : (ពពួកយក្សប្រុស ធាតុដែក)**

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយត្រូវមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច ជាពិសេសមុននឹងចុះហត្ថលេខា ឬផ្តិតស្នាមមេដៃផ្សេងៗ ចូរចេះពិនិត្យពិច័យឱ្យបានល្អិតល្អន់ ព្រោះកាលបើមានការភ្លាំងភ្លាត់តែបន្តិចអាចបង់ខាតផលប្រយោជន៍ច្រើន ៕



**ឆ្នាំរកា : (ពពួកយក្សប្រុស ធាតុដែក)**

រាសីលោកអ្នកខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ ឱកាសល្អៗបានមកដល់ហើយ ដូច្នេះលោកអ្នកត្រូវតែរវៀសរវៃញាប់ជើងញាប់ដៃបន្តិច ព្រោះពេលវេលាជាមាសប្រាក់ធ្វើច្រើនបានច្រើន ។ ចំពោះគូស្នេហ៍ក្នុងរយៈខែនេះ មានភាពស្និទ្ធស្នាលដូចប្រក្រតី ៕



**ឆ្នាំច : ( ពពួកយក្សស្រី ធាតុដី )**

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះ លោកអ្នកមានអារម្មណ៍ភ្លឺថ្លា គំនិតប្រាជ្ញាឈ្លាសវៃ ទោះប្រកបកិច្ចការងារអ្វីៗក៏ដោយ ក៏អាចទទួលបានផលសម្រេចសមតាមបំណងប្រាថ្នាទាំងអស់ ។ ចំពោះស្វាមីភរិយាវិញ មានភាពល្អូកល្អឺនគ្នាណាស់ ហើយពិសេសនោះស្រលាញ់គ្នាលើសមុនទៅទៀត ៕



**ឆ្នាំកុរ : (ពពួកមនុស្សស្រី ធាតុទឹក)**

រាសីលោកអ្នកខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ក៏មានអ្នកជួយជ្រោមជ្រែងយ៉ាងពេញទំហឹងដែរ ។ ចំពោះស្ត្រីភេទនៅលីវ និងត្រូវបានកម្លោះៗ ចោមរោមស្រលាញ់ រហូតអាចឈានដល់ការស្តីដណ្តឹងយកធ្វើជាគូអនាគតទៀតផង ៕

## ចាប់ខ្លួននិពន្ធនាយកកាសែត...

ស្ថាក់ការនៅក្រុងហុងកុងបានធ្វើការស្តីបន្ទោសការចាប់ខ្លួនលោក ដាំ សិទ្ធិ នេះថា វាប៉ះពាល់ដល់សិទ្ធិនៃការបញ្ចេញមតិរបស់អ្នកសារព័ត៌មានយ៉ាងធ្ងន់ធ្ងរ ខុសនឹងរដ្ឋធម្មនុញ្ញបានកំណត់ ។

គួរបញ្ជាក់ថា សកម្មជនសិទ្ធិមនុស្ស និងអ្នកសារព័ត៌មាន ដែលហ៊ានរិះគន់មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលត្រូវបានតុលាការចាប់ខ្លួនជាបន្តបន្ទាប់ករណីលោក កឹម សុខា អតីតប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សលោក រ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា លោក ជាម ចន្ទី តំណាងរាស្ត្រគណបក្ស សម រង្ស៊ី លោក ម៉ម សូណង់ដូម្ចាស់ស្ថានីយ វិទ្យុសំបុកឃ្មុំលោក ដាំ សិទ្ធិ និពន្ធនាយកកាសែតមនសិការ ៕

***រាយការណ៍បន្ថែមដោយ : មាជ សុវណ្ណារ៉ា***

## ៤ចំណុចធ្វើត្រគាកស្អាត



**១_អាហារ :** បើមានអារម្មណ៍ធុញថប់ សូមកុំប្រើវិធីបំបាត់អារម្មណ៍ធុញថប់នោះដោយការញ៉ាំ ។ ត្រូវប្តូរចំណីអាហារទទួលទានដូចជាដំឡូងបារាំងចៀន មកជាទៅហាងកែសម្ផស្ស ដើម្បីធ្វើសក់ម៉ូដថ្មី ឬក៏ធ្វើអ្វីៗផ្សេងទៀត សម្រាប់សម្រស់របស់យើងវិញ ទើបជាការល្អជាង ។

●សូមកុំវីរវល់អាហារពួកប្រ្ហូម៉ា និងសាន់វិច ដែលអាហារប្រភេទនេះ ធ្វើឱ្យធាត់ ។ ត្រូវប្តូរមកជាញ៉ាំបន្លែគ្រប់មុខមួយចានវិញ វានឹងជួយកាត់បន្ថយបានដល់ទៅ១០០កាឡូរី និងជាតិខ្លាញ់ ១៣.៥ក្រាមទៀតផង ។

**២_អាហារជំនួយឱ្យត្រគាកស្អាត :** ផឹកទឹកក្រូចច្របាច់ស្រស់ឱ្យបានច្រើនជាមួយនឹងអាហារពេលព្រឹក ។ វីតាមីន C ដែលនៅក្នុងទឹកក្រូចស្រស់នោះ វានឹងធ្វើឱ្យស្បែករបស់អ្នកស្អាតស្រស់ភ្លឺថ្លា ហើយថែមទាំងជួយឱ្យត្រគាករបស់អ្នកស្អាតផូរផង់គួរឱ្យចង់ប៉ះទៀតផង ។

●ទទួលទានត្រី ធូណា ឱ្យបានញឹកញាប់ ព្រោះវាមានប្រូតេអ៊ីនដែលអាចជួយទប់ស្កាត់កុំឱ្យអ្នកចង់ ទទួលទានចំណី នេះពេលបាយ ដែលចំណីទាំងនោះ អាចធ្វើឱ្យអ្នកធាត់ជាងមុន ។ ត្រូវជ្រើសរើសបរិភោគត្រីធូណា ទឹកប្រៃយ៉ាងណាៗ ក៏វាមិនធ្វើឱ្យធាត់ដែរ ។

**៣_ហាត់ប្រាណ :** ផ្ទះរបស់យើងក៏អាចហាត់ ប្រាណបានដែរ បើទោះជាពុំមានឧបករណ៍ហាត់ប្រាណគ្រប់គ្រាន់ក៏ដោយ ។ យើងអាចហាត់ប្រាណ ដោយគ្រាន់តែឡើងជណ្តើរចុះឡើងៗ ឱ្យបានប្រ-ហែលជា១០នាទីក្នុងមួយថ្ងៃ វានឹងធ្វើឱ្យយើងមាន ត្រគាកស្អាត ព្រមទាំងធ្វើឱ្យជើងស្រលូនតឹងណែនដូចបវរកញ្ញាបាន ៕

## ស្ថានភាពអន្លង់វែង...

ជាព្រៃទិញបានបណ្ដើរៗ ដូច្នេះត្រូវការបន្លែ ត្រូវការត្រី ពូកសាច់ ម្ហូបមិនបានទេ ពេទ្យហាមមិនឱ្យហូបសាច់ ហើយបើទទួលទានខ្លួនឯងទៅក៏មិនបានស្រួលខ្លួនដែរ ។

**សំណួរ :** បើពេលឈឺថ្កាត់អ្វីម្ដងៗ តើអាចហៅពេទ្យបានឬទេ ?

**ប៉ុល ពត :** ឥឡូវមិនទាន់មានទេ ! ពីមុនគេព្យាបាល ខ្ញុំចេះតែកត់វិធីប្រើយ៉ាងម៉េចៗ ខ្ញុំមានបញ្ជីថ្នាំ ប្រើអស់ទៅខ្ញុំសុំការអនុញ្ញាតឱ្យទិញ ដូច្នេះថ្នាំមិនគ្រប់គ្រាន់ណាស់ទេ តែវាជួយ សុខភាពបានដែរ ។

**សំណួរ :** ក្នុងស្ថានភាព ដែលគេឃាត់ខ្លួន លោកចំពេល ដែលលោកមានជំងឺ ដូច្នេះ តើវាស្របទៅនឹងការដែលលោកចង់បានដែរ ឬទេ ?

**សំណួរ :** បើមិនបាន តើត្រូវជួយទៅទឹកដល់ពេលនោះបាន ឬទេ?

**ប៉ុល ពត :** ទី១ ខ្ញុំគ្មានលទ្ធភាពអ្វីទៅស្រាវជ្រាវបានពេលឥឡូវ ប៉ុន្តែនឹកទៅពេលមុននោះទៅទៀត ខ្ញុំឥតមានទទួលខុសត្រូវការងារអ្វីជាក់ស្ដែង ខ្ញុំទទួលតែការងាររៀនសូត្រកម្មាភិបាលតែប៉ុណ្ណឹងទេ ឥតទៅទទួលការងារជាក់ស្ដែងត្រូវទៅធ្វើនេះ ធ្វើនោះអ្វីទេ អ្នកទទួលខុសត្រូវ គឺកម្មាភិបាលគេរួមមានអ្នកខាងយោធាមានអ្នកខាងសេដ្ឋកិច្ច ខ្ញុំតែផ្នែកខាងនយោបាយទេ ។

**សំណួរ :** ពេលវេលាវិលទៅឆ្ងាយសង្គមផ្លាស់ប្ដូរ ប្រជាពលរដ្ឋទាំងអស់ ត្រូវការសេចក្ដីសុខ តើលោកមើលឃើញនយោបាយកម្ពុជាបច្ចុប្បន្នយ៉ាងណា ?

**ប៉ុល ពត :** ខ្ញុំរួមចំណែកតស៊ូស៊ីៗ គ្មានបំណងផ្ទាល់ខ្លួនស៊ីៗទាំងអស់មានតែធ្វើម៉េចឱ្យប្រទេសតូចនេះ ទី១ កុំឱ្យទៅជាកម្ពុជាក្រោម ទី២ ខ្ញុំស្គាល់យួនច្បាស់ណាស់ មិនមែនស្គាល់យួនប្រជាជនធម្មតានោះទេ ប្រជាជនធម្មតាជាប្រជាជនវៀតណាមភាគច្រើនគេល្អ ប៉ុន្តែអ្នកដឹកនាំយួន ខ្ញុំស្គាល់ណាស់ ខ្ញុំរាប់បានទាំងអស់ វាអាក្រក់ណាស់ ។ វាមានយុទ្ធសាស្ត្រយកកម្ពុជា វាស្អប់ខ្ញុំណាស់ ពីព្រោះខ្ញុំទប់ទល់នឹងវា! អាឡេយន់ -អាង្វៀងជិញ-អាវ៉ាន់ យ៉ាប - អាវ៉ាន់តាងយុង -អាហ្វាំងយុង -សុទ្ធតែកាចៗណាស់ ។ ពួកនេះ ហើយខ្ញុំស្គាល់ ធ្វើការជិតស្និតណាស់ ។ នៅមុខយើង វានិយាយអញ្ចេះ ក្រោយខ្នងយើងវានិយាយអញ្ចុះ ។ ឧបមាថា ព្រំដែនគោរពព្រំដែនគ្នា វាថាគោរព ហើយមានគណៈទាក់ទងថ្នាក់រដ្ឋបាល ថ្នាក់ខេត្ត ស្រុក ខាងវាក៏មាន ហើយទៅប្រជុំវាថា យល់ស្រប ប៉ុន្តែការពិតវាវ៉ៃតែយើង ។ ដូច្នេះទាំងអស់គ្នាទ្រាំមិន

( តទៅទំព័រទី២៤ )

## ប្រតិបត្តិការណ៍បញ្ឈប់...

ស្ត្រីរកស៊ីផ្លូវភេទមានផ្ទុកមេរោគ HIV ប៉ុន្តែចំនួននោះតិចជាងឆ្នាំ១៩៩៦ ដែលមានចំនួនរហូតដល់ទៅ៣៩ភាគរយក្នុងចំណោមស្រីពេស្យាដែលបានធ្វើតេស្តរកមេរោគនេះ ។

ដើម្បីជួយឱ្យស្ត្រីរកស៊ីផ្លូវភេទបានវិលទៅកាន់ជីវិតធម្មតាវិញ អ្នកស្រី សុម៉ាលី សង្ឃឹមថា នឹងពង្រីងបន្ថែមនូវកន្លែងរបស់នាង ដែលមានទីលំនៅក្នុងទីជនបទក្រៅទីក្រុងភ្នំពេញ ដែលនៅទីនោះ អតីតស្ត្រីលក់ខ្លួនទាំងឡាយចូលរួមក្នុងសាលារៀន ហើយសិក្សានូវជំនាញផ្សេងៗ ដូចជា ដេរប៉ាក់ ត្បាញ ជាដើម ។

ខាងក្រោមនេះ គឺជាអត្រាផ្លូវភេទ ទូទាំងពិភពលោក :

### ឧស្សាហកម្មផ្លូវភេទទូទាំងពិភពលោក :

នៅជុំវិញពិភពលោកកូនក្មេងយុវតី ច្រើនជាង ១លាននាក់ត្រូវបានគេជួញដូរ នៅក្នុងឧស្សាហកម្មផ្លូវភេទជារៀងរាល់ឆ្នាំ ។ នេះបើយោងតាមក្រសួងការបរទេសរបស់អាមេរិក (U.S Department) ។ គេជឿថា ប្រទេសកម្ពុជា គឺជាកន្លែងគាត់ និងជាទិសដៅសំខាន់ក្នុងការជួញដូរនេះ ។

ការជួញដូរ កេងប្រវ័ញ្ចផ្លូវភេទ ក៏បានកើតឡើងផងដែរ នៅតាមព្រំប្រទល់របស់កម្ពុជាពីតំបន់ចូលមកទីក្រុងភ្នំពេញ ។ នេះបើតាមរបាយការណ៍ដែលសរសេរដោយក្រសួងការបរទេសអាមេរិក ។

អង្គការអន្តរជាតិនានាដូចជា UNICEF/ ECPAT និង Save Children (អង្គការជួយសង្គ្រោះកុមារ) ជាដើមបានអះអាងថា ស្ត្រី និងកុមារដែលចូលរួមក្នុងអាជីវកម្មផ្លូវភេទនេះ មានចំនួនមិនតិចជាង ៥០.០០០ទៅ១០០.០០០នាក់នោះទេ ។ គេបានប៉ាន់ស្មានថា ៣០ភាគរយ នៃអ្នកបម្រើផ្លូវភេទក្នុងទីក្រុងភ្នំពេញ មានអាយុក្រោម១៨ឆ្នាំ ។ តួលេខពិតប្រាកដប្រហែលជាអាចមានតិចជាងនេះ ។ នេះបើតាមរបាយការណ៍មួយចំនួនបានឱ្យដឹងរបស់សកម្មភាពប្រឆាំងនឹងអាជីវកម្មជួញដូរផ្លូវភេទ ៕

## ខ្មែរកណ្ដាលស្រោចខាលខាល់...

ពិតប្រាកដ ឬយ៉ាងណានោះទេ ពីព្រោះជាប្រយោជន៍ដែលខ្ញុំមានការលំបាកជាទីបំផុតនឹងយល់ ។ បុរសចំណាស់នោះបាននិយាយប្រយោគដែលខ្ញុំយល់ថា ត្រូវសែនត្រូវពី "ខ្លួនជាខ្មែរ ក៏ប៉ុន្តែ តាមពិត គឺជាខ្មោចកណ្ដាលស្រែសោះ" ស្មានថា គ្រាន់បើ! ភាពអន់ខ្សោយនៃខ្មែរនេះ បានធ្វើឱ្យខ្ញុំផ្ទុះសំណើចដោយមិនដឹងខ្លួន ។ នៅហ្វីឡាដែលហ្វីយ៉ា យើងនេះ ប្រជាពលរដ្ឋខ្មែរមានប្រមាណជា៣ម៉ឺននាក់ រាយគ្នាជាតំបន់ "ឡូគ្កាន់-អលនី "ប្រមាណជា១ម៉ឺននាក់ តំបន់ "ហ្វីលី" ខាងត្បូងជុំវិញផ្លូវលេខ៧ ប្រមាណជា១ម៉ឺននាក់ទៀត តំបន់ខាងត្បូងនៅឈៀងខាងលិចតាមផ្លូវ "វូដឡិន" ជាដើមមានមនុស្សប្រមាណជា៥០០០នាក់ទៀត នៅសល់ពីនោះមានប្រជាពលរដ្ឋខ្មែរដែលរស់នៅ



ដាច់ពីគេក្នុងតំបន់ផ្សេងៗ រហូតដល់ "ហារីប៊ើក" គិតថា ប្រមាណ៥ពាន់នាក់ទៀត គឺជាពលរដ្ឋជនជាតិភាគតិចដ៏ច្រើនជាងគេបន្ទាប់ពីពួក "ស្បានិស្ក"មក។ លក្ខណៈដែលផ្ទុយពីការរងចាំរបស់សហគមន៍ គឺនៅតំបន់នីមួយៗដែលយើងឆ្លងកាត់ហាងពាណិជ្ជកម្មដែលមានខ្មែរជាម្ចាស់មានចំនួនតិចតួចបំផុត ឬស្ទើរគ្មានទាន់តែសោះលើកលែងតែផ្លូវលេខ៧ខាងត្បូង គឺមានហាងខ្មែរជាច្រើននៅរាយទីនោះ ក៏ប៉ុន្តែពុំមានលក្ខណៈធំសង្រ្គោងណាមួយទេ ដូចជាហាង "អង្គរណូដល" ធំជាងគេមានសាលទទួលភ្ញៀវប្រមាណ ៤០ម៉ែត្រ ការ៉េតែប៉ុណ្ណោះ -ហាងមេគង្គវីដេអូ ដែលធំជាងគេក្នុងតំបន់ផ្លូវលេខ៧ ក៏នៅពុំទាន់ជា SUPER STORE នៅឡើយដែរ -មានហាងដ៏ធំសមរម្យមួយទៀត នៅផ្លូវវ៉ាស៊ីនតុន ឈ្មោះ "អ៊ោក ជឿន "មានកន្លែងចតឡានធំល្មម ប៉ុន្តែមានភ្ញៀវតិចតួច ដោយម្ចាស់ហាងមានសំដីមិនទទួលភ្ញៀវទាល់តែសោះ ។ ឃើញរូបភាពតែប៉ុណ្ណេះគួរឱ្យអណោចអធមដល់គ្រួសារខ្មែរ ដែលរស់នៅលាតសន្ធឹងលើដែនដីវាល់យោជ នាហ្វីយ៉ាដែលហ្វីយ៉ា នេះ ប៉ុន្តែពុំបានគាំទ្រសកម្មភាពពាណិជ្ជកម្មសហគមន៍ខ្លួនឱ្យរស់បានប្រសើរនឹងចំនួនសមស្របតាមសេចក្ដីត្រូវការរបស់ជីវិតសោះមិនខុសពីពាក្យរបស់បុរសចាស់នោះនិយាយថា ខ្មែរវាល់យោជរកខ្មោចមិនឃើញនោះទេ ។

នៅមានកន្លែងដែលគួរឱ្យកត់សម្គាល់ផ្សេង ៣ ទៀតដែរ ដូចជា: នៅម្ដុំ "ឡូគ្កាន់-អលនី" មានភោជនីយដ្ឋានធំតែមួយឈ្មោះ ណាម វ៉ាង ដែលអាចរកម្ហូបរស់ជាតិខ្មែរបានបើមុនដូច្នោះទេ គេត្រូវទៅហាងយួន ឬកូរ៉េ ឬ ចិន ។ ហាងខ្មែរឯទៀត ដូចជា នៅផ្លូវ "អូលយ៉ក" នាខាងជើងហ្វីឡាដែលហ្វីយ៉ាមានហាងខ្មែរ តូចៗដែលមានដំណើរការលំបាក ហើយត្រូវនាំគ្នាចេញមកលក់សាច់គោ ឬមានអាំងបន្ថែម នៅតាមចិញ្ចើមថ្នល់ នារដូវក្ដៅ រីឯហាងខ្លះទៀត ត្រូវបិទទ្វារដោយគ្មានភ្ញៀវគ្រប់គ្រាន់លើកលែងតែហាងចាប់ហួយធំមធ្យម១ទៀត នៅលើផ្លូវ "អូលយ៉ក" នេះដែរ មានដំណើរការសមរម្យ ដូចគ្នានឹងហាង "កុំព្យូទ័រប៊ីស" នៅផ្លូវលេខ៥ខាងជើង ឬក៏ហាងជួសជុលរថយន្តមួយចំនួនធំ ច្រើនធ្វើការនៅ ឡូគ្កាន់ បានល្អស្របគ្នានឹងហាងលក់សៀវភៅ ឬវីដេអូដែរ ។ ចំនួនហាងតិចតួចទាំងនោះ មិនសមនឹងចំនួនប្រជាពលរដ្ឋដ៏ច្រើនដែលរស់នៅទីនោះទេ ។ បើសម្លឹងទៅខាងផ្លូវ "វូដឡិន្ត" នាផ្នែកខាងលិច ឬខាងត្បូងឈៀងខាងលិចវិញ ពលរដ្ឋនៅទីនោះ មកទិញអីវ៉ាន់ តែនៅខាងហ្វីឡាទេ ពីព្រោះពួកគាត់គ្មានជម្រើសច្រើនទេ

( តទៅទំព័រទី២០ )



# ចាប់ខ្លួននិពន្ធនាយក...

កន្លងមកត្រូវមន្ត្រីធំៗនៃគណបក្សប្រជាជនកម្ពុជា អូសទាញទិញទឹកចិត្ត ប៉ុន្តែលោកមិនព្រមលក់ខ្លួន លក់ឧត្តមគតិ ។ ដូច្នេះហើយទើបគណបក្សកាន់អំណាចរកលេសពីបទផ្សព្វផ្សាយព័ត៌មានមិនពិត ធ្វើការចាប់ខ្លួនជាការបំបាក់ស្មារតីតែម្តង ។

លោក អេង ឆៃអ៊ាង បន្តថា ច្បាប់បរិហារកេរ្តិ៍ផ្សព្វផ្សាយព័ត៌មានមិនពិតត្រូវសភាជាតិធ្វើវិសោធនកម្មចេញពីមាត្រានេះហើយ គឺពុំមានអ្នកកាសែតណាត្រូវចាប់ដាក់គុកដោយសារតែការសរសេរព័ត៌មានពីបទបរិហារកេរ្តិ៍ និងផ្សាយព័ត៌មានមិនពិតនោះទេ គឺកំណត់ត្រឹមពិន័យជាប្រាក់តាមការវិនិច្ឆ័យរបស់តុលាការប៉ុណ្ណោះ ។

លោក ចាន់ សុវៃត មន្ត្រីអង្កេតនៃអង្គការសិទ្ធិមនុស្សអាដហុក បានឱ្យដឹងថា ការចាប់ខ្លួនលោក ដាំ សិទ្ធិ តាមដីការរបស់លោកចៅក្រម ឆាយ គង់ តុលាការក្រុងភ្នំពេញ ពីបទបរិហារកេរ្តិ៍ និងផ្សព្វផ្សាយព័ត៌មានមិនពិត តាមបណ្តឹងរបស់លោក ហោ ណាំហុង នេះ គឺជាការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ និងជះឥទ្ធិពលអាក្រក់ដល់អ្នកសាព័ត៌មាន ។

លោក ចាន់ សុវៃត បន្តថា លោក ដាំ សិទ្ធិ ធ្លាប់គេលួងលោមឱ្យចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា តែលោកបដិសេធ ។ ដូច្នេះការចាប់ខ្លួនអាចពាក់ព័ន្ធរឿងនយោបាយ ពីព្រោះលោក ដាំ សិទ្ធិ ជាបេក្ខជនតំណាងរាស្ត្រគណបក្ស សម រង្ស៊ី អាណត្តិទី៤ មណ្ឌលភ្នំពេញ ។

លោកនិពន្ធនាយកកាសែតមនសិការត្រូវបានចាប់ខ្លួននៅម៉ោង១១ ថ្ងៃទី៨ មិថុនាកន្លងមកនេះ ខណៈពេលលោកយកឡានទៅលាងត្រូវសមត្ថកិច្ចប៉េអឹមផ្ទៃប្រទេសចាប់ខ្លួនទៅដាក់គុកព្រៃស ។

ដើម្បីជាការឆ្លើយតបនោះ សមាគមសារព័ត៌មានឃ្លាំមើលកម្ពុជា និងសមាគមអ្នកសារព័ត៌មានខ្មែរប្រជាធិបតេយ្យបានចេញសេចក្តីថ្លែងការមួយសុំឱ្យអង្គការសិទ្ធិមនុស្សជាតិ និងអន្តរជាតិ និងម្ចាស់ជំនួយបរទេស សម្រាប់កម្ពុជាជួយឃ្លាំមើលការចាប់ខ្លួនលោក ដាំ សិទ្ធិ ផង ។

សមាគមសារព័ត៌មានខាងលើបានស្នើឱ្យតុលាការស៊ើបអង្កេតក្នុងសុំណុំរឿងការចាប់ខ្លួនលោក ដាំ សិទ្ធិ ឡើងវិញ ពីព្រោះវាជាការរំលោភទៅលើច្បាប់អ្នកសារព័ត៌មាន ។

ក្នុងពេលជាមួយគ្នានោះដែរ មេធាវីរបស់លោក ដាំ សិទ្ធិ គឺលោក គង់ សំអូន បានឱ្យដឹងថា ការចាប់ខ្លួនលោកនិពន្ធនាយកកាសែតមនសិការ ដែលទាក់ទងទៅនឹងការស្រង់សំដីលោក សម រង្ស៊ី ថាលោក ហោ ណាំហុង ជាអតីតមេគុកបឹងត្របែកក្នុងសម័យ ប៉ុល ពត ។

លោក គង់ សំអូន បញ្ជាក់ថា ការឃុំខ្លួននេះពុំមានហេតុផលច្បាស់លាស់ ពីព្រោះគ្រាន់តែយោងលើការចោទប្រកាន់របស់ព្រះរាជអាជ្ញាក៏សម្រេចឃុំខ្លួន ។ រីឯបទបរិហារកេរ្តិ៍ក៏ពុំមានអ្វីមកបញ្ជាក់ឱ្យបានពិស្តារដែរ ។

ចំណែកលោក ផុង ផូមី ដែលជាមេធាវីលោក ដាំ សិទ្ធិ ដែរ បានឱ្យដឹងថា កូនក្តីរបស់លោកត្រូវលោក ហោ ណាំហុង ប្តឹងពីបទបរិហារកេរ្តិ៍ និងផ្សាយព័ត៌មានមិនពិត ដែលមានលោក កា សាវុធ ជាតំណាងបណ្តឹង ។

លោក ផុង ផូមី បន្តថា ការឃុំខ្លួននេះមិនត្រឹមត្រូវទេ ពីព្រោះតាមអង្គច្បាប់គ្មានឃើញធាតុផ្សំនៃបទល្មើសណាមួយដែលបញ្ជាក់ថាការផ្សព្វផ្សាយរឿងមិនពិតទេ ។ ការផ្សាយនេះធ្វើឡើងតាមរយៈការដកស្រង់សំដីរបស់លោក សម រង្ស៊ី ដែលជាអ្នកនយោបាយមួយរូបប៉ុណ្ណោះ ។

ជាពិសេសនោះកាលពីថ្ងៃទី៥ ខែ មិថុនា គាត់បានចូលខ្លួនទៅបំភ្លឺនៅក្នុងតុលាការរួចហើយ ។ តាមនីតិវិធីតុលាការចៅក្រមត្រូវចេញដីការឱ្យគាត់ចូលខ្លួនម្តងទៀត ប៉ុន្តែពេលនេះ ចៅក្រមស៊ើបអង្កេតពុំបានអនុវត្តទៅតាមនីតិវិធីបង្គាប់ឱ្យចូលខ្លួនទេ បែរជាចេញដីការចាប់ខ្លួនទៅវិញ ។

លោកស្រី ពុង ឈីវកេក ប្រធានអង្គការសិទ្ធិមនុស្សលីកាដូ បានសំដែងការសោកស្តាយយ៉ាងខ្លាំងនៅពេលឃើញតុលាការចេញដីកាចាប់ខ្លួន លោក ដាំ សិទ្ធិ បែបនេះ ពីព្រោះលោក ដាំ សិទ្ធិ ជាអ្នកកាសែត គួរយកច្បាប់កាសែតមកប្រើប្រាស់មិនត្រូវយកច្បាប់ព្រហ្មទណ្ឌមកអនុវត្តលើអ្នកកាសែតទេ ។

លោកស្រី ពុង ឈីវកេក បន្តថា ការចាប់ខ្លួនអ្នកកាសែតបែបនេះ វាប៉ះពាល់ដល់សិទ្ធិសេរីភាពសារព័ត៌មាន ជាពិសេសចំពោះលោក ដាំ សិទ្ធិ ដែលជាអ្នកមាននិន្នាការទៅរកគណបក្សប្រឆាំង គឺអាចប៉ះពាល់ដល់ផ្នែកនយោបាយផងដែរ ។


ពុង ឈីវកេក

ដោយលោកស្រីអំពាវនាវដល់តុលាការឱ្យដោះលែងលោក ដាំ សិទ្ធិ ជាបន្ទាន់ ។

លោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មានក៏បានសរសេរលិខិតទៅកាន់តុលាការក្រុងភ្នំពេញស្នើឱ្យដោះលែងលោក ដាំ សិទ្ធិ នៅក្រៅឃុំបណ្តោះអាសន្ន ពីព្រោះនេះជារឿងបុគ្គលរវាងលោក ដាំ សិទ្ធិ និងលោកឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង មិនមែនរឿងរដ្ឋាភិបាលនោះទេ ។ ចំណែកមន្ត្រីតុលាការក្រុងភ្នំពេញ ក៏បានទទួលលិខិតនេះហើយ ប៉ុន្តែកំពុងធ្វើការពិចារណា តើត្រូវសំរេចបែបណា ។

ចំណែកលោក ប៉ែន សមិទ្ធិ ប្រធានក្លឹបអ្នកកាសែតកម្ពុជា បានសំដែងនូវការរីករាយ នៅពេលដឹងថា លោក ខៀវ កាញារីទ្ធ បានសរសេរលិខិតធានាឱ្យលោក ដាំ សិទ្ធិ នៅក្រៅឃុំបណ្តោះអាសន្ននោះ ។ លោកក៏បានបញ្ជាក់ថាចំពោះលោក ដាំ សិទ្ធិ តាមច្បាប់អ្នកសារព័ត៌មាន ដែលលើកសំដីរបស់អ្នកនយោបាយមកសរសេរនោះ គឺគ្មានកំហុសនោះទេ បើគ្រាន់តែលើកសំដីគេមកសរសេរខុសនោះគ្មាននរណាធ្វើកាសែតកើតទេ ។

កាលពីថ្ងៃទី៩ មិថុនា កន្លងមកនេះ អង្គការនិងសមាគមដែលមានឥទ្ធិពលនៅកម្ពុជា ចំនួន ៣បានចេញសេចក្តីថ្លែងការណ៍រួមគ្នា គឺសមាគមសិទ្ធិមនុស្សអាដហុក អង្គការសិទ្ធិមនុស្សលីកាដូ និងមជ្ឈមណ្ឌលសិទ្ធិមនុស្ស បានស្នើឱ្យតុលាការដោះលែង ដាំ សិទ្ធិ ជាបន្ទាន់ និងជាពិសេសឱ្យលើកលែងការចោទប្រកាន់ ។

សេចក្តីថ្លែងការណ៍ក៏បានបញ្ជាក់ថា ទង្វើបែបនេះវាធ្វើឱ្យប៉ះពាល់សិទ្ធិសេរីភាពសារព័ត៌មាន ជាពិសេសនោះតុលាការមិនគោរពច្បាប់សារព័ត៌មាន ។

ជាមួយនេះដែរ លោក ឡៅ ម៉ុងហៃ អ្នកស្រាវជ្រាវសិទ្ធិមនុស្សជាន់ខ្ពស់អាស៊ី ដែលមាន

( តទៅទំព័រទី១៦ )

# សម រង្ស៊ី ៖ សុខចិត្ត...

អ្នកកាសែតអន្តរជាតិ មន្ត្រីគណបក្សប្រឆាំង អង្គការសង្គមស៊ីវិលទាំងក្នុង និងក្រៅប្រទេស ស្នើឱ្យដោះលែងលោក ដាំ សិទ្ធិ ដោយគ្មានលក្ខខណ្ឌ ។

ជាមួយគ្នានោះដែរ លោកស្រី ពុង ឈីវកេក ប្រធានអង្គការសិទ្ធិមនុស្សលីកាដូ បានហៅការចាប់ខ្លួនលោក ដាំ សិទ្ធិ នេះគឺជាការរំលោភច្បាប់សារព័ត៌មានក្នុងការបញ្ចេញមតិ និងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពសារព័ត៌មាន និងសិទ្ធិផ្នែកនយោបាយផងដែរ ពីព្រោះលោក ដាំ សិទ្ធិ ជាអ្នកកាសែត ដែលមាននិន្នាការគាំទ្រគណបក្ស សម រង្ស៊ី ។


បណ្ឌិត ឡៅ ម៉ុងហៃ

ចំណែកលោក ឡៅ ម៉ុងហៃ អ្នកស្រាវជ្រាវសិទ្ធិមនុស្សជាន់ខ្ពស់អាស៊ី ដែលមានទីស្នាក់ការនៅទីក្រុងហុងកុង បានឱ្យដឹងថា តុលាការមិន គួរចាប់ខ្លួនលោក ដាំ សិទ្ធិ ទេ ពីព្រោះលោកគ្រាន់តែដកស្រង់សំដីរបស់អ្នកនយោបាយមកធ្វើការចុះផ្សាយប៉ុណ្ណោះ ។ ការចោទប្រកាន់រហូតដល់មានការប្រើកងកំលាំងប្រដាប់អាវុធចាប់ខ្លួនបញ្ជូនទៅដាក់គុកបែបនេះវាប៉ះពាល់ដល់សិទ្ធិនៃការបញ្ចេញមតិខ្លាំងណាស់ ។

លោក ឡៅ ម៉ុងហៃ បន្តថា តុលាការគួរតែយកច្បាប់សារព័ត៌មានទៅអនុវត្តលើអ្នកកាសែតណាដែលសរសេរបរិហារកេរ្តិ៍ គឺមិនត្រូវប្រើច្បាប់ព្រហ្មទណ្ឌឡើយ ។

រីឯលោក អៀវ ចាន់ណា សកម្មជនអ្នកឃ្លាំមើលសិទ្ធិមនុស្សកម្ពុជា ដែលបានភៀសខ្លួនទៅរស់នៅប្រទេស ណ័រវៃ បានប្រាប់ខ្មែរប៉ុស្តិ៍ តាមទូរស័ព្ទថា ការចាប់ខ្លួននិពន្ធនាយកកាសែតមនសិការនេះ គឺជាការបំបាក់ស្មារតី ចំពោះអ្នកកាសែតក៏ដូចជាអ្នកគាំទ្រគណបក្ស សម រង្ស៊ី ទាំងឡាយណា ដែលមិនព្រមលក់ខ្លួនលក់ឧត្តមគតិចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា ។

លោក អៀវ ចាន់ណា បន្តថា ចលនាការអូសទាញមន្ត្រីសំខាន់ៗរបស់គណបក្ស សម រង្ស៊ី តាមរយៈការផ្តល់តួនាទី និងអំណាចបុណ្យសក្តិពីសំណាក់ ហ៊ុន សែន នោះ បានធ្វើឱ្យប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋានកាន់តែមានការព្រួយបារម្ភ ពីព្រោះពីមុនពួកគេទាំងនោះធ្លាប់ប្រាប់

( តទៅទំព័រទី២១ )

**Reasons Why You Want to Put**
The Advertisement with the Khmer Post
In Philadelphia

មូលហេតុដែលនាំឱ្យលោកអ្នកផ្សាយពាណិជ្ជកម្មនៅ "ខ្មែរប៉ុស្តិ៍"

The Khmer Post is the only Cambodian media that available to reach out over 30,000 Cambodian readers who live in Philadelphia.



"ខ្មែរប៉ុស្តិ៍" គឺជាប្រព័ន្ធផ្សព្វផ្សាយខ្មែរតែមួយ ដែលចែកផ្សាយដល់អ្នកអានខ្មែរប្រមាណ ៣ ម៉ឺននាក់ កំពុងរស់នៅហ្វីឡាដែលហ្វីយ៉ា

One phone call away to grow your business, 20% discount when you sign up for a contract of year by calling this number (267) 253-3947.

លេខទូរស័ព្ទដែលធ្វើឱ្យពាណិជ្ជកម្មលោកអ្នករីកដុះដាល គឺ :
**(267) 253-3947**
យើងខ្ញុំចុះថ្លៃជូន ២០ % បើលោកអ្នកផ្សាយ ១ ឆ្នាំ

**Growing your business. Advertise yourself.**

## សម្តេចក្រុមព្រះ ហ៊ុន សែន...

មាន ឬគ្មានវត្តមាននរោត្តម រណឫទ្ធិ នោះ គឺគណបក្សនរោត្តម រណឫទ្ធិ បានក្លាយទៅជាគណបក្សទី២ទៅហើយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ លោកនាយករដ្ឋមន្ត្រីដែលវាយប្រហារមកលើរូបខ្ញុំ ឥឡូវនេះមកលើគណបក្សខ្ញុំ មានន័យថា គណបក្សខ្ញុំបានក្លាយជាគណបក្សធំមួយនេះទី១ ។ ហើយទី២ទៀត ទោះអវត្តមាន ឬវត្តមានរូបខ្ញុំ ក៏គណបក្សនរោត្តម រណឫទ្ធិ ត្រូវតែបានទទួលនូវអាសនៈក្នុងរដ្ឋសភាក្នុងប៉ុន្មានថ្ងៃខាងមុខនេះ ។

**+ខ្មែរប៉ុស្តិ៍ :** តើព្រះអង្គមានព្រះតំរិះតាមច្រកណា ដើម្បីឱ្យព្រះអង្គមានលទ្ធភាពយាងចូលប្រទេសកម្ពុជាវិញ នៅពេលដែលប្រជារាស្ត្រក៏កំពុងតែត្រូវការព្រះអង្គដែរ មិនអាចអត់បានដែរនោះ ដោយចង់ឱ្យព្រះអង្គយាងចូលស្រុកដោយសន្តិវិធីមុនការបោះឆ្នោត ក្រៅតែពីច្រកសុំក្តីសណ្តោសប្រណីពីការលើកលែងទោសរបស់ព្រះមហាក្សត្រ ដែលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កំពុងតែជំទាស់មិនឱ្យព្រះមហាក្សត្រលើកលែងទោសព្រះអង្គ ដោយលោក ហ៊ុន សែន អះអាងថា វាទាល់តែមានស្នើសុំពីនាយករដ្ឋមន្ត្រីជាមុនសិន តើបញ្ហានេះព្រះអង្គយល់យ៉ាងណា ហើយមានច្រកណាផ្សេងពីនេះទេ ?

**+សម្តេចក្រុមព្រះ :** ខ្ញុំសូមបញ្ជាក់ហើយបញ្ជាក់ទៀតថា ទី១ពាក្យពេចន៍របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺរំលោភនូវព្រះរាជសិទ្ធិរបស់ព្រះករុណា ដែលបានចែងក្នុងមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញ ដោយព្រះករុណាអត់ត្រូវសុំឬសួរនាយករដ្ឋមន្ត្រីទេ ហើយអតីតកាលបានបង្ហាញឱ្យឃើញច្បាស់ណាស់ថា សម្តេចតា សម្តេចឪលោកបានព្រះរាជទានទោសដល់ទណ្ឌិតច្រើនណាស់ ដែលគ្មានការសុំយោបល់ពីនាយករដ្ឋមន្ត្រី ។ ហើយខ្ញុំសូមជំរាបថា ប្រសិនការបោះឆ្នោតគ្មានវត្តមានខ្ញុំនោះ ខ្ញុំយល់ថា ប្រទេសជាច្រើនណាស់ដែលគេផ្តល់ជំនួយ ឬក៏ប្រជាពលរដ្ឋខ្មែរក៏អញ្ចឹងដែរយល់ថា ការបោះឆ្នោតនេះមិនមែនជាការបោះឆ្នោតមានលក្ខណៈប្រជាធិបតេយ្យត្រឹមត្រូវស្មើភាពគ្នា ។ល។ និង ។ល។ នោះទេ ។ ជាមួយគ្នានោះផងដែរ ខ្ញុំនៅតែមានជំនឿថា ប្រទេសដែលផ្តល់ជំនួយ ដែលខ្ញុំមិនដែលចង់ទៅពឹងពាក់ពួកបរទេសទេ ប៉ុន្តែមានប្រទេសមួយចំនួនគេបានចាប់ផ្តើមចរចារួចហើយ ។ ហើយ ទី២ទៀតអង្គការក្រៅរដ្ឋាភិបាល ក៏គេបានធ្វើសេចក្តីថ្លែងការហើយដែរ សុំឱ្យខ្ញុំចូលទៅស្រុកប្រកួតប្រជែងការបោះឆ្នោត ដោយសេរី មិនមែនចូលទៅហើយយកទៅដាក់គុកដាក់ខ្នោះនោះទេ ក្នុងឋានៈខ្ញុំជាប្រធានគណបក្សមួយ ហើយក្នុងឋានៈខ្ញុំជាខ្មែរម្នាក់ផង ។

**+ខ្មែរប៉ុស្តិ៍ :** បញ្ហាគន្លឹះនៃពាក្យបណ្តឹង និងសំពាធនយោបាយតាមប្រព័ន្ធតុលាការបច្ចុប្បន្នតែងតែញាំញីព្រះអង្គ ដោយនិរទេសនៅក្រៅប្រទេស ក្នុងបំណងបញ្ចប់ជីវិតនយោបាយរបស់ព្រះអង្គ ដូចដែលលោក ញឹក ប៊ុនឆៃ បានអះអាងប្រាប់ខ្មែរប៉ុស្តិ៍មកថា នេះជាផែនការលោកនាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន ជាមួយអតីតព្រះមហាក្សត្រ និងព្រះមហាក្សត្រក្តី ដែលមាន ញឹក ប៊ុនឆៃ ផ្ទាល់ជាអ្នកអនុវត្ត ចាំតែធ្វើតាមព្រះរាជតម្រិះ ឬតាមបញ្ជា ដើម្បីបញ្ឈប់ជីវិតធ្វើនយោបាយរបស់ព្រះអង្គ តើក្នុងការអះអាងរបស់លោក ញឹក ប៊ុនឆៃ នេះ តើព្រះអង្គទតឃើញយ៉ាងដូចម្តេច ?

**+សម្តេចក្រុមព្រះ :** ខ្ញុំសូមជំរាបថា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន តាមរយៈលោក ញឹក ប៊ុនឆៃ មានគម្រោងការកំទេចខ្ទេចឱ្យអស់នូវគណបក្សហ៊្វុនស៊ិនប៉ិច ដែលកាលណោះខ្ញុំជានាយករដ្ឋមន្ត្រី ។ ឥឡូវឃើញថា គណបក្សហ៊្វុនស៊ិនប៉ិច កំពុងស្ថិតនៅក្នុងការខ្ទេចខ្ទាំនូវការអះអាងរបស់លោក ញឹក ប៊ុនឆៃ នេះចំណុចទី១ ។ ចំណុចទី២ ខ្ញុំសូមជំរាបថា សម្តេចតា សម្តេចឪគ្រាន់តែមានជាព្រះរាជយោបល់ទេ ប៉ុន្តែខ្ញុំគ្រាន់តែជំរាបជាយោបល់ទេ ដែលខ្លួនខ្ញុំជាស្តេចធ្លាប់តែរស់នៅជាមួយប្រជារាស្ត្រនរោត្តម រណឫទ្ធិ ធ្លាប់តែបំរើប្រជារាស្ត្រ ដូចជាលោក មាជ សុវណ្ណារ៉ា លោកជ្រាបស្រាប់ហើយ ដែលខ្ញុំនាំមកវិញនូវរបបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញ ។ល។និង។ល។ ហើយខ្ញុំជាខ្មែរម្នាក់ព្រះមហាក្សត្រខ្មែរ ស្តេចខ្មែរ តែងតែធ្វើនយោបាយដើម្បីបំរើជាតិ បំរើរាស្ត្រ ដូច្នេះខ្ញុំ នរោត្តម រណឫទ្ធិ ខ្ញុំពុំអាចឈប់ធ្វើនយោបាយបានទេ ។ នៅពេលខ្ញុំឃើញព្រះរាជាណាចក្រកម្ពុជា កំពុងទទួលនូវវង្គ្រោះរបៀបនេះ បញ្ហាទឹកដី បញ្ហាអន្តោប្រវេសន៍ខុសច្បាប់ បញ្ហាអ្នកមានអំណាចរំលោភយកដីធ្លី ផ្ទះសម្បែងប្រជាពលរដ្ឋ ការឃុបឃិតរវាងអាជ្ញាធរ តុលាការចាប់ខ្លួនជនស្លូតត្រង់ដាក់គុក ដាក់ច្រវាក់យ៉ាងមហាវេទនា មហាអយុត្តិធម៌ ដែលខ្មែរយើងស្ថិតក្នុងភាពក្រីក្របំផុត ទំនិញឡើងថ្លៃ លក់នូវដីព្រៃ និងសម្បត្តិរដ្ឋលក់អស់រលីងហើយ ។ ដូច្នេះនៅក្នុងស្ថានការណ៍ដែលពិបាកតោកយ៉ាករបៀបនេះ នរោត្តម រណឫទ្ធិ បិទមាត់មិនបានទេ គេឱ្យធ្វើនយោបាយ ឬមិនឱ្យធ្វើនយោបាយ ដែលខ្ញុំគ្មានជំរើសអ្វីក្រៅតែពីបន្តនូវសកម្មភាពរបស់ខ្លួន មិនមែនធ្វើនយោបាយដើម្បីចង់ធ្វើធំនោះទេ គឺធ្វើនយោបាយដើម្បីបំរើប្រទេសជាតិ និងបំរើរាស្ត្រ ។

**+ខ្មែរប៉ុស្តិ៍ :** លោក ហ៊ុន សែន បានស្នើទៅព្រះមហាក្សត្រ ដើម្បីកុំឱ្យគណបក្សនយោបាយនានាយកឈ្មោះរបបរាជានិយម ឬថា គណបក្សរាជានិយមទៅប្រើប្រាស់ ដើម្បីធ្វើជាប្រជាភិថុតនយោបាយក្នុងការគៀងគររកសម្លេងឆ្នោតក្នុងការបោះឆ្នោតនោះ ។ តើបំរាមហាមរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន វាជាការស្រប ឬផ្ទុយពីរដ្ឋធម្មនុញ្ញទេ សូមព្រះអង្គមានព្រះរាជបន្ទូលមើល ?

**+សម្តេចក្រុមព្រះ :** ខ្ញុំសូមជំរាបថា រដ្ឋធម្មនុញ្ញអត់មានហាមឃាត់ទេ រដ្ឋធម្មនុញ្ញ និងច្បាប់តែងអំពីគណបក្សនយោបាយបាននិយាយហាមប្រាមមិនឱ្យគណបក្សណាប្រើអ្វីមួយដែលជាសញ្ញាជាតិដូចជា ប្រាង្គប្រាសាទអង្គរវត្ត គេមិនឱ្យប្រើទេ និងប្រើប្រាស់ព្រះឆាយាល័ក្ខណ៍អតីតព្រះមហាក្សត្រក៏គេមិនឱ្យប្រើដែរ ។

ក៏ប៉ុន្តែថាខ្លួន, ថាគណបក្សរបស់ខ្លួន ថាជាអ្នករាជានិយម ឬគណបក្សរាជានិយមគ្មានច្បាប់គ្មានរដ្ឋធម្មនុញ្ញហ្នឹងហើយៗ ! កម្ពុជារបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនមែនច្បាប់នៅលើក្រដាសទេ គឺច្បាប់នៅលើមាត់ ហ៊ុន សែន តែប៉ុណ្ណោះ ។ ដូច្នេះអ្វីដែលយើងខ្ញុំធ្វើនៅកម្ពុជា យើងមានគណបក្សកុម្មុយនិស្តមានគណបក្សសាធារណរដ្ឋគណបក្សរបស់ខ្ញុំ គឺគណបក្សនរោត្តម រណឫទ្ធិ ជាគណបក្សរាជានិយម ហើយរបបរាជានិយមនេះ ជារបបស្របច្បាប់បានចែងក្នុងរដ្ឋធម្មនុញ្ញ ដែលយើងហៅច្បាស់ថា គណបក្សនៃរបបរាជានិយម និងយើងខុសរដ្ឋធម្មនុញ្ញ ។ ប៉ុន្តែផ្ទុយទៅវិញ យើងគាំទ្ររបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញនេះ ។ ដូច្នេះ អ្វីដែលលោកនាយករដ្ឋមន្ត្រី ( នៅទំព័រទី២២ )

## ការប្រកួតខេមរកីឡា Tenis លើកទី១២ នៅ Long Beach នាសប្តាហ៍ក្រោយ




***ឡុងប៊ិច : វ៉ាន់នាថ***

●●●សហគមន៍ខ្មែរ Long Beach មានក្រុមយុវជន និស្សិត ពួករដ្ឋការ ក្នុងតំបន់គ្រោងចូលរួមប្រកួតប្រជែងល្បែងកីឡាវាយ Tenis លើកទី១២ ដែលប្រព្រឹត្តទៅនៅសប្តាហ៍ក្រោយ នាថ្ងៃទី២១-២២ ខែមិថុនា ឆ្នាំ២០០៨ ។

អ្នករៀបចំកម្មវិធីប្រកួតខេមរកីឡា Tenis លោក សុខ សារ៉េន បានប្រាប់ខ្មែរប៉ុស្តិ៍ថា កម្មវិធីប្រកួតនេះ កើតមានមក តាំងពីឆ្នាំ១៩៩៧ ដែលមានបងប្អូនខ្មែរនៅ Long Beach នាំគ្នាចូលប្រកួតប្រជែង ដែលក្នុងឆ្នាំនេះថា ជាលើកទី១២ហើយ ដោយយើងប្រព្រឹត្តទៅនៅថ្ងៃទី ២១-២២ ខែមិថុនា ឆ្នាំ២០០៨ ។ ដោយលោកអំពាវនាវដល់បងប្អូនខ្មែរដែលមានជំនាញវាយបាល់ Tenis មេត្តាចូលរួមប្រកួតដណ្តើមយកពានរង្វាន់ឆ្នាំ២០០៨ និងរង្វាន់លើកទឹកចិត្ត ។

លោក សុខ សារ៉េន បន្តថា ការរស់រានអាយុកាលនៃកម្មវិធីប្រកួតកីឡាបាល់ Tenis នេះមកចំនួន១២លើកបាន ក៏អាស្រ័យដោយបងប្អូនខ្មែរ ដែលបានគាំទ្រ និងឧបត្ថម្ភទាំងថវិកា ឬសំភារៈឱ្យមានកម្មវិធីនេះជាបន្តមកនោះ ។

សូមបញ្ជាក់ថា ទីតាំងនៃការប្រកួតកីឡា Tenis លើកទី១២ប្រព្រឹត្តទៅនៅថ្ងៃទី២១-២២ សប្តាហ៍ក្រោយនៅមជ្ឈមណ្ឌល VETERANS STADIUM 4901 E. CARSON St, Long Beach, CA 90808 ៕

## ខ្មែរកណ្តាលស្រោចទាល...

មានហាងមាសខ្មែរមួយដែរ នៅលើផ្លូវ "រ៉ូដឡិន្ត" ឬនៅក្បែរនោះ មានហាងធ្វើក្រចកមួយទៀត ។ គួរឱ្យអណោចអធមដែលភ្លេងខ្លួងខែកត្រូវលេងដោយសារពាណិជ្ជកម្មខ្មែរត្រូវរលត់ ឬមិនបានកើតក្នុងតំបន់ដែលសំបូរខ្មែររស់នៅ ។

នៅក្នុងសំនួរដែលថា ពួកយៀកណាម ពួកកូរ៉េ-ចិន គេរកស៊ីកាក់កបបាន ហេតុអ្វីក៏ខ្មែរធ្វើមិនបាន ? ទំនងជាមកពីខ្មែរធ្វើពាណិជ្ជកម្ម ដោយគ្មានជំនាញ ឬក៏មកពីខ្មែរមិនចេះជួយគាំទ្រគ្នា ! ឬក៏មកពីវាសនាខ្មែរ ត្រូវតែវេទនាជារហូតទៅយ៉ាងនេះ ?

ដល់ត្រឹមនេះ ខ្ញុំនឹកដល់សំដីបុរសចាស់នោះទៀត ខ្លួនគាត់ជាខ្មែរ តែ "ខ្មែរឆ្កោច" គឺគាត់នឹងស្លាប់ទៅដូច"ខ្មោចឆ្កែ"ដោយសេចក្តីក្រមិនអាចឱ្យយកខ្មោចទៅដុត ឬកប់តាមប្រពៃណីបានទេ គាត់នឹកថា ប្រគល់សពឱ្យទៅពេទ្យយកទៅពិសោធន៍ សំរាប់រៀនសូត្រទៅមិនអស់លុយ!។ ស្ថិតិបាននិយាយថា "ខ្មែរនៅសហគមន៍ ហ្វីឡានេះ មានលើសពី ៥០% រស់នៅក្រោមបន្ទាត់ក្រីក្រ ដោយសារភាគច្រើនរស់ "ដោយលុយពិកា" ខ្លះរស់ដោយលុយ"ជំនួយរដ្ឋ " ដែលទទួលបានតិចជាង៥០០ ដុល្លារក្នុង១ខែ ហើយមួយចំនួនទៀត រស់ដោយការងារ "លុយសុទ្ធ" ដែលជាការងារមិនទៀតទាត់ ហើយបានប្រាក់កំរៃតិច ។ បើសង្ឃឹមលើកូន ឬចៅសិស្សកូនខ្មែរប្រមាណជាង៦០% បានបោះបង់សាលារៀននៅមុនចប់វិទ្យាល័យ គឺប្រាកដជាពុំមានសំណាងទៅជួយឪពុកម្តាយចាស់ ក្រៅតែពីជួយខ្លួនឯងតែម្នាក់នោះបានឡើយ ។ ក្នុងរូបភាពនេះបុរសចំណាស់នោះ ជាពុំមែន "ខ្មែរឆ្កោច" តែម្នាក់ឯងទេ... ។ រីឯរូបខ្ញុំបើចង់គិតត្រូវ តើត្រូវគិតតាមមនុស្សឆ្កួត ឬអ្វី? ឬក៏ចាំខ្ញុំឆ្កួត ទើបគិតត្រូវ?

ខ្ញុំបានឃើញមនុស្សចាស់នោះបីខែមកក្រោយមកឈរសម្ងក់អ្នកអាំងសាច់នៅជ្រុងផ្លូវ "រ៉កឡិន្ត" នឹង "អូលយ៉ក" យ៉ាងស្ងៀមស្ងាត់ ខ្ញុំបានឃើញគាត់ពិសារសាច់គោមួយចង្កាក់ ដែលកំពុងអាំងក្លិនឈ្ងុយ គាត់តបថា "គាត់គ្មានលុយទេ-អរគុណហើយ " ហើយក៏ដើរចេញទៅដូចមនុស្សត្រូវថ្នាំសណ្តំ ៕

## គុណប្រយោជន៍របស់ ការ៉ុត



●មើមការ៉ុតគេអាចទទួលទានបានទាំងសាច់ និងសំបក នោះក៏ព្រោះសំបកមើមការ៉ុត វាពោរពេញទៅដោយវីតាមីន និង រ៉ែធាតុយ៉ាងច្រើនបំផុត ។ មុនដំបូងអ្នក គួរលាងទឹកឱ្យស្អាតរួចសឹមយកទៅហាន់ទាំងសំបកប្រើការទៅតាមបំណងប្រាថ្នា ។

## ប្រតិបត្តិការណ៍បញ្ឈប់...

បង្ខំឱ្យទទួលភ្ញៀវ ប្រសិនបើនរណាមិនស្តាប់បង្គាប់ទេនោះ ជីវិតនាងនឹងត្រូវរលត់ ដូចជាមិត្តភ័ក្តិរបស់នាងអញ្ចឹង ។

ដោយការពុះពារតស៊ូរនោះ ធ្វើឱ្យក្មេងម្នាក់នេះរួចផុតពីឋាននរកអវិចីក៏កាចឃោរឃៅនេះ។ សព្វថ្ងៃនេះអ្វីៗបានផ្លាស់ប្តូរជាបន្ទបន្ទាប់នាងក្លាយទៅជានារីម្នាក់ដែលមានរូបសម្ផស្សស្រស់សោភា ។ ជាពិសេសនោះត្រូវបានប្រជាជនភាគច្រើនបានស្គាល់ និងផ្តល់តំលៃដល់នាងដែលមិននឹកស្មានដល់ ។ ជីវិតក្នុងកុមារីភាពរបស់នាងពិតជាជូរចត់ដែលមិនអាចនឹងរកពាក្យមកប្រៀបធៀបបាន ។ ទោះជាយ៉ាងណាក្តីទម្រាំតែនាងមានឱកាសដល់សព្វថ្ងៃនេះ នាងត្រូវបានអង្គការស្របច្បាប់មួយជួយសង្គ្រោះ ។ ក្នុងនោះគោលបំណងរបស់នាង និងធ្វើយ៉ាងណាមិនឱ្យក្មេងជំនាន់ក្រោយជួបបញ្ហាដ៏ជូរចត់ ដូចជារូបនាងឡើយ ។ ម្យ៉ាងវិញទៀតនោះ នាងត្រូវបានវិបសាយរបស់ CNN លើកឡើងថា នាងជា "នារីឯក" ទៀតផង ។ អ្នកនាង សុមាលី សព្វថ្ងៃនេះបានបង្កើតកន្លែងស្នាក់នៅសំរាប់ជនរងគ្រោះពីអាជីវកម្មផ្លូវភេទនៅក្នុងប្រទេសកម្ពុជា ។ រហូតមកដល់ពេលនេះ អ្នកស្រី ម៉ម សុមាលី បានជួយសង្គ្រោះក្មេង៥៣នាក់ហើយ ហើយក្មេងជាច្រើន ក្នុងចំណោមនោះមានរបួសផ្នែកចិត្តសាស្ត្រជាខ្លាំងចំណែក ខ្លះទៀតបង្ហាញយ៉ាងច្បាស់ថា "ពួកគេជាច្រើន នាក់ពេលដែលមកដល់ទីនេះមានបញ្ហាផ្លូវចិត្តជាខ្លាំង ។ ហើយពួកគេមិនដែលទទួលបាននូវក្តីស្រលាញ់ពីមនុស្សដទៃទៀត សូម្បីតែឪពុកម្តាយក៏មិនដែលផ្តល់ភាពកក់ក្តៅសំរាប់ពួកគេដែរ ។

ក្មេងស្រីម្នាក់នៅក្នុងកន្លែងរបស់អ្នកស្រី សុម៉ាលី ដែលមើលទៅហាក់បីដូចជារងគ្រោះជាខ្លាំង ។ នាងត្រូវបានគេជួយសង្គ្រោះក្រោយ ពេលជាប់ឃុំឃាំងអស់រយៈពេលប្រហែលជាពីរឆ្នាំ នៅក្នុងទីកន្លែងដ៏តូចមួយនៅទីនោះនាងត្រូវបានគេចាប់រំលោភយ៉ាងព្រៃផ្សៃ ។

ជាការពិតណាស់នាងត្រូវការថែទាំចិត្តតាមបែបចិត្តសាស្ត្រ ។ អ្នកស្រី សុម៉ាលី ក៏បានបន្តទៀតដែរថា នាងនឹងខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាពទាំងកំលាំងកាយ និងចិត្ត ដើម្បីផ្តល់នូវក្តីស្រឡាញ់ ក៏ដូចជាការគាំទ្រចំពោះក្មេងស្រីគ្រប់ៗរូប ។ ផ្នែកទៅលើបញ្ហានេះ វាមិនងាយស្រួលសំរាប់អ្នកស្រីទេ ពីព្រោះខណៈពេលដែលមានក្មេងៗជាច្រើនទៀតក៏ត្រូវការថែទាំបែបនេះដែរ ។

បើទោះបីជាមានការចាប់អារម្មណ៍បែបនេះ ក្តី សុម៉ាលី បាននិយាយថា ស្ថានភាពនៃអ្នករកស៊ីផ្លូវនេះ មិនទាន់មានភាពប្រសើរនៅឡើយទេ ។ ពួកក្មេងស្ទាវចាប់រំលោភស្ត្រីរកស៊ីផ្លូវភេទក្លាយជារឿងធម្មតាទៅហើយ ពីព្រោះភាគច្រើននៃអ្នកទាំងនោះមិនបានប្រើស្រោមអនាម័យទេ ។ អ្នកស្រីក៏បានបន្តទៀតថា "ស្ត្រីដែលមានជីវភាពក្រីក្រខ្លះធ្លាប់រងនូវការចាប់រំលោភ ដោយបុរសពី៨, ១០, ២០ នាក់ ពួកគេវាយធ្វើបាបស្ត្រីទាំងនោះ ពោលគឺស្ត្រីរងគ្រោះទទួលនូវការប្រើអំពើហិង្សាច្រើនណាស់ ។ ដែលស្ត្រីខ្លះទៀត ស្ទើរក្លាយជាមនុស្សដែលបាត់សតិអារម្មណ៍ទៅហើយនោះ ។

ចំពោះ HIV/AIDS ក៏នៅតែជាបញ្ហាមួយធំចំពោះស្ត្រីរកស៊ីផ្លូវភេទក្នុងប្រទេសកម្ពុជាផងដែរ បើទោះបីជាមានអត្រាធ្លាក់ចុះខ្លះក៏ដោយ ។ យោងទៅតាមក្រសួងសុខាភិបាលប្រហែលជា២០ភាគរយ ( **តទៅទំព័រទី១៧** )

**សម្តេចក្រុមព្រះ: ហ៊ុន សែន...** ហ៊ុន សែន និយាយនោះ គឺខុសស្រឡះអំពីរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីអំពីគណ-បក្សនយោបាយ ។

**+ខ្មែរប៉ុស្តិ៍ :** ព្រះអង្គ !... មានក្រុមអ្នកតាមដាននយោបាយ ឬអ្នកវិភាគនយោបាយក្តីគេគិតថា ដោយ



ហ៊ុន សែន



នរោត្តម រណឫទ្ធិ

សារតែព្រះមហាក្សត្រមិនបានប្រើប្រាស់តួនាទីជាព្រះរាជបុព្វសិទ្ធិរបស់ព្រះអង្គ និងការមិនចេញនូវព្រះរាជប្រតិកម្មអ្វីសោះ ចំពោះព្រឹត្តិការណ៍នានា ទៅលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន វិញ ដោយសារតែការខ្លាចបាត់បង់រាជបល្ល័ង្គ ឬដួលរំលំរបបរាជានិយម និងក្រុមរាជវង្សក្តី ដែលបញ្ហានេះ តើព្រះអង្គទតឃើញយ៉ាងដូចម្តេចដែរ ?

**+សម្តេចក្រុមព្រះ :** ក្នុងនាមខ្ញុំជាក្សត្រមួយអង្គ ខ្ញុំពុំហ៊ានធ្វើអត្ថាធិប្បាយអ្វីមួយដែលប៉ះពាល់ដល់អតីតព្រះមហាក្សត្រ ដែលជាព្រះរាជបិតារបស់ខ្ញុំ ឬក៏ជាព្រះមហាក្សត្រនោះទេ ។ ប៉ុន្តែ ខ្ញុំសុំនិយាយថា ចំពោះខ្លួនខ្ញុំ ខ្ញុំមានការឈឺចាប់ណាស់ ដែលខ្ញុំឃើញ (តែខ្ញុំសុំទុកព្រះកុរណាមួយដោយឡែក) ដែលខ្ញុំឈឺចាប់ណាស់ ដែលស្តេចមួយចំនួនយកសុខនិយាយថា ដេកស្រួលស៊ីស្រួល នៅលើគំនរទុក្ខរបស់ប្រជារាស្ត្រ ៕

## គ្មានការចោទប្រកាន់...

នៃឆ្នាំ១៩៤៩ (ការសម្លាប់ដោយចេតនាការប្រព្រឹត្តអមនុស្សធម៌ ការបង្កព្យសនកម្មធ្ងន់ធ្ងរ ឬការធ្វើឱ្យមានការឈឺចាប់ខ្លាំងដោយចេតនាដល់រាងកាយ និងសុខភាពការដកហូត ដោយចេតនានូវសិទ្ធិទទួលបានការជំនុំជម្រះក្តី ដោយយុត្តិធម៌ ការនិរទេស ឬជន្លៀស ឬការបង្ខាំងជនស៊ីវិល ដោយខុសច្បាប់)"។ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ របស់សហចៅក្រមស៊ើបអង្កេត)។

(៥) អៀង ធារិទ្ធ ហៅ ភា : " បទល្មើសប្រឆាំងនឹងមនុស្សជាតិ (មនុស្សឃាត ការធ្វើទុក្ខបុកម្នេញ ការសំលាប់បំផុតពូជ និងអំពើអមនុស្សធម៌ឯទៀត)"។ (ដីកាសម្រេចឃុំខ្លួន បណ្តោះអាសន្ន ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់សហចៅក្រមស៊ើបអង្កេត) ។

តុលាការខ្មែរក្រហមមិនបានធ្វើការចោទប្រកាន់ទៅលើមេដឹកនាំខ្មែរក្រហមទាំងនេះពីបទប្រល័យពូជសាសន៍ទាស់តែសោះ ។ មានបទឧក្រិដ្ឋពីរដែលតុលាការនេះបានយកទៅចោទប្រកាន់មេដឹកនាំខ្មែរក្រហម ដែលគេអាចយល់ច្រឡំបានថា ជាបទប្រល័យពូជសាសន៍ គឺមួយ "ការសម្លាប់រង្គាល" ដែលយកទៅចោទទៅលើ កាំង ហ្គេចអ៊ាវ ហៅ ឌុច និងពីរ គឺ



កាំង ហ្គេចអៀវ ហៅ ឌុច



នួន ជា

"ការសម្លាប់បំផុតពូជ" ដែលយកទៅចោទលើជនជាប់ចោទឯទៀតទាំង៤រូប ។ "ការសម្លាប់រង្គាល" ដែលពាក្យអង់គ្លេសថា "Extermination" ក៏មិនមែនជា "ការប្រល័យពូជសាសន៍" ដែរទេ ។

"អនុសញ្ញាស្តីអំពីការបង្ការ និងផ្តន្ទាទោស ចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ "បានឱ្យនិយមន័យដល់ "ការប្រល័យពូជសាសន៍" ដែលអង់គ្លេសថា "Genocide" ក្នុងមាត្រា២ថា "ជាអំពើណាមួយក្នុងចំណោមអំពើទាំង ប៉ុន្មានខាងក្រោមនេះ ដែលត្រូវបានធ្វើឡើងក្នុងបំណងបំផ្លាញ ទោះជាទាំងស្រុងក្តី ឬក៏ខ្លះៗក្តីដល់ប្រជាជាតិមួយពូជសាសន៍មួយ ឬក៏ក្រុមសាសន៍ ឬសាសនាណាមួយដូចជា :

ក-ការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម ។

ខ-បង្កការឈឺចាប់ និងខូចខាតយ៉ាងដំណំខាងផ្នែករាងកាយ ឬផ្នែកសតិបញ្ញាដល់សមាជិកទាំងឡាយនៅក្នុងក្រុមនោះ ។

គ-បង្កឡើងដោយចេតនានូវមហន្តរាយ ឬការហិនហោចដល់ស្ថានភាពរស់នៅរបស់សង្គមមនុស្សដោយកំទេចបំផ្លិចបំផ្លាញក្រុមទាំងមូល ឬផ្នែកខ្លះនៃក្រុម ។

ឃ-ដាក់បង្ខំនូវវិធានការណ៍នានាដែលបង្ការមិនឱ្យមានកំណើតទារកនៅក្នុងក្រុម ។

ង-យកកូនក្មេងពីក្រុមមួយទៅដាក់នៅក្នុងក្រុមមួយទៀតដោយបង្ខំ ។

អនុសញ្ញាដដែលបានចែងក្នុងមាត្រា៣ថា "ការប្រព្រឹត្តខាងក្រោមនេះ នឹងត្រូវផ្តន្ទាទោស" :

ក-ការប្រល័យពូជសាសន៍

ខ-ការរួមគំនិតដើម្បីធ្វើការប្រល័យពូជសាសន៍។

គ-ជំរុញដោយផ្ទាល់ និងជាសាធារណៈ ដើម្បីធ្វើការប្រល័យពូជសាសន៍ ។

ឃ-ការប៉ុនប៉ងធ្វើការប្រល័យពូជសាសន៍ ។

ង-ការឃុបឃិត ឬចូលដៃក្នុងការប្រល័យពូជសាសន៍ ។

"ប្រភព : អត្ថបទខ្មែរនៃអនុសញ្ញានេះ បោះពុម្ពផ្សាយ ដោយការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ដោយមានការកែសម្រួលបន្តិចបន្តួច" ។

ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជាឧក្រិដ្ឋកម្ម មួយដែលមានចែងយ៉ាងច្បាស់នៅក្នុងមាត្រា៤ នៃ "ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ឆ្នាំ២០០១ (និងវិសោធនកម្មបន្តបន្ទាប់) សំរាប់ឱ្យតុលាការនេះ ធ្វើការចោទប្រកាន់ទៅលើមេដឹកនាំខ្មែរក្រហម ។ មាត្រានេះដកស្រង់ទាំងស្រុងនូវនិយមន័យ និងការផ្តន្ទាទោសពីមាត្រា ២ និង៣ នៃអនុសញ្ញា ដូចមានចែងខាងលើ ។

នៅក្នុងពេលដែលតុលាការខ្មែរក្រហមពុំមានការចោទប្រកាន់ទៅលើមេដឹកនាំខ្មែរក្រហមធំៗជាងគេ ដែលនៅរស់ពីបទប្រល័យពូជសាសន៍ ដូច្នេះតើគេអាចយល់បានថា ការប្រល័យពូជសាសន៍នៅក្នុងរបបខ្មែរក្រហមពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ ១៩៧៩ វាអត់មានទេនោះបាន ឬទេ ? បើសិនជាអត់មានការប្រល័យពូជ-សាសន៍ តើការកាត់ទោស ប៉ុល ពត និង អៀង សារី ពីបទប្រល័យពូជសាសន៍ និងការចោទប្រកាន់ និងការហៅរបបខ្មែរក្រហមជារបបប្រល័យពូជសាសន៍ទាំងនេះវាមិនខុសអស់ទៅហើយឬ ? ឬក៏ទាំងអស់នេះ វាគ្រាន់តែជាការឃោសនាបែបផែននយោបាយតៗគ្នាតែប៉ុណ្ណោះ ? តែដំណាក់កាលនេះគេនៅមិនទាន់អាចឆ្លើយទៅនឹងសំនួរទាំងនេះបាន ឬសន្និដ្ឋានយ៉ាណាបាននៅឡើយទេ ។ ក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នសហចៅក្រមស៊ើបអង្កេតតែងតែបានបើកវង់ក្រចកជូនជាព័ត៌មានជាអាទិ៍ថា "ការស៊ើបសួរ... កំពុងដំណើរការដែលអាចឱ្យកំណត់បទល្មើសផ្សេងទៀត... និងដែលអាចដាក់បន្ទុកលើជនត្រូវចោទ" ។ គេត្រូវរង់ចាំមើលលទ្ធផលស្ថាពរនៃការស៊ើបអង្កេត និងការស៊ើបសួរ ថាតើ "បទល្មើសផ្សេងទៀត" នឹងមានបទប្រល័យពូជសាសន៍ ឬក៏អត់ទេ ។ ពេលនោះគេនឹងអាចឆ្លើយទៅនឹងសំនួរទាំងប៉ុន្មានខាងលើ ឬសន្និដ្ឋានយ៉ាងណាបានហើយ ។ ការប្រល័យពូជសាសន៍ វាជាការពិត ឬមិនពិតនៅពេលនោះ ៕

**New World Travel II**
**ញូវើលត្រាវែលធូ**
Specialized in Selling Flight Tickets
For National and International
ជំនាញខាងលក់សំបុត្រយន្តហោះសំរាប់ក្នុងប្រទេស និងអន្តរជាតិ យើងតំណាងឱ្យក្រុមហ៊ុន ចិន កូរ៉េ កាថៃ ។ល។ ធ្វើលិខិត Re-Entry Permit ប្រញាប់ជូនបាន ទិញសំបុត្រជិះនាវាសមុទ្រ-សណ្ឋាគារ ឬជួលឡាន សំបុត្រយន្តហោះទៅច្រើនប្រទេសក្នុងតម្លៃទាបបំផុត ។
Represented Several of Company such as China, Korea, Cathay etc.,
Offer Rush Re-Entry Permit
Reserve Cruise, Hotels and Car Rentals
Best Price Air Ticket for Many Destinations
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

# វិធីធ្វើសាច់ឡុកឡាក់ ឬសាច់ប៊ីស្តីក ឱ្យទន់ផុយ គួរឱ្យចង់ទទួលទាន



• នៅពេលអ្នកចំអិនអាហារប្រភេទសាច់ ហើយបើចង់ឱ្យវាទន់ផុយគួរឱ្យចង់ទទួលទាននោះ មិនពិបាកទាល់តែសោះដោយគ្រាន់តែណែនាំឱ្យអ្នកចាក់ទឹកខ្មេះបន្តិចរួចយកវាទៅត្រាំផ្លាប់ជាមួយប្រេងធញ្ញជាតិចោលរយៈពេល២ម៉ោង នោះ បន្ទាប់មកអ្នកអាចយកទៅចំអិនធ្វើឱ្យសាច់ផុយ ហើយទន់គួរឱ្យចង់ទទួលទាន់បំផុត ៕


**Credent** REAL ESTATE

2101 Tyson Ave. Philadelphia, PA 19149
Office # 215-338-5650, Fax # 215-338-5651



Charlie Kien Broker/Owner ABR
charliekien@credent.us

**We provide completed Real Estate and Mortgage Services**

យើងផ្តល់ជូនលោកអ្នកនូវការទិញ លក់ អចលនវត្ថុគ្រប់យ៉ាង ហើយនឹងធ្វើសេវាហិរញ្ញវត្ថុសម្រាប់អចលនវត្ថុទាំងនោះជូនទៀតផង

> First time home buyer grant up to $7,800 ទិញផ្ទះដំបូងរដ្ឋអាចជួយរហូតដល់ $7,800
> Purchase Home & New Contraction ទិញផ្ទះនិងសង់ផ្ទះថ្មី
> Refinance វាយតម្លៃអចលនវត្ថុសាជាថ្មី ហើយដកប្រាក់ចំណេញជូន
> Want to sell your house បំណងលក់ផ្ទះ

**For more information, please call Charlie Kien**

**Direct # (267) 688-6626**

**Nationwide**

Insurance & Financial Service

សេវាធានារ៉ាប់រង និងហិរញ្ញវត្ថុ

We offer Cheap Price for Every Client

យើងធ្វើជូនគ្រប់ភ្ញៀវដោយតម្លៃទាប

| | |
|---|---|
| Business Liability Insurance | ធានារ៉ាប់រងជំនួញលោកអ្នក |
| Home Insurance | ធានារ៉ាប់រងផ្ទះសម្បែង |
| Health Insurance | ធានារ៉ាប់រង សុខភាព |
| Auto Insurance | ធានារ៉ាប់រងរថយន្ត |
| Life Insurance | ធានារ៉ាប់រងជីវិត |

Discount 30% when you purchase Home & Auto Insurance

ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញ ធានារ៉ាប់រង ផ្ទះ និងរថយន្តរួមគ្នា

South Philadelphia office:
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

North Philadelphia office:
6603 Bustleton Ave.
Philadelphia, Pa 19149
Tel: (215) 335-2140
Fax: (215) 335-2147

# លោកមានសុខភាពរាល់ថ្ងៃ មិនប្រក្រតី សូមប្រើ RELIV

## សក្ខីកម្ម

ខ្ញុំមានជំងឺ Cancer ខួរក្បាល ហើយបានវះក្បាលពីរដង ខ្ញុំស្ថិតក្នុងការព្យាបាល Chemotheraphy ១៨ ខែ ....ពីរឆ្នាំក្រោយមកខ្ញុំមានគ្រោះថ្នាក់រថយន្តទៀត ។

ពេលបានជួប Relive មួយឆ្នាំក្រោយមកការឈឺចុកចាប់ក៏បាត់ទៅអស់ ខ្ញុំប្រែមានកម្លាំង ហើយអាចហាត់ប្រាណវិញបាន មិនតែប៉ុណ្ណោះចុះទម្ងន់ទៀតផង ។

Stephanis -Emmons (817) 847-5476



The Reliv scientists formulate the most recent nutrition research into products that scientifically advance, nutritionally complete, and is proven to restore the boby functions.

របៀបប្រើ : រៀងរាល់ព្រឹក ដួស RELIV មួយស្លាបព្រាវង្វាល់ពីកំប៉ុង A មួយស្លាបព្រាវង្វាល់ទៀត ពីកំប៉ុង B ដាក់ទៅក្នុងកែវមានទឹកធម្មតា ឬទឹកផ្លែ ឈើ កូរលាយគ្នា រួចពិសារព្រឹកម្តង ល្ងាចម្តងទទួលលទ្ធផលទាន់ចិត្ត

● ទូរស័ព្ទសំរាប់ជាវ (636) 537-9715

ជាវ ១ RELIV CLASSIC : A
២ RELIV INNERGIZE : B

កុំភ្លេចឱ្យលេខ Reliv Distributor :
(RNC.# 7070 438001)

● ទូរស័ព្ទ : (267) 253-3947 សំរាប់ហៅ បើលោកចង់ចែកចាយជូនមិត្តភក្តិបងប្អូនបន្ត ទៅទៀតជា Relive Distributor

RCN# 7070438001 www.reliv.com

នៅ VIRGINIA CALL VANNDY 1-703 415- 6257

Please Call : (267) 253-3947

# ស្ថានភាពអន្លង់វែង...

បាន ហើយវាថា យើងខ្ញុំវៃ... ទៅវៃយ៉ាងម៉េច ខ្មែរតូចប៉ុណ្ណឹងតិចប៉ុណ្ណឹង មានអាវុធប៉ុណ្ណឹង ចង់តែរស់នៅដោយសុខសាន្ត ។ វា (យួន) ចង់បានសហព័ន្ធឥណ្ឌូចិនរបស់យួន ។ ពីមុនក៏វាធ្វើអញ្ចឹង ឥឡូវក៏វាធ្វើអញ្ចឹង នៅតែដដែលគ្មានប្រែប្រួលទេ ។ ឥឡូវនេះ អាយ៉ងៗនេះ "បក្សប្រជាជននេះ "ពីមុនហៅថា "បក្សកុម្មុយនិស្តឥណ្ឌូចិន" ក្រោយមកចែកជាបក្ស ៣ :"បក្សពលកររៀត-ណាមបក្សប្រជាជនបដិវត្តខ្មែរបក្សប្រជា-ជនបដិវត្ត ឡាវ " គ្រាន់តែចែកជា៣ទេ តែយុទ្ធសាស្ត្រតែមួយ ។ វាថាប្រទេសតែមួយ១ វាថា "បីបង ប្អូន" ពាក្យយួន ពាក្យខ្មែរថា "បងប្អូន៣នាក់" ។ វាថា ទី១ យុទ្ធសាស្ត្រការពារដែនដីវា ខ្ញុំយល់ថា ចុះបើមកយកដែនដីកម្ពុជាម៉េចកើតយើងមិនត្រូវការពារទឹកដីយើង ! ទី២ វាថា យកបរិវេណ ដែនដី ដើម្បីមនុស្ស វាច្រើន វាដោះស្រាយមនុស្ស វាច្រើនណាស់ ឥឡូវជាង៧០លានហើយ ។ ខ្មែរក៏ចង់រស់ដែរ ដូច្នេះខួរក្បាលខ្ញុំ ...ខ្ញុំមិនចង់ និយាយទេ បើនិយាយចេះតែទឹកភ្នែក កុំឱ្យយួនវា យកខ្មែរបានអត់ដី ! អត់ទឹក ! ខ្មែរ ! ខ្មែរណាក៏ដោយ ។ ខ្ញុំប្រាប់អ្នកទាំងអស់គ្នាថា ខ្ញុំស្លាប់ទៅ ខ្ញុំអត់ស្តាយទេ កុំឱ្យតែយួនវាយកទឹកដីកម្ពុជា បាន ។ បើឡាវយកស្រេចទៅហើយ តាមកិច្ចព្រមព្រៀងឆ្នាំ ១៩៧៧ អត់ព្រំដែនទេ ។

**សំនួរ :** តើមានធ្វើកិច្ចព្រមព្រៀងជាមួយខ្មែរដែរ ឬទេ នៅឆ្នាំ ១៩៧៧ នោះ ?

**ប៉ុល ពត :** អត់ទេៗ!អានេះ កិច្ចព្រមព្រៀងជាមួយឡាវ យួន និង ឡាវ រំលាយព្រំដែនចូលគ្នាជាមិត្តភាពសហការ ។ ខ្ញុំទៅជួបអាឡេយន់ជាប្រតិភូ វាខ្ញុំស្នើរថា ឱ្យមានកិច្ចព្រមព្រៀងសន្ធិសញ្ញាមិត្តភាពសហការរវាងកម្ពុជា និងយួន វាអត់ឆ្លើយ នៅឆ្នាំ ១៩៧៥ ហើយវាវៃ តែព្រំ-ប្រទល់ ។ ដល់វៃអញ្ចឹង ដូចជាយកកាំបិតមកចាក់ក្នុងទ្រូងអាញ្ចឹង ! ក្នុងនាមជាអ្នកទទួលខុសត្រូវម្នាក់ គេយកដី ម្យ៉ាងហើយៗ ប្រជាជនអត់ដីធ្លី តែកាលនោះ មិនដល់ឥឡូវទេ ។ ដល់វារំលំកម្ពុជាប្រជាធិបតេយ្យឆ្នាំ ១៩៩៧៩ ។



ពិន សំខុន នៅផ្លូវចូលអន្លង់វែង

( នៅមានត )





Buy now on DVD

award winning film about a Cambodian American family's story

www.NewYearBaby.net

Phone Order: 877-345-6222

Find out more about Socheata Poeuv's organization Khmer Legacies:

www.KhmerLegacies.org

ទិញនៅទីនេះ

"ទទួលពានរង្វាន់ខ្សែភាពយន្តស្តីអំពីរឿងគ្រួសារខ្មែរ-អាមេរិកាំង

www.NewYearBaby.net លេខទូរស័ព្ទបញ្ជាទិញ (877) 345-6222

បើចង់ដឹងបន្ថែមពីអង្គការ "ខ្មែរឡេហ្គាស៊ី" របស់ សុជាតា ពៅ : www.KhmerLegacies.org

# Lynn Skin Care

Professional Esthetician

215-467-4082

ហាងថែរក្សាស្បែក លីន

អាចធ្វើឱ្យផ្ទៃមុខអ្នកផ្លាស់ប្តូរទៅជាភ្លឺថ្លា ហើយឃើញសាច់អ្នកម៉ត់ល្អស្អាតឥតខ្ចោះ នេះគឺជាភាពស័ក្តិសិទ្ធិនៃ "ស្បតអីរេស័រ" ។ កុំភ្លេចសួររកឱសថថែស្បែកមុខផ្សេងៗទៀត...សំរាប់បំបាត់ស្បែកជ្រីវជ្រួញជាដើម...ហាងយើងខ្ញុំអាចប្តូរឱ្យសម្ផស្សឱ្យមានភាពប្រសើរ ដូចបំណងប្រាថ្នារបស់អ្នកបាន

បើមុខខ្មៅ_កើតមុន ឬកើតអាចម៍រុយលើផ្ទៃមុខ !!

**WHITE SHOT**

works magically transforming your skin from dark spots, or freckle to a bright and perfect looking skin.

**WRINKLE SHOT**

The new formula that is long-lasting, And deep-acting wrinkle fighter

**WHITISSIMO PRESSED POWDER**

Gives a soft and translucent look while help brighten your face all day long.

**LIQUID FOUNDATION**

Has a moisturizing texture similar to a brightening moisturizer, resistant to strong sunlight, and covers any blemishes






Sale & Skin Care Consultant: Lynn B. Kong

Open 7 Days A Week: Sun to Thurs: 10 a.m. – 7 p.m. / Fri. & Sat: 10 a.m. – 8 p.m.

1730 Snyder Avenue. Philadelphia, Pa 19145